ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Mar-2012, 15:11
CMS/CFO: Kauv Keoratanak

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
## ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី៤២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
លោក ដាវ អានសាន
កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*
លោក ម៉ាតេអូ គ្រីបប៉ា *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
លោក វីល្លៀម ស្មីត *(Mr. William SMITH)*
លោក ឌេល លីសាក់ (*Mr. Dale LYSAK*)
លោក ពេជ្រ សម្បត្តិ
កញ្ញា សារ៉ាស អេនឌ្រូ *(Ms. Sarah ANDREWS)*
លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ *(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ស៊ីន សុវ៉ន

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោក បាណាបេ ណេគុយ

*(Mr. Barnabé NEKUIE)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា លី ម៉ាញៀន | អង់គ្លេស |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សីលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរបន្តដោយលោក វីល្លៀម ស្មីត ផ្តើមពី៖ ..................................................................ទំព័រ០២

## កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៤២]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះយើងនឹងបន្តស្តាប់សក្ខីកម្មរបស់សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលនឹងសួរដេញដោលដោយក្រុមសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងមេធាវីការពារ ហើយនិងសាធារណជនទាំងអស់នៅទីនេះ។ ហើយក៏ជម្រាបសួរលោកសាក្សីផងដែរ។

[០៩:០៦:១៥]

**សួរបន្តដោយលោក វីល្លៀម ស្មីត៖**

កាលពីម្សិលមិញយើងបានបញ្ចប់ការពិភាក្សាមួយ និយាយអំពីឯកសារមួយចំនួន ដែលបង្កើតឡើងនៅស-២១ ហើយនិងព័ត៌មានមួយចំនួនដែលត្រូវបានកត់ត្រានៅលើឯកសារនោះ។ ដូច្នោះហើយយើងបានយល់ដឹងអំពីព័ត៌មាន ហើយនិងប្រាស្រ័យទាក់ទងទៅកន្លែងផ្សេងទៀត ហើយយើងនឹងបង្ហាញជូននូវឯកសារមួយចំនួន ហើយសូមឲ្យលោកពិនិត្យមើលថាតើលោកស្គាល់ឯកសារហ្នឹងឬទេ? ហើយសូមលោកជម្រាបជូននូវព័ត៌មានអំពីទម្រង់ និងឯកសារនោះ ថាតើជាឯកសារពិតរបស់ស-២១ ឬទេ? ថាតើមានអ្វីមាននៅលើឯកសារនោះដែលធ្វើឲ្យលោកនឹកឃើញអំពីព័ត៌មាននោះ ថាតើកត់ត្រាដោយវិធីណា?

លោក លោកស្រីចៅក្រម ខ្ញុំចង់បង្ហាញនូវឯកសារពីរដំបូង IS3.5 ហើយនិង IS3.1 ហើយយើងមានអត្ថបទជាភាសាខ្មែរសម្រាប់ជូនសាក្សី ហើយនិងសូមស្នើតុលាការបង្គាប់ឲ្យអ្នកគ្រប់គ្រង

សំណុំរឿងបញ្ជូនឯកសារទៅដល់សាក្សីបាទ។ បាទ IS3.5 សូមបង្ហាញនៅលើអេក្រង់បាទ។

**ស៖** លោក កាំង ហ្គេកអ៊ាវ លោកមើលឯកសារហ្នឹង តើលោកស្គាល់ទេ? ថាតើចំណាត់ថ្នាក់ប្រភេទឯកសារហ្នឹងអ្វី? តើលោកស្គាល់ឯកសារហ្នឹងដែរឬទេបាទ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះ ពិតជាឯកសាររបស់ស-២១។ ច្បាស់លាស់មែនទែន គឺអក្សរដៃដែលសរសេរនេះ គឺអក្សរ មិត្តហ៊ៃ អនុប្រធានរបស់ខ្ញុំ។ ឯឯកសារនេះសម្រាប់កត់ត្រាអ្នកដែលជាប់ទៅទីនោះ ព័ត៌មានលម្អិតអ្នកដែលចូលទៅដល់ទីនោះ សម្រាប់ឃុំឃាំងនៅភ្នំពេញ មិនមែនសម្រាប់យកទៅព្រៃសទេ សម្រាប់ឃុំឃាំងនៅភ្នំពេញ។

[០៩:០៩:០៣]

**ស៖** សូមអរគុណ។ មើលឯកសារនេះ តើលោកអាចអញ្ជើញអាននូវចំណងជើង ថាតើឯកសារហ្នឹងឈ្មោះថាអ្វីបាទ?

**ឆ៖** ឯកសារនេះមានចំណងជើងថា "ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង"។

**ស៖** ហើយឯកសារនៅនេះ គឺថា-- ហើយនៅក្នុងនេះឈ្មោះអ្នកជាប់ឃុំហ្នឹងឈ្មោះអ្វីដែរបាទ?

**ឆ៖** អ្នកជាប់ឃុំនោះឈ្មោះ ផល វ៉ា ឈ្មោះបដិវត្តន៍ ឬក៏ឈ្មោះប្រែហ្នឹងហៅ ណាត។

**ស៖** នៅក្នុងឯកសារ នៅចំណុចទីបី ដែលនិយាយថា ក្រសួង និងនាទី ចាប់ថ្ងៃចូលបដិវត្តន៍រហូតដល់បច្ចុប្បន្ន ថាតើព័ត៌មាននោះគឺទទួលបានទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យនោះ មានព័ត៌មានអ្វីដែរឬទេ?

**ឆ៖** ត្រង់ទីបីនេះ ក្រសួង និងនាទីចាប់ពីថ្ងៃចូលបដិវត្តន៍រហូតបច្ចុប្បន្ន នេះគឺ មិត្តហ៊ៃ កត់ត្រាតាមការសួរអ្នកជាប់ឃុំឃាំងដែលឈរចំពោះមុខគាត់។

**ស៖** ថាតើនេះជាប្រភេទនៃឯកសារ ដែលលោកបាននិយាយយោងដល់ពីម្សិលមិញនោះ នៅពេលដែលគេបញ្ជូនមនុស្សមកដល់ស-២១ ដំបូងហើយត្រូវគេកត់ត្រាព័ត៌មានសង្ខេប តើប្រភេទឯកសារហ្នឹងទាក់ទងទៅនឹងសេចក្ដីលម្អិតដែលស-២១ កត់ត្រាពីអ្នកទោសនោះបាទ?

[០៩:១១:៣០]

**ឆ៖** ហ្នឹងជាព័ត៌មានដំបូងដែលស-២១ កត់ត្រាពីអ្នកទោសដែលខ្ញុំរាយការណ៍ពីម្សិលមិញហើយ។

**ស៖** តើលោកឯកភាពជាមួយខ្ញុំទេ គឺថាឯកសារនេះមានសេចក្ដីលម្អិតដូចជា អាយុ មុខងារដែលអ្នកនោះកាន់តាំងពីគេចូលបដិវត្តន៍ ហើយឈ្មោះឪពុកម្ដាយ ទីកន្លែងកំណើត ហើយនិងទីកន្លែងដែលចាប់ខ្លួននោះផងដែរ? តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពិតជាអ៊ីចឹងហើយ។

**ស៖** ហើយទាក់ទងទៅនឹង ផល វ៉ា គាត់ជាគណៈកម្មការនៃគណៈកម្មការពាណិជ្ជកម្មប្រចាំហុងកុង ហើយត្រូវចាប់ខ្លួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ តើព័ត៌មានហ្នឹងត្រឹមត្រូវតាមហ្នឹងដែរឬទេបាទ?

**ឆ៖** ព័ត៌មាននេះត្រឹមត្រូវតាមនុ៎ង។

**ស៖** ហើយប្រសិនបើយើងមើលឯកសារ 3.1 ដែលជាប្រវត្តិរូប ថាតើលោកឃើញទេនៅក្នុងប្រវត្តិរូបនេះ? តើគាត់មានប្រពន្ធ-- គាត់ជាប្រពន្ធរបស់ ផល វ៉ា ហើយក៏ត្រូវបានឃាត់ខ្លួននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៨ តើព័ត៌មានហ្នឹងត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[០៩:១៣:៥៥]

**ស៖** ហើយៗព័ត៌មានបឋមរបស់អ្នកទោសបែបនេះ តើផ្នែកណាមួយនៃស-២១ ដែលគេរក្សាទុកឯកសារប្រភេទនេះបាទ?

**ឆ៖** ខ្ញុំភ្លាប់ដល់ជម្រៅមិនច្បាស់ទេ តែឯកសារនេះតម្កល់នៅនឹងសាលាកណ្ដាល។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំបានបញ្ចប់ជាមួយឯកសារពីរនេះហើយ ប្រសិនបើយើងមើលឯកសារបន្ថែមទៀតនេះ គឺ IS3.5 ជាឯកសាររូបថត។ សូមអនុញ្ញាតតុលាការដាក់តាំង ដាក់បង្ហាញនូវលើអេក្រង់ ហើយនិងសូមឲ្យលោកពន្យល់អំពីរូបថតនេះ ថាតើលោកស្គាល់ដែរទេ? ថាតើប្រភេទរូបថតនេះគេប្រើប្រយោជន៍អ្វីដែរ? បើយើងមើលរូបថតនៅខាងស្ដាំដៃចំពោះមុខនេះ តើប្រភេទ ហើយនិងជាទម្រង់រូបថតនេះ លោកស្គាល់ថាជាប្រភេទបែបណាទេបាទ?

[០៩:១៥:៤៣]

**ឆ៖** រូបថតនៅខាងស្ដាំដៃនេះជារូបថតដែលស-២១ ថត ដើម្បីតម្កល់បិទៗនៅក្នុងបញ្ជី តម្កល់ឬក៏បិទនៅក្នុងបញ្ជី។

**ស៖** រូបថតនេះនៅក្នុង-- បាទ ដែលរូបថតមួយខាងក្រោមថា ផល វ៉ា ហៅ ណាត ហើយក៏មានឈ្មោះនៅក្នុងប្រវត្តិរូប នេះជាផ្នែកដែលថានីតិវិធីធម្មតា បែបបទធម្មតាដែលថាអ្នកទោសមក

ដល់គេត្រូវថតរូប ហើយកត់យកព័ត៌មានសង្ខេប មុននឹងដាក់បញ្ចូលទៅក្នុងកន្លែងឃុំឃាំង។ តើបែប នោះដែរឬទេ?

[០៩:១៦:៣៣]

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** តើរូបថតគ្រប់តែអ្នកទោសទាំងអស់នៅស-២១ នៅពេលដែលគេមកដល់នោះ គេថត គ្រប់គ្នាទាំងអស់ដែរឬទេ?

**ឆ៖** ជាគោលការណ៍ថតគ្រប់គ្នា ក៏ប៉ុន្តែអាចអត់នៅក្នុងរយៈដំបូង នៅពេលចាប់តាំងពីថ្ងៃ១៧ មេសា រហូតមកដល់រវាងខែ១០ ខែ១១ ចាប់តាំងពីពេលដែលខ្ញុំឡើងកាន់កាប់ជាប្រធានថតទាំងអស់។ ក៏ប៉ុន្តែ ក្នុងនុំងមានអ្នកទោសពិសេស ដែលប្រគល់ឲ្យកងពិសេសយាមការពារផ្ទាល់ ហើយអ្នកសួរក៏ ពិសេសដែរ នុំងគឺប្រហែលជាអត់រូបថតទេ ដូចជារូបថត កុយ ធួន អីប្រហែលជាអត់ដែរ នេះតាមខ្ញុំ ស្មានទេ។

**ស៖** ហេតុអ្វីបានជាមានករណីថា មានអ្នកទោសពិសេសបែបនេះមិនត្រូវបានគេថតរូបនោះ?

**ឆ៖** ដើម្បីរក្សាការសម្ងាត់ វិធានការនៅស-២១ ដែលមេណែនាំ អ្នកទោសសំខាន់មែនទែន ដែលចូលទៅដល់មិនឲ្យអ្នកណាដឹងទេ។ ដាក់គុកពិសេស កងពិសេសយាម ហើយអ្នកទៅថត ក៏ចូល មិនចុះ ហើយអ្នកកត់ត្រាថ្ងៃចូល ក៏ចូលមិនចុះ។

**ស៖** តើអ្នកណាជាអ្នកធ្វើចំណាត់ថ្នាក់ថា អ្នកនោះជាអ្នកទោសពិសេស ឬក៏អ្នកទោសប្រភេទ អ្វី? ថាតើប្រភេទមនុស្សបែបណា ដែលគេចាត់ទុកថាជាអ្នកទោសពិសេស?

[០៩:១៨:៤៦]

**ឆ៖** អ្នកទោសពិសេសភាគច្រើន គឺមេកំណត់មក សុន សេន គាត់កំណត់មកតែម្ដង។ មុននឹង ចាប់ កុយ ធួន ខ្ញុំដឹងយូរហើយ មេណែនាំមកឲ្យរៀបចំ រៀបយ៉ាងម៉េច សម្រាប់សួរ កុយ ធួន។ ព្រោះ កុយ ធួន ខ្ញុំធ្លាប់ទៅបម្រើគាត់នៅបឹងធំ ក្រោយរោងចក្រតម្បាញកំពង់ចាម។ ដូច្នេះមេគេដឹង ដូច្នេះ គាត់ណែនាំសព្វគ្រប់ទាំងអស់ ដូច្នេះអ្នកទោសពិសេស គឺមេកំណត់។

**ស៖** ថាតើអ្នកទោសពិសេសនោះ គឺជាអ្នកដែលមានតំណែងខ្ពស់នៅក្នុងរដ្ឋាភិបាល ឬនៅក្នុង បក្សឬ?

**ឆ៖** ប្រាកដហើយ។

[០៩:១៩:៤៤]

**ស៖** តើអ្នកណាជាអ្នកផ្តល់គំនិតថា ត្រូវថតរូបអ្នកទោសនៅពេលដែលគេចូលមកដល់? ថាតើបញ្ជាពីថ្នាក់លើ ឬក៏ប្រធាននៅស-២១ ជាអ្នកសម្រេចធ្វើបែបនេះ?

**ឆ៖** របៀបរបបនេះ មុនខ្ញុំកាន់កាប់ជាប្រធានបន្ទិច ជាខ្ញុំជាអនុប្រធានហើយបានមួយរយៈឃើញចាប់ផ្តើមថតហើយ។ ណាត កសាងអ្នកថតហ្នឹងហ្វូរហែមក នៅពេលមុនខ្ញុំចូល-- មុនពេលខ្ញុំកាន់កាប់កិច្ចការហ្នឹងបន្តិច គាត់ចាប់ផ្តើមឱ្យថតហើយ។

**ស៖** តើលោកដឹងពីមូលហេតុដែលត្រូវថតរូប តើគោលបំណងនៃការថតរូបនោះគឺថតដើម្បីអ្វី?

**ឆ៖** ថតរូបនេះ ដើម្បីពេលណាដល់មានរត់ មានអ្នកទោសរត់ យើងមានរូបថតសម្រាប់ផ្តិតទៅជូនអង្គភាពដើមឱ្យគេរក ជូនទូទាំងប្រទេសឱ្យគេរក ព្រោះអង្គាល់ជំនាន់នុំងអ្នកណាក៏នៅក្នុងសហករណ៍ ឬនៅក្នុងសហជីព ឬនៅក្នុងអង្គភាពយោធា ឬមន្ទីរ។ ដូច្នេះ យើងចាត់ភ្លាមៗទៅទាន់ពេលវេលា។ ហ្នឹងសំខាន់ត្រង់ហ្នឹងមួយ។

**ស៖** សូមអរគុណ។ យើងនឹងចេញពីប្រធានបទរូបថតនៅទីនេះ។ ខ្ញុំនឹងចូលទៅឯកសារមួយទៀតគឺ D108/2.6.82 ហើយសូមអនុញ្ញាតតុលាការដាក់តាំងឯកសារនោះ ទៅលើអេក្រង់ ហើយនិងខ្ញុំជូនឯកសារលើក្រដាសជូនលោកសាក្សី។ ហើយសូមឱ្យសាក្សីបញ្ជាក់ប្រាប់ខ្ញុំថាតើប្រភេទឯកសារហ្នឹងប្រភេទអ្វី? ចំណាត់ថ្នាក់អ្វី? ថាតើជាឯកសារអ្វីបាទ?

[០៩:២៣:២៨]

ជាបឋមសូមឱ្យលោកអានចំណងជើងនៃឯកសារនេះ ហើយបើលោកមានសេចក្តីសង្កេតថាឯកសារនេះប្រភេទអ្វី សូមលោកបញ្ជាក់តុលាការឱ្យបានដឹងផងបាទ។

**ឆ៖** ឯកសារនេះ មានចំណងជើងថា "ឈ្មោះអ្នកទោស ផ្នែកក្រសួងការបរទេស" បានន័យថាអ្នកទោសដែលចាប់ចេញមកពីក្រសួងការបរទេស។ ចំណាត់ថ្នាក់ឯកសារនេះ គឺជាស្ថិតិអ្នកទោសប្រចាំថ្ងៃដែលគេស្រង់យកក្នុងរយៈពេលនីមួយៗ។

**ស៖** ថាតើនេះជាឯកសារ ជាប្រភេទឯកសារដែលផលិត ឬក៏បង្កើតឡើងនៅស-២១ ឬ?

**ឆ៖** ច្បាស់លាស់ណាស់ ប្រភេទឯកសារនេះជាឯកសារធ្វើឡើងដោយគំនិតផ្តើមរបស់ស-២១ ផលិតនៅស-២១ ធ្វើឡើងដោយគំនិតផ្តើមរបស់ស-២១។

[០៩:២៤:៤៦]

**សៈ** តើលោកយល់ស្របជាមួយខ្ញុំទេថា ឯកសារនេះមានមនុស្សមួយចំនួន ដែលថាមានឈ្មោះ មានអាយុ មានភេទ ហើយនិងមានមុខងារ ហើយនិងថ្ងៃចូលផងដែរ?

**ឆៈ** យល់ស្រប។

**សៈ** កាលពីម្សិលមិញ លោកផ្តល់សក្ខីកម្ម ហើយលោកបានយោងទៅរកការអនុវត្តនៃការកត់ត្រានូវអ្នកទោសស-២១ នៅក្នុងបញ្ជីអ្នកទោស។ ថាតើនោះជាគំនិតរបស់លោក នៅពេលដែលលោកក្លាយជាប្រធាន ឬក៏ជាគំនិតរបស់ ណាត មុនពេលដែលលោកក្លាយជាប្រធាន? ឬក៏ជាគំនិតដែលចេញមកពីប្រភពផ្សេង ឬក៏ពីថ្នាក់លើណាដែរឬទេ?

**ឆៈ** ការងារបញ្ជីម្រយ ភាគច្រើនជាគំនិតផ្តើមរបស់ មិត្តហ៊ ទេ។ អង្កាល់ដែល ណាត នៅច្របូកច្របល់ណាស់។

**សៈ** ថាតើគោលបំណងនៃការធ្វើបញ្ជីនោះគឺដើម្បីអ្វី?

**ឆៈ** ធម្មតាទេ ធ្វើបញ្ជីគឺដើម្បីឲ្យវាច្បាស់លាស់ការងារ កុំឲ្យមេចោទប្រកាន់បាន ចាប់ថ្នាក់បានថាខ្លួនធ្វើការខ្ជីខ្ជា។ មិត្តហ៊ ធ្លាប់នៅទ័ព។ កងទ័ពគេមានស្ថិតិរបស់គេរាល់ថ្ងៃ។ មួយថ្ងៃយុទ្ធជនឈឺប៉ុន្មាន ជាប៉ុន្មាន ធ្វើការកើតប៉ុន្មាន គេមានច្បាស់លាស់របស់គេប្រចាំថ្ងៃ។ ដូច្នេះគំនិតហ្នឹងវាជាប់នៅក្នុងខ្លួនគាត់រហូតមក។ គំនិតបញ្ជីមួយរយហ្នឹងគឺគំនិត មិត្តហ៊។

[០៩:២៧:០៥]

**សៈ** សូមអរគុណ។ ខ្ញុំបានបញ្ចប់ជាមួយឯកសារមួយនេះហើយ ហើយខ្ញុំចង់ចូលទៅដល់ឯកសារមួយទៀត D43/4 សូមអភ័យទោសលោកចៅក្រម IS16.80 ឬក៏ D121.4 គឺឯកសារដដែលនោះទេ។ ហើយសូមជូនឯកសារលើក្រដាសទៅលោកសាក្សី ហើយនិងសូមតុលាការអនុញ្ញាតបង្ហាញលើអេក្រង់ផងដែរ។

លោក កាំង ហ្កេកអ៊ាវ សូមលោកមើលឯកសារនេះ ហើយសូមលោកអានចំណងជើងឯកសារនេះផង ហើយប្រសិនបើលោកអាចជម្រាបតុលាការបាន ថាតើលោកបានឃើញឯកសារហ្នឹងពីមុនទេ? ហើយប្រភេទឯកសារហ្នឹង ថាតើលោកស្គាល់ ឬក៏ធ្លាប់ជួបប្រភេទឯកសារនេះទេនៅស-២១?

[០៩:២៩:១៧]

**ឆៈ** អរគុណ។ ខ្ញុំសូមចាប់ផ្តើមពន្យល់បញ្ហានេះ។ ឯកសារនេះពិតជាយកចេញពីស-២១ មែនព្រោះឃើញ TSL នៅនុំង។ ក៏ប៉ុន្តែវាមិនមែនជាឯកសារស-២១ ធ្វើឡើងប្រើការក្នុងការងាររបស់ខ្លួន

ទេ។ ព្រោះពាក្យថាពេទ្យអង្គការ មិនមែនជាកូនផ្នែកមួយណារបស់ ស-២១ ទេ។ ពេទ្យអង្គការនេះ វាជាអង្គភាពមួយនៅខាងលើឯណោះទេ។ ដោយឃើញទំនាស់គ្នាបែបនេះ បញ្ហានេះមួយ ហើយបញ្ហាមួយទៀត សូមលោកសហព្រះរាជអាជ្ញាលោកពិនិត្យមើល ក្រដាសនេះជាក្រដាសចាស់ មានពាក្យថា ស្ពី*“ដេប៉ូ”* មានពាក្យថា ស្ពី *“អឺ ដេប៉ូ អូរីហ្ស៊ីន ដេស្ទីណាទែរ”*(ភាសាបារាំង) អីនេះ ស-២១ មិនប្រើទេ។ ដូច្នេះក្រដាសនេះប្រហែលជារើសយកក្រដាសចាស់ពីណាយកមកប្រើ ខាងពេទ្យអង្គការហ្នឹងរើសយកក្រដាសចាស់ពីណាយកមកប្រើទេ។ ស-២១ ប្រើសុទ្ធតែក្រដាសថ្មី។ ក្រដាសចាស់ គឺក្រដាសឯកសារដែលតម្កល់ យកពីមន្ទីររបស់ លន់ នល់ មក យកមកតម្កល់រក្សាទុក អាហ្នឹងមែន។ ដូច្នេះ ស-២១ មិនដែលយកក្រដាសចាស់ពីគេយកមកប្រើទេ។

[០៩:៣១:០០]

**ស៖** សូមអរគុណលោក។ ប្រសិនបើយើងពិនិត្យទៅលើឯកសារនេះ វាបានបញ្ជាក់អំពីឈ្មោះ ឈ្មោះបដិវត្តន៍ អាយុ ភេទ ព្រមទាំងតួនាទីរបស់បុគ្គល ព្រមទាំងថ្ងៃដែលចូល ហើយនិងថ្ងៃសួរចម្លើយតទៅទៀតផង។ តើលោកអាចជួយយើងបានដែរឬទេ ក្នុងការពន្យល់ថាតើថ្ងៃចូលហ្នឹងមានន័យថាម៉េច? ហើយថ្ងៃសាកសួរហ្នឹងតើចង់មានន័យយ៉ាងដូចម្តេចដែរ?

**ឆ៖** អរគុណ ដែលលើកបញ្ហានេះយកមកនិយាយ ហើយបញ្ជាក់ឲ្យខ្ញុំឆ្លើយ។ បញ្ហានេះធ្វើឲ្យខ្ញុំគិតទៅផ្សេងវិញទៀតទៅហើយ។ ដូច្នេះបានន័យថា មនុស្សទាំងអស់នេះមកពីពេទ្យអង្គការ។ ថ្ងៃចូលហើយនិងថ្ងៃសាកសួរ ដូច្នេះមនុស្សអស់-- ឯកសារនេះធ្វើនៅស-២១ មែន ក៏ប៉ុន្តែឯកសារនេះខ្ញុំពិតជាមិនដែលបានឃើញពីមុនមកទេ។ មាន *“ដេប៉ូ”* មានស្ពីៗអានេះ ខ្ញុំពិតជាមិនដែលបានឃើញមកទេ។ ដូច្នេះដល់ឃើញអាពីរ*កូឡោន*ពីរខាងចុងនេះ ជឿហើយថា ឯកសារនេះផលិតនៅស-២១។ មនុស្សអស់នេះមកពីពេទ្យអង្គការ មិនមែនមនុស្សរបស់-- បញ្ជីរបស់ស-២១ ទេ។ មិនមែនជាបញ្ជីរបស់បុគ្គលិក ស-២១ទេ។ នេះសូមបញ្ជាក់ថែមប៉ុណ្ណេះ ដើម្បីច្បាស់លាស់ក្រោយពីបានឃើញកូឡោនខាងចុងពីរនេះ។

[០៩:៣២:៥៤]

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីការសាកសួរចម្លើយកាលពីម្សិលមិញនេះ។ ថាតើការសួរចម្លើយនេះ ត្រូវបានគេកត់ត្រាជារបៀបបែបនេះ បានន័យថាកត់ត្រាជាកាលបរិច្ឆេទនៃការសាកសួរ ឬមួយក៏គេកត់ត្រាតែសម្រាប់អ្នកទោសមួយចំនួននោះទេ។

**ឆ៖** អរគុណ។ លោកចៅក្រម-- លោកព្រះរាជអាជ្ញាឃើញហើយ ពួកអស់នេះមកសុទ្ធតែ

ឆ្នាំ៧៨។ ដូច្នេះការសួរចម្លើយប្រញាប់ណាស់ ប្រហែលសួរច្បោលៗ ប្រញាប់យកចេញនោះទេ មិនមានសារៈសំខាន់សម្រាប់យកព័ត៌មាន។ ដូច្នេះមិនមានឯកសារសម្រាប់សួរចម្លើយវែងឆ្ងាយទេ បើតាមពិត។

[០៩:៣៤:០៩]

**ស៖** សូមអរគុណ។ ឥឡូវយើងសូមបញ្ចប់លិខិតនេះ ហើយយើងពិភាក្សាអំពីបញ្ហាមួយផ្សេងទៀត គឺបញ្ហានៃការផ្តល់ចម្លើយនៃការសារភាព។ កាលពីម្សិលមិញ គឺថាការផ្តល់ចម្លើយ-- ការឆ្លើយនៅមន្ទីរស-២១ ជាទូទៅធ្វើឡើងដោយការប្រើទារុណកម្ម។ តើលោកអាចពន្យល់ដោយសង្ខេប ដើម្បីឱ្យយើងយល់ច្បាស់ ថាតើពាក្យ “ផ្តល់ចម្លើយ” ហ្នឹងគឺពាក្យ “ឆ្លើយ” ហ្នឹង ថាតើមានន័យយ៉ាងដូចម្តេច? ថាតើពាក្យ “សារភាព” ហ្នឹងវាមានន័យយ៉ាងដូចម្តេចនៅក្នុងការឆ្លើយសារភាពនោះ?

[០៩:៣៥:០៧]

**ឆ៖** ពាក្យសារភាពនេះប្រើជារួមទេ សំដៅពាក្យថា “ឆ្លើយ” ទោះបីចម្លើយនេះបានមកពីការបង្ខំក៏ដោយ ប្រើជារួមទេ។ នេះទីមួយចំពោះពាក្យសារភាព។ ឯចំណែកទីពីរ តើទាំងអស់សុទ្ធតែទទួលទារុណកម្មរឿងអី? ខ្ញុំសូមឆ្លើយថា លើកលែងតែម្នាក់គត់ គឺ កុយ ធួន ដែលមេហាមផ្តាច់មិនឱ្យវ៉ៃ មិនឱ្យធ្វើទារុណកម្ម ហើយឱ្យនិយាយត្រឹមត្រូវគួរសម។ ខ្ញុំសួរដោយផ្ទាល់ មេចាត់តាំងឱ្យខ្ញុំសួរដោយផ្ទាល់ ដូច្នេះគ្មានអ្នកណាហ៊ានប៉ះទេ។

ដោយឡែក មានម្នាក់ទៀត យឹម សម្បត្តិ អ្នកបោកគ្រប់បែក។ មេហាមមិនឱ្យវ៉ៃមែន ប៉ុន្តែមិនឱ្យខ្ញុំសួរ មិនឱ្យ មិត្តប៉ុន សួរទេ គឺឱ្យអ្នកផ្សេងទៀតសួរ ខ្ញុំឱ្យ មិត្តហ៊ សួរ។ ដូច្នេះ សួរដំបូងដើម្បីឱ្យចេញចម្លើយថា គាត់បោកគ្រប់បែកមែន ឬមិនមែន។ ហ្នឹងអត់វ៉ៃមែន។ ក៏ប៉ុន្តែដល់ក្រោយមក វ៉ៃ មានវ៉ៃ។ សរុបមក រឿងល្អិតដែលខ្ញុំបានរាយទាំងពីរនេះ ជារឿងលើកលែង ក្រៅពីនោះមានវ៉ៃទាំងអស់។

[០៩:៣៦:៣២]

**ស៖** សូមអរគុណ។ ហើយពាក់ព័ន្ធទៅនឹងសេចក្តីសារភាព បានន័យថាឯកសារសារភាពហ្នឹងថាតើឯកសារភាពហ្នឹងត្រូវបានកត់ត្រាដែរឬទេ? ហើយថាតើឯកសារសារភាពហ្នឹង វាមានប៉ុន្មានទំព័រដែរ? តើវាមានតែពីរបីទំព័រ ឬក៏មានដល់ អាចថារាប់រយទំព័រ។ តើលោកអាចផ្តល់ជាគំនិតបានដែរឬទេ ថាតើឯកសារភាពហ្នឹងវាមានប្រហែលប៉ុន្មានទំព័រ ហើយតើការសួរចម្លើយហ្នឹង វាមានរយៈពេលប្រហែលប៉ុន្មានដែរ?

E1/54.1

**ឆ៖** បញ្ហាឯកសារជាចម្លើយសារភាព វាមានរឿងវិវឌ្ឍទៅតាមដំណើររឿង។ ដំបូងឡើយ នៅពេលដែលមុនខ្ញុំទៅដល់ ហើយនិងក្រោយខ្ញុំទៅដល់បន្តិចនេះ គេច្រើនតែចាប់មនុស្សម្នាក់ដែលជាអតីតមន្ត្រីរបស់ លន់ នល់ មក គេឲ្យធ្វើអង្គការលេខ។ អ្នកណាមេ អ្នកណាកូន។ គំរូបែបនេះ ខ្ញុំជឿថានៅសល់ នៅស-២១។ ដល់ក្រោយមក ខ្ញុំណែនាំឲ្យថតសំឡេងបញ្ជូនទៅខាងលើ។ ប៉ុន្តែ សុន សេន ណែនាំថាអត់ទេ កុំថត។ បងនួន គាត់ចូលចិត្តអានជាជាងស្ដាប់។ ខ្ញុំក៏ប្រែពីថតសំឡេងមកសរសេរ។ ក៏ប៉ុន្តែមានអ្នកខ្លះដែលមិនចេះសរសេរ យើងថតសំឡេង ហើយបុគ្គលិករបស់ស-២១ ហ្នឹងចម្លងពីខ្សែអាត់មកចូលក្រដាស។

សរុបមក អ្នកណាដែលចេះសរសេរ គឺយើងឲ្យគេសរសេរ។ ចម្លើយសារភាពមានរយៈខ្លី ឬវែងទៅតាមនុំង មិនច្បាស់ទេ។ ដោយឡែក កុយ ធួន ឆ្លើយបួនលើក។ មេឲ្យខ្ញុំសួរចម្លើយ កុយ ធួន មួយលើកហើយ មួយលើកទៀត។ បួនលើកទាំងអស់។ ហើយដល់ចុងបញ្ចប់ គាត់ថាចម្លើយដែលពិតមានតែយ៉ាងច្រើនត្រឹមលើកទីបីទេ។ ក្រៅពីនោះប្រឌិតហើយ។ អាហ្នឹងគាត់សរុបមកឲ្យវិញ។

ដូច្នេះ ចម្លើយកុយ ធួន មិនដឹងជាប៉ុន្មានរយទំព័រទេ ច្រើនណាស់។ ហើយចម្លើយអ្នកខ្លះតិចៗទេ។

[០៩:៣៨:៥៦]

**ស៖** ឲ្យខ្ញុំសុំបញ្ចប់ទៅលើប្រធានបទនេះ មុននឹងខ្ញុំបញ្ជូនឲ្យលោកមើលឯកសារថ្មីមួយ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមសួរលោកថាតើគោលបំណងនៃការទទួលបានចម្លើយសារភាពហ្នឹង តើមានគោលបំណងអ្វីដែរ? ហើយថាតើការទទួលបានចម្លើយសារភាពហ្នឹង ដោយការធ្វើទារុណកម្ម ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** គោលបំណងរបស់ ស-២១ ធ្វើម៉េចបានចម្លើយសារភាព ជូនអង្គការ ជូនខាងលើ ដើម្បីខាងលើត្រិះរិះពិចារណា វិភាគ និងសម្រេច។ នេះជាភារកិច្ចរបស់ស-២១។ បើកាលណាយើងបានចម្លើយហើយ ខាងលើថាឲ្យយកចេញ យើងយកចេញ មេ។ ដូច្នេះ ជាទូទៅទារុណកម្ម ដូចខ្ញុំជម្រាបហើយចៀសមិនរួច។ ក៏ប៉ុន្តែគោល-- យុទ្ធវិធីដែលស-២១ ប្រើមិនមែនជាទារុណកម្មជាមូលដ្ឋាន ចូលទៅដល់គិតពីវាយ ម៉ោកម៉ាកៗនោះទេ។ គេមានវិធីគេ។ ស្ងួត ក្ដៅ អង្កៀម ហ្នឹងអ៊ីចឹង។

[០៩:៤០:២៨]

**ស៖** តើៗខាងនុំងចង់ឲ្យអ្នកហ្នឹងគាត់ឆ្លើយសារភាពយ៉ាងដូចម្ដេចដែរ?

**ឆ៖** គោលបំណងចង់ឲ្យអ្នកទោសឆ្លើយសារភាពឲ្យបានមានលក្ខណៈជាប្រព័ន្ធ ឲ្យវាមានកិច្ចដំណើរការមួយវារលូនទៅជាប្រព័ន្ធ ឲ្យមានសមហេតុផលថា ខ្លួនបានប្រព្រឹត្តក្បត់ពីឆ្នាំនេះៗមកមែន។ ដូច្នេះហើយបានជាស-២១ ចូលចិត្តឲ្យនិយាយពីរឿងដើមមកជាហូរហែ សកម្មភាពក្បត់ពីដើមមក តាំងពីដើម ចាប់ផ្ដើមអើយមកហូរហែ។ ដូច្នេះទុកឲ្យខាងលើវិនិច្ឆ័យចុះ ពិតឬមិនពិតយ៉ាងម៉េចគឺស-២១ ធ្វើប៉ុណ្ណឹង។

[០៩:៤១:៣១]

**ស៖** ថាតើៗអ្នកទោសហ្នឹងតម្រូវឲ្យផ្ដល់ឈ្មោះអ្នកដែលគិតថាជាជនក្បត់ ឬមួយក៏យ៉ាងម៉េចដែរ ថាតើស-២១តម្រូវ ឬក៏ចង់ឲ្យអ្នកទោសហ្នឹងឆ្លើយអំពីឈ្មោះអ្នកដទៃទៀតថា ជាជនក្បត់ដែរឬមួយក៏យ៉ាងណា?

**ឆ៖** មនុស្សណាដែលជាប់នូវសកម្មភាពក្បត់ជាមួយនឹងគ្នា យើងរាយការណ៍ទៅខាងលើ។ ដូច្នេះខាងលើវិនិច្ឆ័យទៅ អ្នកណាល្មម ខាងសម្រេចយ៉ាងម៉េច អាហ្នឹងយើងគិតអ៊ីចឹង។ ដូច្នេះហើយបានជាស-២១ ឲ្យធ្វើប្រវត្តិសកម្មភាពក្បត់ជាហូរហែ អ្នកនេះបញ្ជាខ្ញុំអ៊ីចេះ អ្នកនោះបញ្ជាខ្ញុំអ៊ីចុះ អ៊ីៗ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងសូមបង្ហាញនូវឯកសារ D24/-- D43/4 ដូច្នេះខ្ញុំសូមផ្ដល់ទៅឯកសារនេះ ហើយយើងបង្ហាញនៅលើកញ្ចក់ទូរទស្សន៍។ លោក កាំង ហ្កេកអ៊ាវ សូមលោកពិនិត្យទៅលើឯកសារដែលលោកបានទទួលនេះ ហើយលោកពិនិត្យមើលថាតើលោកធ្លាប់ស្គាល់ឯកសារនេះឬមួយយ៉ាងម៉េចដែរ ហើយថាតើឯកសារនេះជាប្រភេទឯកសារម៉េចដែរ ដែលលោកធ្លាប់ស្គាល់នោះ? ហើយប្រសិនបើលោកអាចជម្រាបបាន គឺសូមជម្រាបទៅតុលាការថាតើឯកសារនេះជាឯកសារអ្វីដែរ?

[០៩:៤៣:២០]

**ឆ៖** ឯកសារនេះ ជាក្រុបនៃចម្លើយសារភាពរបស់មនុស្សម្នាក់ឈ្មោះ ទីវ ម៉ី ឈ្មោះដើម សន្តិភាព។ នៅពេលដែលគេសួរចប់ គឺគេសួរចប់នៅថ្ងៃ១៨ ខែ៩ ឆ្នាំ៧៧។ នេះអ្នកសួរ គេសួរចប់អ៊ីចឹង។ គេប្រគល់មកឲ្យខ្ញុំ។ ខ្ញុំអានហើយចប់ ខ្ញុំសរសេរសរុបទៅជូនខាងលើ៖ "បងជាទីគោរព ឯកសារនេះសុទ្ធតែជាមនុស្សសង្គមចាស់ទាំងអស់។ ដោយគោរព"។ ហើយខ្ញុំស៊ីញ៉េ។ ខ្ញុំស៊ីញ៉េនៅថ្ងៃ ១០ ខែ១១ ១៩៧៧។ ពាក្យប៉ុន្មានម៉ាត់នេះជាអក្សរខ្ញុំ។ ហើយខាងលើពីនោះ អក្សរបន្ថែមជាទឹកខ្មៅ "ខៀវ" គឺជាអក្សរ សុន សេន មេខ្ញុំ។ ខាងលើបំផុតគាត់ដាក់ថា "ប្អូន ទីវ អុល"។

[០៩:៤៤:៣៩]

**ស៖** សូមអរគុណ។ ឯកសារសរសេរដៃរបស់លោកគឺបាននិយាយទៅដល់ គឺមាននៅខាងក្រោម បានន័យថាប្រអប់ក្រហមខាងក្រោម ហើយចំណែកឯកសារសរសេរដៃនៅក្នុងប្រអប់ក្រហមខាងលើផ្នែកខាងឆ្វេងហ្នឹង គឺជារបស់អ្នកណាដែរ? តើឯកសារផ្នែកខាងលើខាងឆ្វេងដៃហ្នឹងជារបស់អ្នកណា?

[០៩:៤៥:០៧]

**ឆ៖** អរគុណ។ នៅប្រអប់ខាងលើ ខាងឆ្វេងដៃ ដែលសរសេរថាមិនទាន់អាន។ ជូនបង នួន មួយច្បាប់។ ១១-១១-៧៧ ជាអក្សររបស់ សុន សេន មេខ្ញុំ។

**ស៖** តើលោកយល់ស្របដែរឬទេ? ថាតើអក្សរនៅក្នុងប្រអប់ក្រហមហ្នឹង គឺអត់មាននៅក្នុងឯកសារដើមដែលយើងបានដាក់នៅក្នុងឯកសារពីមុនទេ បានន័យថាយើងដាក់ប្រអប់ក្រហមហ្នឹង ដើម្បីគ្រាន់តែឲ្យមានភាពងាយស្រួលក្នុងការពិនិត្យមើលទៅលើចំណារនោះ តើមែនដែរឬទេ? ហើយនៅពេលដែលនិយាយថាជូនបង នួន មួយច្បាប់ហ្នឹងតើបងនួន សំដៅទៅលើលោក នួន ជា មែនឬមិនមែន?

**ឆ៖** អរគុណ។ ពណ៌ក្រហមដែលហ៊ុមជុំវិញប្រអប់នេះជាពណ៌ថ្មីទេ ដែលទើបនឹងធ្វើឥឡូវដោយការិយាល័យសហព្រះរាជអាជ្ញា ដើម្បីឲ្យខ្ញុំពន្យល់។ អរគុណ។ ឯចំណែកពាក្យ បងនួន នេះគឺពិតជាសំដៅលោក នួន ជា ហើយ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ចប់ឯកសារនេះ។ កាលពីម្សិលមិញលោកបាននិយាយថា បន្ទាប់ពីផ្តល់ចម្លើយសារភាពហើយ-- ហើយខ្ញុំប្រហែលជាត្រូវបង្កើតសំណួរថ្មី គឺថានៅពេលដែលការសួរចម្លើយបញ្ចប់ បានន័យថានៅពេលដែលទទួលបានសេចក្តីសារភាពចប់ថា តើអ្នកជាប់ឃុំហ្នឹងត្រូវបានគេយកទៅក្រៅ ហើយសម្លាប់ចោល តើមែនឬទេ?

[០៩:៤៧:១២]

**ឆ៖** មែន! ប៉ុន្តែអ្នកខ្លះចាំបាច់ណាស់។ ខ្ញុំត្រូវការ-- ខាងលើឲ្យពន្យារទុកយូរបន្តិចដែរ។ ឧទាហរណ៍ កុយ ធួន មួយ ខ្ញុំទុកយូរក្រោយដែលសួរចម្លើយចប់។

**ស៖** តើអ្នកណាជាអ្នកបញ្ជាមកលោក?

**ឆ៖** អង្គាល់ដែល សុន សេន គាត់នៅ គាត់ជាអ្នកបញ្ជា។ ដល់ សុន សេន គាត់ទៅមុខបាត់ទៅ ទៅអ្នកលឿងបាត់ទៅ ទៅប្រចាំការនៅអ្នកលឿងបាត់ទៅចាប់ពីថ្ងៃ១៥ ខែសីហា ១៩៧៧ មក បងនួន ជាអ្នកបញ្ជា។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំបញ្ចប់ការផ្តល់ចម្លើយសារភាព។ ឥឡូវហ្នឹងខ្ញុំលើកយក ឯកសារ D1.3.5.1 ហើយខ្ញុំមានឯកសារដើម្បីប្រគល់ដល់សាក្សី ហើយខ្ញុំសូមស្នើឱ្យបង្ហាញនៅលើ កញ្ចក់ទូរទស្សន៍នៅក្នុងពេលជាមួយគ្នានេះ។

លោកសាក្សី តើលោកអាចពិនិត្យទៅលើឯកសារ ហើយថាតើលោកស្គាល់ឯកសារនេះដែរឬ មួយយ៉ាងណាដែរ? ហើយលោកអាចពន្យល់ដល់តុលាការបានដែរឬទេ? ថាតើឯកសារហ្នឹង គឺជា ឯកសារអ្វី?

[០៩:៤៩:១១]

**ឆ៖** ឯកសារនេះ ហៅថា "បញ្ជីកម្មេចរបស់មន្ទីរស-២១"។ លោកព្រះរាជអាជ្ញាមើលទៅ ឃើញហើយ ទាំងអស់សុទ្ធជាសមាសភាពទាហានរបស់ លន់ នល់។ មួយទៀត យើងមើលលេខនៅ ខាងលើថ្ងៃខែម្តងដាក់៧៥ ម្តងកែមក៧៦។ ដូច្នេះមនុស្សអស់នេះកម្មេច ក៏ប៉ុន្តែថ្ងៃខែហ្នឹងរេចុះរេឡើង ដូច្នេះរយៈកាលដំបូងថ្ងៃខែអត់ច្បាស់លាស់ទេ។ ជាភស្តុតាងមួយទៀតសម្រាប់បញ្ជាក់ថាថ្ងៃខែរយៈ កាលដំបូងមិនច្បាស់លាស់ទេ។ នេះសូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេថា ឯកសារនេះគឺមានឈ្មោះ អ្នកទោស ៤៧នាក់ គឺជាឈ្មោះអ្នកទោសដែលត្រូវកម្មេចនៅថ្ងៃ២៧ ខែបី ឆ្នាំ៧៥ ឬក៏ ៧៦ ហើយ លោកនិយាយថា វាមិនច្បាស់ទេចំពោះកាលបរិច្ឆេទហ្នឹងមិនដឹងច្បាស់ថា ថ្ងៃណា? ឆ្នាំណានោះទេ? តើ ឬមួយថា តើលោកអាចអានទៅលើថ្ងៃខែហ្នឹងជាភាសាខ្មែរបានដែរឬទេ?

[០៩:៥០:២៥]

**ឆ៖** ខ្ញុំអាចអានបាន។ ឈ្មោះអ្នកទោសដែលត្រូវកម្មេចហើយៗ នៅថ្ងៃ២២ ខែមីនា ១៩៧៥ ហើយដល់ក្រោយមកកែ៧៦។ ដូច្នេះថ្ងៃខែអត់ច្បាស់អីចឹង មីនា ៧៥ អត់ទាន់កកើតមន្ទីរនគរបាល ឬក៏ យើងមិនទាន់ឈ្នះ លន់ នល់ នៅឡើយទេ ទៅចាប់ទាហានគេយកមកកម្មេចម៉េច?

**ស៖** សូមអរគុណ។ ដូច្នេះ ដើម្បីការកត់ត្រា ខ្ញុំសូមឱ្យមានការបញ្ជាក់ចំនួន ព្រោះថាឯកសារ នេះវាមានលេខមួយទៀតដែលទាក់ទងទៅក្នុងសំណុំរឿងមួយដែរ គឺឯកសារលេខD3.1.2.46។ សូម អរគុណៗ លោកសាក្សី ឥឡូវនេះ ខ្ញុំចង់បង្ហាញនូវឯកសារចំនួនពីរប្រហាក់ប្រហែលគ្នានេះដែរ មុននឹង ពេលយើងបន្តទៅឯកសារផ្សេងទៀត។ ហើយឯកសារដែលខ្ញុំចង់បង្ហាញលោក គឺឯកសារ IS7.2 ដែលឯកសារ D312.1.55 ហើយខ្ញុំសូមបង្ហាញលោកនូវឯកសារនេះ ហើយយើងនឹងដាក់ឯកសារ

 

នេះនៅលើកញ្ចក់ទូរទស្សន៍។

[០៩:៥២:២២]

លោកសាក្សី សូមលោកពិនិត្យទៅលើឯកសារមួយនេះ ហើយថាតើលោកស្គាល់ឯកសារនេះដែរឬទេ? ហើយប្រសិនបើលោកស្គាល់ លោកអាចពន្យល់បានដែរឬទេ? ហើយក្នុងពេលជាមួយគ្នានេះ សូមលោកជួយអាននូវឈ្មោះចំណងជើងនៃឯកសារនេះផង?

**ឆ៖** អរគុណ។ ឯកសារនេះពិតជាឯកសាររបស់ស-២១។ ចំណងជើង "ឈ្មោះអ្នកទោសដែលងាប់នៅមន្ទីរស-២១(គ)" ហើយទាំងអស់មានចំនួន ១៦២នាក់។

**ស៖** តើលោកយល់ស្របដែរឬទេថា តើតួនាទី ឬក៏ភារកិច្ចរបស់មនុស្ស-- បុគ្គលទាំងអស់នេះគឺជាទាហាន? ហើយមានសិស្ស និស្សិតមួយចំនួនតូច?

**ឆ៖** អរគុណ។ ខ្ញុំយល់ស្របទាំងអស់សុទ្ធតែទាហាន ក្រៅពីនោះសិស្ស និស្សិតមួយចំនួនតូចសុទ្ធតែជាបងប្អូនរបស់ ឡុង បូរ៉េត។

**ស៖** ហើយឯកសារនេះបានបង្ហាញពីកាលបរិច្ឆេទនៃការកម្ទេចផងដែរ?

[០៩:៥៥:00]

**ឆ៖** ទេខ្ញុំមិនឃើញកាលបរិច្ឆេទ អ៎! "ថ្ងៃកម្ទេចរើយ ល្អ"។ ថ្ងៃអស់នេះខ្ញុំជឿថា ព្រះរាអាជ្ញាអាចនៅចាំ។ នៅពេលដែលស-២១ ណាត ត្រូវចេញពីស-២១ គាត់ចេញប្រហែលក្នុងខែ៣ គាត់មានសិទ្ធិ មេឲ្យបញ្ជាមកគាត់ចុះឡើងមកស-២១ ទាក់ទងដើម្បីបង្ហើយការងារចាស់។ ដូច្នេះ រយៈកាលហ្នឹងហើយដែលគាត់ឲ្យបញ្ចេញអ្នកទោសពីតាខ្មៅ ពីមន្ទីរពេទ្យព្រែកគ្នោតតាខ្មៅ ដែលគាត់យកធ្វើគុកនោះយកទៅកម្ទេច។ ដូច្នេះប្រាកដ។

**ស៖** សូមអរគុណ។ ហើយនេះជាឯកសារចុងក្រោយ នៅក្នុងប្រភេទនេះ ដែលខ្ញុំចង់បង្ហាញគឺឯកសារដែលមានលេខ IS16.4.6 និងឯកសារ D3.1.2.5.125។ ដូច្នេះ ខ្ញុំអាចផ្តល់ឯកសារនេះជូនទៅលោក គឺឯកសារដែលខ្ញុំបញ្ជូនទៅលោក ហើយនិងឯកសារដើម ខ្ញុំដាក់នៅលើអេក្រង់ទូរទស្សន៍។

លោកសាក្សី តើលោកអាចពិនិត្យមើលទៅលើឯកសារ ហើយថាតើលោកស្គាល់ឯកសារនេះដែរឬទេ? ហើយតើលោកអាចជួយពន្យល់ឯកសារនេះ ដោយអានឈ្មោះឯកសារនេះផងបានដែរឬទេ? ហើយប្រសិនបើអាចសូមលោកជួយពន្យល់ដោយសង្ខេប ថាតើឯកសារនេះវាមាននិយាយអំពីអ្វី?

[០៩:៥៦:៤៧]

**ឆ៖** ឯកសារនេះ ជាឯកសារស-២១ នៅក្នុងប្រអប់ខាងឆ្វេង ខាងលើប្រអប់តូច មន្ទីរស-២១ ភ្នំពេញ បញ្ជាក់បញ្ហានេះ។ ឯកសារនេះមានចំណងជើងថា “បញ្ជីរាយឈ្មោះអ្នកទោស ដែលបានផ្អាក ក្នុងខែ១ ១៩៧៧”។

**ស៖** ប្រសិនបើលោកមើលទៅបញ្ជីឈ្មោះទាំងអស់នេះ តើលោកយល់ស្របដែរឬទេ ដែលថា ភាគច្រើននៃបុគ្គលនៅក្នុងបញ្ជីនេះ គឺមានតួនាទីដែលថា អ្នកខ្លះមានតួនាទីនៅក្នុងផ្នែកយោធា ហើយអ្នកខ្លះជាសិស្សនិស្សិត និងអ្នកខ្លះជាបុគ្គលិកពេទ្យ ហើយមានតួនាទីយ៉ាងច្រើននៅក្នុងបញ្ជីនេះ យើងឃើញមានតួនាទីផ្សេងៗគ្នា តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ?

**ឆ៖** ខ្ញុំយល់ស្រប។

[០៩:៥៨:១០]

**ស៖** ឯកសារនេះ គឺហាក់ដូចជាខុសបន្តិច ហើយចំណងជើង ក៏វាដូចជាប្លែក។ តើលោកអាចអានចំណងជើងនៃឯកសារនេះបានទេ? ហើយជួយពន្យល់ផង ថាតើឯកសារហ្នឹងវាមានន័យយ៉ាងដូចម្តេចដែរ?

**ឆ៖** ចំណងជើងនេះ ប្លែកមែន អ្នកទោសដែលបានផ្អាកក្នុងខែ១ ឆ្នាំ១៩៧៧។ សូមបញ្ជាក់ថា ផ្អាកនេះ គឺសួរមិនទាន់ចប់ តែផ្អាកសួរ។ ម៉េចបានផ្អាក? ព្រឹត្តិការណ៍ជាក់ស្តែង គឺ--

**លោក វីណ្លៀម ស្មីត៖**

សូមទោសលោកប្រធាន គឺខ្ញុំអត់បានទទួលនូវការបកប្រែ តាំងពីផ្នែកប៉ុន្មាន ផ្នែកដំបូងមក។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយអ្នកបកប្រែ មានបញ្ហាបច្ចេកទេស រាយការណ៍ឲ្យខ្ញុំវិញ។

**លោក វីណ្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំគិតថាឥឡូវអ្វីៗដំណើរការល្អវិញហើយ។ សូមអរគុណ។

**សួរដោយលោក វីណ្លៀម ស្មីត៖**

**ស៖** លោកសាក្សី ដោយសារតែខ្ញុំមិនបានទទួលបានចម្លើយរបស់លោក ដោយសារតែមិនមានការបកប្រែមកជាភាសាអង់គ្លេស ប្រហែលជាមានបញ្ហាបកប្រែ។ ដូច្នេះ តើលោកអាចឆ្លើយសាជាថ្មីបានឬទេ ថាតើឯកសារហ្នឹងវាមានចំណងជើងថាយ៉ាងដូចម្តេចដែរ?

[១០:០០:០៣]

**ឆ៖** អរគុណ។ ឯកសារនេះមានចំណងជើងថា បញ្ជីរាយឈ្មោះអ្នកទោស ដែលបានផ្អាកក្នុងខែ០១ ឆ្នាំ១៩៧៧។ ផ្អាក មានន័យថាសួរអត់ទាន់ចប់ តែឈប់សួរ។ យកទៅណា? យកទៅកម្ទេច។ ម៉េចបានជាសួរមិនទាន់ចប់ហើយយកទៅកម្ទេច? បញ្ហានេះវាទាល់តែយើងក្ដាប់សភាពការណ៍នៅស-២១បាន។ នៅថ្ងៃ២៥ ខែធ្នូ ១៩៧៦ ខាងលើប្រគល់ កុយ ធួន មកឲ្យស-២១។ ថ្ងៃ២៩ ខែធ្នូ ១៩៧៦ កុយ ធួន ចាប់ផ្ដើមសារភាព។ ថ្ងៃ០១ ខែ០១ ១៩៧៧ ខាងលើសម្រេចសម្រិតសម្រាំងខ្សែ កុយ ធួន រាប់រយនាក់ចូលស-២១។ ដូច្នេះ អ្នកទោសប៉ុន្មាននៅសល់នោះ ខាងលើឲ្យបញ្ចេញ។ នេះហើយបានពាក្យផ្អាកនេះ។

**ស៖** សូមអរគុណសាក្សី ហើយលោកមើលទំព័រចុងក្រោយនៃឯកសារនេះ ហើយសូមអនុញ្ញាតតុលាការបង្ហាញនៅលើអេក្រង់ លើទំព័រចុងក្រោយ។ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៧៧ អ្នកណាជាអ្នករៀបចំឯកសារនេះ?

[១០:០១:៥០]

**ឆ៖** ឯកសារនេះជាស្ថិតិដែល មិត្តហ៊ី សរុប។ មិត្តហ៊ី ជាអ្នកសរុប។

**ស៖** សូមអរគុណ។ សូមអរគុណចំពោះការពន្យល់ទៅលើឯកសារមូលដ្ឋានមួយចំនួនដែលបានរៀបចំ ហើយបានរក្សាទុកនៅ ស-២១។ ឥឡូវនេះខ្ញុំសូមចូលទៅប្រភេទឯកសារមួយទៀត ដែលលោកអាចស្គាល់ដែរ។ ខ្ញុំសូមអនុញ្ញាតតុលាការបង្ហាញឯកសារនេះចំពោះមុខលោក IS11.14 ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧៨ មួយផ្នែកមួយនៃឯកសារនេះនឹងជូនទៅលោកសាក្សីដើម្បីពិនិត្យ ហើយមួយផ្នែកទៀត សូមបង្ហាញនៅលើអេក្រង់បាទ។

សាក្សី សូមលោកមើលឯកសារនេះ ហើយពិនិត្យមើលថាតើឯកសារនេះដែលលោកស្គាល់ដែរឬទេ? ហើយសូមលោកពន្យល់ដល់តុលាការថាតើវាជាអ្វី? ហើយគោលបំណងនៃឯកសារនេះ ដើម្បីអ្វី?

**ឆ៖** អរគុណ។ ឯកសារនេះមានចំណងជើងថា“ទង់បដិវត្ត”។ ទង់បដិវត្តគឺជាឈ្មោះទស្សនាវដ្ដីផ្ទៃក្នុងបក្ស ដែលលេខាសរសេរទៅសម្រាប់អប់រំបក្ខជនរបស់ខ្លួនរាល់ខែ។ ដោយឡែក ឯកសារដែលខ្ញុំកាន់ ដែលព្រះរាជអាជ្ញាប្រគល់មកនេះ លេខពិសេស ខែឧសភា មិថុនា ១៩៧៨ ដូច្នេះពីរខែនេះបញ្ចូលគ្នា។ ហ្នឹងខ្ញុំសូមអធិប្បាយប៉ុណ្ណឹង អំពីទស្សនាវដ្ដីទង់បដិវត្ត។

[១០:០៤:៣០]

**ស៖** ថាតើនេះជាសេចក្ដីចម្លងនៃឯកសារមួយ ដែលលោកបានយោងពីខាងដើម ដែលគេត្រូវបានប្រើជាផ្នែកការអប់រំ ហើយការបំពាក់បំប៉នបុគ្គលិកនៅស-២១ ដែរឬទេ?

**ឆ៖** ទង់បដិវត្តនេះជាឯកសារមួយ ដែលបក្ខជនគ្រប់រូបត្រូវតែរៀន។ បក្ខជនគ្រប់រូបត្រូវតែយកខ្លឹមសារក្នុងនេះទៅអប់រំជួររបស់ខ្លួន។

**ស៖** ហើយឯកសារនេះ តើមានខ្លឹមសារអ្វីខ្លះនៅក្នុងនោះ? បាទមិនមែនតែពិសេសតែមួយនេះទេ គឺដែលថាជាឯកសារទង់បដិវត្តនេះ តើខ្លឹមសារនៅក្នុងនោះជាអ្វី បាទជាទូទៅ?

**ឆ៖** អរគុណ។ ធម្មតាទេ ការអប់រំរបស់បក្ស សំខាន់លើបញ្ហាបី។ ទីមួយគោលនយោបាយរបស់បក្ស។ ទីពីរ ជំហរសតិអារម្មណ៍របស់បក្ស។ ទីបី គោលជំហរចាត់តាំងរបស់បក្ស ប្រចាំខែគឺសរសេរអប់រំ លេខាបក្សសរសេរអប់រំបក្សរបស់ខ្លួនត្រង់គោលការណ៍បីនេះឯង។

[១០:០៦:៣៣]

**ស៖** ហើយនៅមន្ទីរស-២១ លោកបានទទួលនូវឯកសារទង់បដិវត្តនេះ តើមែនឬទេ?

**ឆ៖** អរគុណ។ នៅស-២១ ខ្ញុំបានទទួលឯកសារទង់បដិវត្តនេះទៀងទាត់។

**ស៖** នៅពេលដែលគេបោះពុម្ពជាទង់បដិវត្តនេះ តើលោកទទួលតែមួយច្បាប់នៃឯកសារហ្នឹង ឬក៏មានជាច្រើនច្បាប់ជូនមកលោក សម្រាប់បុគ្គលិកផ្សេងទៀតនៅស-២១ ដែរនោះ?

**ឆ៖** អរគុណ។ ទង់បដិវត្តនេះ គេសម្រាប់តែចែកឲ្យបក្ខជន។ ដូច្នេះបក្ខជនមានប៉ុន្មាន គេឲ្យជិតគ្រប់ ឬក៏ពាក់កណ្ដាល។

**ស៖** ថាតើការបញ្ជូនច្បាប់នៃទង់បដិវត្តនេះដោយវិធីណា? ហើយនិងចែកបន្តទៅទៀតនៅស-២១ ដោយវិធីណា? ហើយ/ឬក៏ចែកបន្តទៅទៀតដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំបានជម្រាបហើយថា ស-២១ វាជាវរសេនាធំមួយរបស់កងទ័ពមជ្ឈិម។ ដូច្នេះអ្នកដែលប្រគល់ទង់បដិវត្តមកដល់ស-២១ គឺជំនួយការសេនាធិការជាអ្នកប្រគល់មក ដល់ដៃខ្ញុំ តាមរយៈនីរសារ តាមរយៈខ្សែនីរសារ រាល់ខែ។ ហើយមកដល់ស្រេចនឹងខ្ញុំចាត់ចែងហើយ ឲ្យ មិត្តហ៊ី គេចាត់ចែងទៅឲ្យទៅអ្នកណាខ្លះ ប៉ុន្មានអីប៉ុន្មានយើងចាត់ចែងទាំងអស់គ្នា។

[១០:០៨:៥៤]

**ស៖** ជាផ្នែកមួយនៃវគ្គសិក្សារបស់លោក ដែលលោកធ្វើឡើងនៅស-២១ ជាការបណ្ដុះបណ្ដាលនោះ។ តើលោកបានបង្រៀនពីខ្លឹមសារនៃឯកសារទាំងនោះដែរឬទេ? ជាពិសេសទៅដល់បុគ្គលិករបស់

លោក តើមែនឬមិនមែន?

**ឆ៖** មែនៗ។

**ស៖** សូមអរគុណ។ ប្រហែលជាយើងបន្តទៅឯកសារមួយទៀត ហើយខ្ញុំបង្ហាញជូនលោកនូវឯកសារ IS14.3 លើ គឺលើមួយ គឺថាខែកញ្ញា ឆ្នាំ១៩៧៧។

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំមានឯកសារលើក្រដាសនឹងជូនសាក្សីពិនិត្យ។ សូមអនុញ្ញាតតុលាការបង្ហាញឯកសារនេះនៅលើអេក្រង់ទូរទស្សន៍ផងដែរ។

[១០:១០:០៥]

សូមលោកសាក្សីប្រើពេលបន្តិច ដើម្បីពិនិត្យមើលឯកសារនេះដោយសង្ខេប គឺមានតែពីរបីទំព័រទេ ដែលយើងចម្លងយកចេញពីឯកសារទាំងស្រុង។ តើលោកស្គាល់ឬទេ ថាឯកសារហ្នឹងជាប្រភេទអ្វី ជាទម្រង់បែបបទយ៉ាងដូចម្តេច? ហើយជម្រាបតុលាការឲ្យជ្រាប ថាតើគោលបំណងនៃឯកសារនេះគេប្រើដើម្បីអ្វី? ហើយនិងប្រភេទព័ត៌មានដែលគេកត់ត្រានៅក្នុងឯកសារនេះផងបាទ?

**ឆ៖** អរគុណ។ ឯកសារនេះជាកំណត់ដៃរបស់កម្មាភិបាលម្នាក់នៅមន្ទីរស-២១ ឈ្មោះ ម៉ម ណៃ។ ឯកសារនេះក្រាស់។ ទៅរៀនវគ្គសិក្សាជាមួយនឹងមេ គឺជាមួយ សុន សេន ក៏ ម៉ម ណៃ គាត់សរសេរទាន់មួយចំនួនណាដាក់ក្នុងឯកសារនេះ។ គាត់រៀនវគ្គជាមួយនឹងខ្ញុំ ក៏ ម៉ម ណៃ គាត់សរសេរនៅក្នុងនេះ។ គាត់ធ្វើជីវទស្សន៍ប្រវត្តិរូប-- អ៊ំ! គាត់ធ្វើ គាត់ឆ្លងជីវទស្សន៍ប្រវត្តិរូបរបស់មនុស្សនៅក្នុងអង្គភាពក៏គាត់ចម្លងនៅក្នុងនេះ។ ស្អីទាំងប៉ុន្មានគាត់ចម្លងនៅក្នុងនេះទាំងអស់។ កាលដែល ណាត បញ្ជាគាត់ឲ្យធ្វើម៉េចខ្លះ គាត់មាននៅក្នុងនេះ។ ដូច្នេះ វាជាកំណត់ហេតុមួយដែលយើងអាចដឹងព័ត៌មានយ៉ាងជ្រាលជ្រៅច្បាស់លាស់ពី ស-២១។ ខ្ញុំរក្សាទុកឯកសារនេះតាំងពីដើមដល់ចប់។ សូមបញ្ចប់ប៉ុណ្ណឹង។

[១០:១១:៥៥]

**ស៖** ហើយលោកបាននិយាយថា កំណត់ហេតុនេះបានកត់ត្រាពីវគ្គសិក្សា។ ហើយឯកសារនេះចុះកាលបរិច្ឆេទឆ្នាំ១៩៧៧ ហើយក្នុងឆ្នាំនេះ ៧៧នេះ ថាតើវគ្គសិក្សាអ្វីដែល ម៉ម ណៃ បានចូលរួម ថាតើវគ្គដែលលោករៀបចំ ឬដោយថ្នាក់លើរបស់លោក ឬក៏ដោយអ្នកណាខ្លះបាទ?

**ឆ៖** អរគុណ។ វគ្គសិក្សាដែលខ្ញុំចូលរួម ហើយមេខ្មេសនាមមានតែខ្ញុំប៉ុន្មាននាក់ទេ។ គ្នាខ្ញុំពីរបីនាក់ ខ្ញុំ មិត្តហ៊ា មិត្តហ៊ុយ ឯចំណែកបង ម៉ម ណៃ បន្ទាប់មកខាងជំនួយការសេនាធិការ គេហៅយក

ទៅរៀន។ ដូច្នេះ គេអប់រំ។ ដូច្នេះ គាត់កត់បានវគ្គឯនុ៎ងទេ ដែលជំនួយការសេនាធិការ គេអប់រំ។

**ស៖** ថាតើជាលក្ខខណ្ឌតម្រូវដែលថាឱ្យសមាជិកត្រូវតែកត់ត្រា ពីវគ្គមួយៗដែលគេចូលរួម ឬគ្រាន់តែលោក ម៉ម ណៃ ហ្នឹង គាត់ធ្វើខ្លួនឯងសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់?

**ឆ៖** ធម្មតាសិក្ខាកាមមួយរូបៗមានសៀវភៅទៅសរសេរ បទឧទ្ទេសនាមរបស់កម្មាភិបាលដែលឧទ្ទេសនាម។ ខ្ញុំ ក៏ខ្ញុំកត់ ប៉ុន្តែខ្ញុំកត់មិនច្បាស់លាស់ឱ្យល្អិតដូចគាត់ទេ សមត្ថភាពខ្ញុំនៅចាញ់គាត់។ សូមបញ្ជាក់ថា ម៉ម ណៃ នេះជាសាស្ត្រាចារ្យបរិញ្ញាអក្សរសាស្ត្រខ្មែរ។ ដូច្នេះគាត់មានសមត្ថភាពកត់ត្រាបានលឿនជាងខ្ញុំ។ ដូច្នេះហើយបានឯកសារនេះវាមានសារៈសំខាន់សម្រាប់ខ្ញុំ ដើម្បីឆ្លុះបញ្ចាំងទៅអតីតកាល។

[១០:១៥:១៦]

**ស៖** ថាតើការងារចម្បងរបស់លោក ម៉ម ណៃ សំខាន់នៅស-២១ ហ្នឹង គឺការងារគាត់ធ្វើអ្វី?

**ឆ៖** និយាយមួយចប់ គាត់មានតួនាទីជាជំនួយការរបស់ខ្ញុំ។ កន្លែងណាដែលខ្ញុំត្រូវការគាត់ គាត់រត់ទៅភ្លាម ហើយរកអ្នកណាជំនួសគាត់មិនបាន មានតែគាត់ គឺខ្ញុំឱ្យគាត់ទៅ។ ទៅទាក់ទងសុំយុវជនមកពីខាងកំពង់ឆ្នាំង មកចូលស-២១ ក៏គាត់ទៅ។ ជូនខ្ញុំទៅវត្តឧណ្ណាលោម ទៅចង់បានព្រះបរមរូបសម្តេច ជួន ណាត ក៏គាត់ជូនខ្ញុំទៅ។ ទៅណាក៏គាត់ជូនខ្ញុំទៅដែរ ទៅពីរនាក់ ហើយការងារសួរចម្លើយអីបន្ទាន់ ខ្ញុំរុញឱ្យគាត់ចាត់ចែងជំនួសខ្ញុំ។ ដូច្នេះ និយាយមួយម៉ាត់គាត់ជាជំនួយការរបស់ខ្ញុំលើគ្រប់បញ្ហាណាដែលខ្ញុំត្រូវការគាត់។

**ស៖** ថាតើគាត់មានតួនាទីនៅក្នុងការសួរចម្លើយអ្នកទោសដែរឬទេ?

**ឆ៖** ពេលចាំបាច់ខ្ញុំប្រើគាត់ ជាពិសេសពីថ្ងៃ០៦ មករា ១៩៧៨ មក ខ្ញុំប្រើគាត់ឱ្យសួរចម្លើយយួនដើម្បីយកចម្លើយថតខ្សែអាត់ផ្សាយតាមវិទ្យុ គាត់រៀនចេះវៀតណាម ខ្ញុំចាត់តាំងមនុស្សម្នាក់ឱ្យទៅជួយគាត់ផង ហើយបង្រៀនគាត់ផងឈ្មោះ ផា ថាចាន់ ។

[១០:១៦:៣៣]

**ស៖** សូមអរគុណ។ លោកប្រធានខ្ញុំបានបញ្ចប់ឯកសារនេះហើយ។ លោកសាក្សីប្រហែលយើងអាចចូលទៅដល់ប្រធានបទមួយផ្សេងមួយទៀត។ លោកទើបតែបានពណ៌នាពីប្រភេទនៃឯកសារទាំងឡាយ ឬក៏ប្រភេទនៃព័ត៌មានដែលត្រូវបានកត់ត្រានៅស-២១។ ឥឡូវនេះ ខ្ញុំចង់ចូលទៅដល់សំណួរមួយចំនួនថា តើមធ្យោបាយផ្សេងទៀត ដែលគេប្រាស្រ័យទាក់ទងព័ត៌មានពីកន្លែងផ្សេងមកស-២១

ហើយនិងសំណួរមួយទៀត ថាតើលោកទំនាក់ទំនងព័ត៌មានទៅថ្នាក់លើ និងក្រៅស-២១ ហ្នឹងដោយវិធីណា? ជាពិសេសតាមវិធីដែលលោកទំនាក់ទំនងទៅអ្នកក្រោមបង្គាប់ ហើយនិងតាមវិធីដែលពួកគេទំនាក់ទំនងមកលោកវិញ។ ហើយលោកបាននិយាយថា នៅស-២១ មានវគ្គសិក្សា និងវគ្គបណ្តុះបណ្តាលមួយចំនួន ហើយក៏មានគំនិតដែលថា មានការ-- កិច្ចប្រជុំនៅគណៈកម្មការមន្ទីរស-២១ ដែរនៅក្នុងសម័យនោះ។ ថាតើអ្នកក្រោមបង្គាប់គេបញ្ជូនព័ត៌មានមកលោកហ្នឹងដោយវិធីណា? អំពីអ្វី? ពីសភាពការណ៍ការងារដែលបានអនុវត្តនោះដូចម្តេច? រាយការណ៍ដោយផ្ទាល់មាត់ ឬក៏ដោយលាយលក្ខណ៍អក្សរ រូបលោកពន្យល់អំពីវិធីថា តើព័ត៌មានទាំងអស់នោះនាំជូនមកដល់លោកដោយវិធីណាដើម្បីតុលាការបានជ្រាបផង?

[១០:១៨:១៨]

**ឆ៖** អំពីការងារបក្សនៅក្នុងមន្ទីរស-២១ សន្និបាតធ្វើបាន បើតាមខ្ញុំចាំ តែពីរដងគត់ នៅខែ១២ ឆ្នាំ១៩៧៦ អ៊ំ!៧៥ ម្តង ពេលនោះ ណាត ដឹកនាំធ្វើសន្និបាត។ សំណូមពរសំខាន់គឺដើម្បីឲ្យទាំងអស់គ្នាក្នុងបក្សទទួលថាយើងខំធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ នេះសំណូមពរសន្និបាតលើកនុ៎ង។ ដល់ក្រោយមករវាងថ្ងៃ២៧ ខែមេសា ឆ្នាំ១៩៧៧ មេអញ្ជើញចុះទៅដឹកនាំសន្និបាតនៅស-២១ ម្តងគឺសុន សេន គាត់អញ្ជើញទៅ។ សូមបញ្ជាក់ថា បានជាខ្ញុំចាំថ្ងៃខែច្បាស់ពីព្រោះថ្ងៃនោះប្រពន្ធខ្ញុំឆ្លងទន្លេបានកូនដំបូងរបស់ខ្ញុំ ដូច្នេះខ្ញុំចាំថ្ងៃខែហ្នឹងច្បាស់។ ដូច្នេះក្រៅពីនុ៎ងមកសន្និបាតដូចអត់មានបានធ្វើតទៅទៀតទេ ឯចំណែកការប្រជុំក្នុងគណៈរបស់ខ្ញុំជាប់។ ប៉ុន្តែគ្មានបានកត់ត្រាកំណត់ហេតុអីទេ គ្មានមនុស្សនៅក្នុងនុ៎ងសម្រាប់កត់ត្រាកំណត់ហេតុទេ។

**ស៖** សំណួរ នៅក្នុងមហាសន្និបាតនោះ គឺសម្រាប់បុគ្គលិកស-២១ ឬក៏សម្រាប់ក្រុមមហាជនផ្សេងទៀតដែលចូលរួមផងដែរ?

**ឆ៖** សម្រាប់តែបុគ្គលិកស-២១ ទេ ជាពិសេសបក្ខជន សុទ្ធតែបក្ខជនចូលរួម។

[១០:២០:០៤]

**ស៖** នៅក្នុងមហាសន្និបាតនោះ តើគេធ្វើឡើងនៅស-២១ ឬក៏នៅកន្លែងផ្សេង?

**ឆ៖** មហាសន្និបាតស-២១ ធ្វើនៅស-២១។ មេគាត់អញ្ជើញទៅដល់ទៅក្នុងនុ៎ង។ សុន សេន គាត់អញ្ជើញទៅដល់ក្នុងនុ៎ង។

**ស៖** អ៊ីចឹងខ្ញុំអាចនឹងចូលទៅដល់ប្រធានបទមួយទៀតដែលថា បុគ្គលិកម្នាក់ៗអាចប្រាស្រ័យ

ទាក់ទងជាមួយលោក ហើយខ្ញុំបង្ហាញឯកសារ D1.5/5.22។ ខ្ញុំមានឯកសារលើក្រដាសជូនលោកសាក្សីដើម្បីពិនិត្យ ហើយខ្ញុំសូមអនុញ្ញាតតុលាការបង្ហាញលើអេក្រង់ផងដែរ នូវឯកសារនេះ។

លោកសាក្សីទាក់ទងទៅនឹងឯកសារនេះ តើលោកបានឃើញទេថាតើលោកស្គាល់ឯកសារនេះឬទេ? ប្រសិនបើមែន សូមលោកអានអ្វីដែលសរសេរនៅលើប្រអប់ពណ៌ក្រហមនៅលើឯកសារនេះ។ នៅក្នុង 00 បាទ 055 នៅលើភាសាខ្មែរ ហើយសូមលោកពន្យល់ផងថា តើព័ត៌មានអ្វីដែលគេបញ្ជូនមកឬក៏បញ្ជូនទៅនោះ? បាទ បញ្ជូនមកលោក ឧទាហរណ៍។

[១០:២១:៤១]

**ឆ៖** ឯកសារដែលប្រគល់មកហើយខ្ញុំ ហើយឯកសារដែលបញ្ចាំងនៅលើអេក្រង់ខុសគ្នា។ តើលោកសួរណាមួយ?

**សៈ** បាទ គឺថាត្រូវហើយអ្វីដែលលោកមាននោះ គឺជាឯកសារត្រឹមត្រូវ គឺD159/5.22។ បាទ ឥឡូវនេះ យើងឃើញនៅលើអេក្រង់ហើយ សូមលោកពិនិត្យមើលឯកសារនេះ នៅក្នុងចំណារផ្ទាល់ដៃ សូមលោកអានជូនតុលាការផង ហើយពន្យល់ខ្លឹមសារផងថា តើព័ត៌មាននេះគេមានបំណងយកទៅប្រើដើម្បីអ្វី?

**ឆ៖** ឯកសារនេះ មិនដឹង ឬឯកសារស្រដៀងនេះមិនដឹង ត្រូវបានបង្ហាញជូននៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ក្រដាសដែលបិទពីលើនេះ ខ្ញុំជឿថាមិនមែនជារបស់ស-២១ ទេ។ ស-២១ អត់ប្រើលេខរ៉ូម៉ាំង ហើយអត់ប្រើឈ្មោះជាភាសាឡាតាំងទេ។ ចាប់បាត់៤៥ឆ្នាំ សរសេរដាក់ *“ការ៉ង់ សែងកង់”* ស-២១ មិនប្រើទេ។ ខ្ញុំបានសន្និដ្ឋានជូនសហចៅក្រមស៊ើបអង្កេតហើយ ការសរសេររបៀបនេះ គឺពិតជារបស់ អ៊ឹង ប៊ិច ប្រធានដំបូងរបស់សារមន្ទីរទួលស្លែង។ ដូច្នេះ ខ្ញុំមិនបដិសេធទេ ឯកសារនេះ វាជាឯកសារ ស-២១ ក៏ប៉ុន្តែស្លាកដែលបិទពីក្រៅពីលើនេះ ពិតជាមិនមែនជំនាន់ស-២១ ទេ គឺពិតជាជំនាន់ អ៊ឹង ប៊ិច។ ហ្នឹងខ្ញុំសូមសន្និដ្ឋានប៉ុណ្ណឹងឡើងវិញ។

[១០:២៣:៥២]

**សៈ** សូមអរគុណ។ ការពន្យល់នេះឲ្យយើងដឹងច្បាស់ ឥឡូវនេះយើងមើលឯកសារទីពីរ អ៎! ទំព័រទីពីរ នៃឯកសារនេះ តើលោកស្គាល់ទំព័រទីពីរនេះទេ? បាទ សូមលោកអានចំណងជើងផង ហើយនិងចំណារផ្ទាល់ដៃនោះផងបាទ?

**ឆ៖** អរគុណៗ។ ពង្រីកបានសមរម្យហើយ។ ចំណងជើងឯកសារនេះ សរសេរថា “ប្រវត្តិ

សកម្មភាពរបស់ ចាប មុិត ផ្ទាល់" គេសួរចប់នៅថ្ងៃ៣១ ខែ១ ១៩៧៨។ ខ្ញុំសរសេរទៅ មិត្តប៉ុន ជូន មិត្តប៉ុន។ សរុបដូចមុន គឺឲ្យ មិត្តប៉ុន គេសរុបដូចមុន។ ដកឈ្មោះ បងឈាន តំបន់៣២ បងម៉ុន, បងសូ ចេញផង។ ជាគោលការណ៍ដែលបងទីពីរណែនាំៗ កាលពីថ្ងៃ២៥ ខែ២ ៧៨ ថាដកឈ្មោះ បងសូ តំបន់ ២៣, បងម៉ុន ២០៣, សុខ តំបន់២១ និងឈាន តំបន់២២, តាត និងសុខ កងពល១៧០, តាល់ ២៩០ បើមាន។ វាយពុម្ពហើយគូសឲ្យផង ឈ្មោះណាដែលចាប់ហើយ ដោយភាតរភាពបដិវត្តន៍។ ខ្ញុំអត់បាន ចុះថ្ងៃខែទេ នេះគឺ អក្សរខ្ញុំសរសេរបញ្ជាទៅ មិត្តប៉ុន។

**ស៖** តាមចំណារផ្ទាល់ដៃនេះ តើលោកអាចមើលឃើញទេ ឬក៏យល់ទេថា អ្នកណាជាអ្នក ណែនាំរបស់លោកនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដែលថាឲ្យដកឈ្មោះមួយចំនួននេះតាមចំណារនេះ ថា អ្នកណាជាអ្នកផ្តល់ការណែនាំ ឬក៏ជាអ្នកបញ្ជាលោកឲ្យធ្វើបែបនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ មានការតវ៉ាពីមេធាវីការពារក្តី នួន ជា។ បាទ សូមអញ្ជើញមេធាវី!

[១០:២៦:៣៩]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំយល់ថា-- សូមអរភ័យទោសលោកតុលាការនេះ ជាសំណួរនាំមុខ។ ខ្ញុំមិនមានការណែនាំអ្វី ដល់សាក្សីនេះទេតាមដែលខ្ញុំពិនិត្យមើល!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគ្រាន់តែយោងទៅលើចំណារផ្ទាល់ដៃនោះទេ ដែលអានថា ជាគោលការណ៍បងទីពីរណែនាំនៅ ថ្ងៃទី២៥ ខែ២ ឆ្នាំ៧៨ ថាឲ្យដកឈ្មោះនេះ។ នៅក្នុងបកប្រែជាភាសាអង់គ្លេស អ្វីដែលខ្ញុំធ្វើនោះគ្រាន់តែ សួរសាក្សីថាតើៗ ព័ត៌មាននោះចេញមកពីណា? ហើយខ្ញុំគ្រាន់អាន-- គ្រាន់តែអានចំណារផ្ទាល់ដៃ ដែល មិនឃើញច្បាស់។ នេះហើយគឺថា ជាចំណារផ្ទាល់ដៃខ្លឹមសារនៅក្នុងហ្នឹងទេ ខ្ញុំមិនបង្កើតអ្វីជាការនាំមុខ នោះទេ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ហើយប្រសិនជាខ្ញុំសួរសំណួរនោះឡើងវិញ ហើយយើងសួរទៅតាមតែចំណារផ្ទាល់នោះ លោកសាក្សី។ តាមចំណារផ្ទាល់ដៃនេះ តើមានបង្ហាញទេនៅក្នុងខ្មែរនេះ អក្សរខ្មែរ? ថាតើការណែនាំ នោះមកពីណា? តែប៉ុណ្ណឹង លោកឆ្លើយ។

[១០:២៨:០៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសរសេរថា ជាគោលការណ៍ដែលបងទីពីរណែនាំ កាលពីថ្ងៃ២៥ ខែកុម្ភៈ ១៩៧៨។ ដូច្នេះគោលការណ៍នេះគឺ បងនួន ហៅឈ្មោះពេញរបស់គាត់ឈ្មោះ នួន ជា ជាអ្នកណែនាំ។

**ស៖** អ៊ីចឹង យើងឃើញច្បាស់ហើយថានូវចំណារផ្ទាល់ដៃភាសាខ្មែរហ្នឹង គឺដូចលោកថាហ្នឹង មែនឬទេ?

**ឆ៖** ខ្ញុំថានេះគឺ ខ្ញុំអះអាងតាមចំណារផ្ទាល់ដៃដែលខ្ញុំសរសេរកាលពីនោះ ពីពេលៗនោះ។

**លោក វីណ្ឌៀម ស្មីត៖**

បាទ លោក លោកស្រីចៅក្រម លោកប្រធាន ឥឡូវនេះម៉ោងដប់កន្លះហើយ ប្រសិនជាលោកប្រធានយល់ថាដល់ពេលសម្រាក ខ្ញុំនឹងគោរពទៅតាមនោះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។

សូមអញ្ជើញ លោកមេធាវីជាតិការពារក្តីឱ្យលោក អៀង សារី!

[១០:២៩:៣១]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! សូមអរគុណ លោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាពគឺបញ្ហាឈឺជើង ឈឺចង្កេះ និងឈឺខ្នង លោក អៀង សារី មិនអាចទ្រាំទ្រអង្គុយនៅទីនេះបានតទៅទៀត លោកស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ពេញមួយថ្ងៃនេះតែម្តង ប៉ុន្តែសូមចូលរួមសវនាការនេះដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាពិចារណា និងសម្រេចតាមសំណើ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់សូមលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំ

ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានដោយផ្ទាល់បាន។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន សុំលះបង់សិទ្ធិមិនចូលរួមក្នុងដំណើរការសវនាការដោយផ្ទាល់នៅក្នុងសវនាការនេះ ដោយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយ ស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ពេញមួយថ្ងៃនេះ។

[១០:៣០:៤៥]

ហើយក្រុមមេធាវីការពារក្ដី អៀង សារី ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងបន្ទប់សវនាការរបស់លោក អៀង សារី។ ហើយនិងបង្គាប់ឲ្យមន្ត្រីសោតទស្សន៍តភ្ជាប់នូវប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលដំណើរការសវនាការ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលមានរៀបចំនូវប្រព័ន្ធសោតទស្សន៍សម្រាប់គាត់ចុះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងអញ្ជើញលោក នួន ជា -- លោក អៀង សារី-- លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់ទីកន្លែងផ្ដល់សក្ខីកម្មឲ្យបានមុខអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្ត សូមផ្ដល់វេទិកាទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** អរុណសួស្តីជាថ្មីម្តងទៀតដល់លោកសាក្សី។ មុននឹងយើងផ្លាស់ទៅប្រធានបទថ្មី ខ្ញុំសូមបង្ហាញលោកនូវឯកសារចំនួនប្រាំបន្តទៀត។ គឺឯកសារនេះវានឹងជួយដល់យើងក្នុងការយល់អំពីការប្រាស្រ័យទាក់ទងព័ត៌មាននៅមន្ទីរស-២១។ មុននឹងពេលដែលយើងចាប់ផ្តើម ខ្ញុំចង់សួរលោកមួយ--សំណួរពីរបីបន្តទៀតទៅលើឯកសារ ដែលយើងបានពិភាក្សាមុនពេលដែលយើងឈប់សម្រាកនេះ។ ហើយនេះគឺ យើងនិយាយអំពីចម្លើយសារភាពរបស់ ចាប មុិត ខ្ញុំគិតថា វាមានបញ្ហាលំបាកជាមួយនឹងការបកប្រែ។ ដូច្នេះហើយចំណារផ្ទាល់ដៃនោះ ដែលលោកបានសរសេរដោយផ្ទាល់ គឺវាមានលក្ខណៈច្បាស់លាស់ ហើយនិងលម្អិតប្រសិនបើលោកបានអាន ហើយយើងកត់ចូលទៅក្នុងប្រតិចារឹក។ ដូច្នេះតើលោកអាចអានបាន ឬទេ ទៅលើចំណារផ្ទាល់ខ្លួនរបស់លោក ដើម្បីឲ្យយើងអាចកត់ត្រានៅក្នុងប្រតិចារឹកជាភាសាអង់គ្លេសផងដែរ។ សូមអញ្ជើញ!

[១០:៥៥:២១]

**ឆ៖** អរគុណ។ ខ្ញុំសូមអានជូនចំណាររបស់ខ្ញុំដូចតទៅ៖ “ជូនមិត្ត ប៉ុន ១) សរុបដូចមុនៗ។ ២) ដកឈ្មោះ បង ឈាន តំបន់២២ បង ម៉ុន, បង សូ ចេញផង។ ជាគោលការណ៍ ដែលបងទីពីរ ណែនាំកាលពីថ្ងៃ២៥ ខែ០២ ឆ្នាំ១៩៧៨ ថា ដកឈ្មោះ បង សូ តំបន់២៣, ម៉ុន សេនាធិការ២០៣, សុខ តំបន់២១, ឈាន តំបន់២២, តាត និង សុខ ១៧០, តាល់ ២៩០ បើមាន។ ៣) វាយពុម្ពហើយ គូសឲ្យផងឈ្មោះណាដែលចាប់ហើយ។ ភាតរភាពបដិវត្ត! ហត្ថលេខា ឌុច”។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេថាហេតុអ្វី បានជា នួន ជា បញ្ហា ឬក៏ផ្តល់យោបល់ឲ្យលោក ណែនាំឲ្យលោក ដកចេញនូវឈ្មោះទាំងអស់នេះ?

**ឆ៖** ក្នុងស-២១ ការប្រតិបត្តិក្នុងរឿងដកឈ្មោះចេញជាបណ្តោះអាសន្ននេះ មានជាហូរហែ។ ដូច្នេះ នៅពេលនេះ គឺដកឈ្មោះប៉ុន្មាននាក់នេះ ដើម្បីកុំឲ្យសាមីខ្លួនដឹងខ្លួនថា មានគេឆ្លើយដាក់ ព្រោះឯកសារនេះពិតជាត្រូវផ្ញើទៅខាងបូព៌ា។

**ស៖** ដូច្នេះ ថាតើដើម្បីការពារពួកគាត់មិនឲ្យគេឆ្លើយដាក់ ឬមួយក៏ដើម្បីទុករក្សានូវព័ត៌មានដើម្បីឲ្យពួកគាត់ភ្ញាក់ផ្អើលនៅពេលក្រោយទៅវិញ?

**ឆ៖** ជាគោលការណ៍កុំឲ្យដឹងខ្លួន។ មនុស្សដែលត្រូវគេឆ្លើយដាក់ តែកាលណាដឹងខ្លួន គេមានវិធានការជាសម្ងាត់ ដើម្បីរត់គេច ដើម្បីប្រឆាំងតបបែបណាមួយ។ ដូច្នេះ ធ្វើម៉េច កុំឲ្យម្ចាស់ខ្លួនដឹងខ្លួនថាមានគេឆ្លើយដាក់ ព្រោះឯកសារនេះផ្ញើទៅបូព៌ា។ ជាគោលការណ៍ គឺផ្ញើទៅបង ភឹម លេខាភូមិភាគបូព៌ា។

[១០:៥៨:៤៥]

**ស៖** ហើយតើលោកដឹងទេថា មានអ្វីកើតឡើងចំពោះបុគ្គលដែលគេដកឈ្មោះចេញពីបញ្ជីនេះ ថាតើចុងក្រោយពួកគាត់ហ្នឹងមានរឿងអ្វីកើតឡើង?

**ឆ៖** ថ្ងៃក្រោយពួកនេះ ត្រូវចាប់ជាហូរហែ អ្នកដែលចាប់ក្រោយគេ គឺក្នុងខែ០៦ ខែមិថុនា ១៩៧៨។ ជំនាន់ដែលសម្រេចចាប់ សោ ភឹម ដែរ។ ដូច្នេះ ពេលនោះ ម៉ុន ក៏មក ហើយ សួ ប្រហែលជាមកមុន ឈាន ក៏មក ហើយ តាត និង តាល់ កងពលនេះ មកមុនយូរហើយ។ ដូច្នេះសរុបមកទាំងអស់ហ្នឹងសុទ្ធតែត្រូវចាប់។ យ៉ាងហោចណាស់-- យ៉ាងយឺតណាស់ យ៉ាងយូរណាស់ គឺចាប់នៅក្នុងខែ០៦ ១៩៧៨។

**ស៖** ហើយបន្ទាប់ពីចាប់ពួកគាត់ តើគេយកគាត់ទៅកន្លែងណា? ហើយតើមានអ្វីកើតឡើងចំពោះពួកគាត់?

**ឆ៖** ពួកនេះចាប់ បញ្ជូនមកស-២១។ ម៉ុន ក៏បញ្ជូនមកស-២១, ឈាន ក៏បញ្ជូនមកស-២១។ សួរចម្លើយហើយកម្ទេច។ ប៉ុន្តែជួនពេលនោះ សារៈសំខាន់នៃចម្លើយមិនជាខ្លាំងប៉ុន្មានទេ។

**ស៖** ឯសំណួរចុងក្រោយរបស់ខ្ញុំគឺថា តើបុគ្គលទាំងអស់នេះ បានន័យថាបុគ្គលដែលដកឈ្មោះចេញហ្នឹង តើពួកគាត់មកពីតំបន់ណា? តើពួកគាត់មកពីភូមិភាគណា?

**ឆ៖** ទាំងអស់នេះមកពីភូមិភាគបូព៌ា។ ដោយឡែក មិត្តតាត មិត្តសុខ កងពល១៧០ ជាកងពលដើមកំណើតពីខាងបូព៌ាដែរ តែប្រគល់មកឲ្យកងទ័ពមជ្ឈិមហើយ។ មិត្តតាល់ ២៩០ ក៏ប្រគល់មកឲ្យកងទ័ពមជ្ឈិមដែរ។ លេខ១៧០ និងលេខ២៩០ ជាលេខកងពលរបស់កងទ័ពមជ្ឈិម។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបង្ហាញឯកសារមួយទៀត ដែលមានលេខ IS10.5 ខ្ញុំមានឯកសារជាភាសាខ្មែរជូនលោក ហើយយើងនឹងដាក់ឯកសារនេះនៅលើអេក្រង់ផងដែរ។ លោកសាក្សី តើលោកអាចពិនិត្យមើលទៅលើឯកសារនេះ ហើយតើលោកធ្លាប់ស្គាល់ឯកសារនេះដែរឬទេ? ហើយប្រសិនបើលោកធ្លាប់ស្គាល់ តើលោកអាចអានបានដែរឬទេ ទៅលើឃ្លាពីរដែលនៅក្នុងប្រអប់ពណ៌

ក្រហមនេះ តើលោកអាចអានឃ្លាចំនួនពីរនៅក្នុងប្រអប់ពណ៌ក្រហមនេះបានដែរឬទេ?

[១១:០២:២៦]

**ឆ៖** អរគុណ។ ខ្ញុំសូមអាន-- (សូមទោស) ឯកសារនេះពិតជាឯកសាររបស់ស-២១។ អក្សរដែលសរសេរនេះគឺអក្សរ មិត្តប៊ុន អ្នកសួររបស់ខ្ញុំ។ នេះខ្ញុំសូមអានដូចតទៅ៖

“បងឌុច វិធានការសួរចម្លើយលេខប្រាំបួន ដែលធ្វើឲ្យសាមីខ្លួនសារភាពនៅថ្ងៃ២៦ ខែ០៩ ៧៦ ល្ងាច។ ១) ពេលព្រឹក បងឌុច ចូលគក់ច្របាច់បបោសអង្អែល។ យើងខ្ញុំណែនាំពីបង ឌុច សួរសាកថ្នាំដែលប្រើសម្រាប់ផ្ទាល់ខ្លួន រំឭកអំពីសុខទុក្ខប្រពន្ធកូន។ ឃាត់ខ្លួន ប្រពន្ធកូនដឹងទេ? ពេលមកនេះប្រពន្ធដឹងថាទៅណាដែរ? យើងខ្ញុំសួរ មុនចាប់ខ្លួនមកនេះ--

**ស៖** សូមទោសលោកសាក្សី ខ្ញុំស្នើថាលោកកុំអានបន្តទៅទៀតអី គឺថា តើគោលដៅនៃឯកសារនេះ តើលោកអាចពន្យល់បានដែរឬទេ ថាតើព័ត៌មានហ្នឹងគេរាយការណ៍ដោយរបៀបណា? បានន័យថារាយការណ៍ពីអ្នកនៅក្រោមបង្គាប់របស់លោក។ ដូច្នេះ ប្រហែលជាលោកចៅក្រម លោក លោកស្រីចៅក្រមអាចឃើញឯកសារនេះ ហើយខ្ញុំនឹងអានឯកសារនេះ។ ប៉ុន្តែតើលោកអាចមើលទៅលើប្រអប់ក្រហមទីពីរ ដើម្បីឲ្យលោកអាចជួយពន្យល់យើងបានដែរឬទេ ទៅលើប្រអប់ទីពីរ ប្រអប់ក្រហមទីពីរនេះ?

[១១:០៤:១៨]

**ឆ៖** អរគុណ។ “៤) ល្ងាច យើងខ្ញុំស្នើបង ឌុច សូមធ្វើវិធានការក្ដៅផង ត្រជាក់ផង។ ក្រោយទទួលការអនុញ្ញាត ដល់ក្បាលល្ងាចយើងខ្ញុំចូលទៅកំភ្លើង ឲ្យត្រៀមខ្លួន ម៉ោងប្រាំបី ឬម៉ោងប្រាំបួនផ្ដើមធ្វើទារុណកម្មបន្តទៀត”។ នេះក្នុងប្រអប់ទីពីរនេះ គឺមានខ្លឹមសារប៉ុណ្ណេះ។ ដោយឡែកសូមពន្យល់អំពីវត្ថុបំណងនៃឯកសារនេះ។

**ស៖** សូមអរគុណ។ ដូច្នេះទៅលើចំណុចនេះ ថាតើលោកអាចប្រាប់យើងបានទេ ថាតើការបញ្ជូនព័ត៌មានហ្នឹងធ្វើឡើងដោយរបៀបណា? តើ ប៊ុន ស្នើសុំបែបណាចំពោះលោក ដើម្បីឲ្យលោកអនុវត្តនូវវិធីសាស្ត្រនេះ? ថាតើគេធ្វើឡើងដោយផ្ទាល់មាត់ ឬមួយក៏ដោយជាលាយលក្ខណ៍អក្សរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះ គឺជាយុទ្ធវិធីនៃការសួរចម្លើយ ដែលខ្ញុំហើយនិង ប៊ុន ធ្លាប់ធ្វើចំពោះបុគ្គលសំខាន់ៗ។ ជាទូទៅ យើងខ្ញុំនិយាយគ្នាតែមាត់ទេ ប៉ុន្តែពេលនេះ មិត្តប៊ុន គាត់សរសេរដើម្បីយកអាអត្ថបទនេះទៅឲ្យ យ៉ា គាត់មើល ដើម្បីថាខ្ញុំអនុញ្ញាតឲ្យគាត់វាយ យ៉ា ហើយ ប្រយ័ត្នខ្លួន។

ហ្នឹងតែប៉ុណ្ណឹងឯងទេ សំណូមពរដើម្បីបំភ័យ យ៉ា ប៉ុនន៉ុង។

[១១:០៦:១២]

**ស៖** សូមអរគុណ។ ឥឡូវនេះយើងបន្តទៅឯកសារថ្មីមួយទៀត គឺឯកសារ D366/7.1.481។ ដូច្នេះ ខ្ញុំប្រគល់ឯកសារហ្នឹងជូនលោក ហើយយើងដាក់នៅលើកញ្ចក់ទូរទស្សន៍ផងដែរ។ សូមលោកពិនិត្យទៅមើលឯកសារនេះ។ ថាតើលោកស្គាល់ឯកសារនេះដែរឬទេ? ហើយថាតើអាចលោក-- តើលោកអាចអានបានដែរឬទេ ទៅលើប្រអប់ក្រហមពីខាងដើមហ្នឹង? បានន័យថា ឃ្លានៅក្នុងប្រអប់ពីរខាងដើមនេះ ដើម្បីឱ្យយើងយល់អំពីដំណើរការនៅក្នុងឯកសារមួយនេះ។ សូមអរគុណ។

**ឆ៖** អរគុណ។ ឯកសារនេះជាឯកសាររបស់ ស-២១។ នៅតែក្នុងយុទ្ធវិធីសួរចម្លើយ យ៉ាដដែល។ ម្ដងនេះខ្ញុំសរសេរទៅឱ្យ មិត្តប៉ុន ដើម្បីឱ្យ មិត្តប៉ុន យកសំបុត្រនេះទៅបង្ហាញ យ៉ា។ ដូច្នេះខ្ញុំសូមអានខ្លឹមសារនៅក្នុងប្រអប់ទីមួយ។

[១១:០៧:៤០]

"១) ខ្ញុំបានរាយការណ៍ជូនអង្គការនៅម៉ោងប្រាំបួនខ្វះដប់នាទីព្រឹកមិញនេះ អំពីករណីអាល្បូង យ៉ា។ តាមដែលឯកសារសមមិត្តផ្ដល់មក និងតាមសេចក្ដីរាយការណ៍របស់សមមិត្តអំពីសតិអារម្មណ៍វា។ ២) អង្គការសម្រេចថា អាម្បៀ យ៉ា នេះ បើវានៅតែត្រេងត្រាង លាក់ខ្សែក្បត់ និងសកម្មភាពក្បត់វាតទៅទៀតទេ អង្គការសម្រេចឱ្យវាយចោលទៅ។ កុំឱ្យវាលេងល្បែងជាមួយយើងតទៅទៀត ម្ដងនិយាយបង្អើបមួយម៉ាត់ ម្ដងបដិសេធមួយសៀវភៅ។ នេះអង្គការថាជាបាតុភាពមើលងាយបក្ស មិនមែនមើលងាយត្រឹមតែគណៈសន្តិបាលរបស់យើងទេ"។ ប្រអប់ខាងក្រោម "ដោយភារតភាពបដិវត្តន៍កក់ក្ដៅ ឌុច។ ១ ខែតុលា ១៩៧៦"។

[១១:០៨:៥០]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមសួរលោកទៅលើឯក-- សូមសួរសំណួរលោកទាក់ទងទៅនឹងឯកសារនេះ។ គឺឯកសារនេះចុះនៅថ្ងៃទី១ ខែតុលា ឆ្នាំ៧៦ ហើយលោកបាននិយាយនៅក្នុងឯកសារនេះនៅម៉ោងប្រាំបួនខ្វះដប់នាទី លោកបានរាយការណ៍ជូនអង្គការ។ តើ "អង្គការ" ហ្នឹងសំដៅទៅលើអ្នកណាដែរ? ហើយតើលោករាយការណ៍ទៅជូនអ្នកណាដែរ?

**ឆ៖** អង្គការនេះគឺសំដៅ សុន សេន។ ពេលនោះខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ខែ១០ ៧៦។

**សៈ** សូមអរគុណ។ ប្រហែលជាលោកចាំមិនឲ្យអស់នោះទេ ប៉ុន្តែជាទូទៅនៅពេលដែលលោករាយការណ៍ទៅ សុន សេន ថាតើរាយការណ៍ដោយផ្ទាល់ ឬមួយក៏រាយការណ៍តាមទូរស័ព្ទ?

**ឆៈ** អរគុណ។ អត្ថបទនេះប្រឌិតឡើងទេ ជាយុទ្ធវិធីប្រឌិតនៅស-២១ រវាងខ្ញុំ និង មិត្តប៉ុនដើម្បីសួរចម្លើយ យ៉ា គ្មានបានរាយការណ៍ស្អីនៅឡើយទេ។ យើងខ្ញុំ-- ខ្ញុំអាចរាយការណ៍តាមទូរស័ព្ទរបៀបដំណើរការអីខ្លះជូនគាត់បាន មានមែន ក៏ប៉ុន្តែឯកសារនេះអត់ចេញទៅដល់គាត់ទេ។

**សៈ** ដូច្នេះ នៅក្នុងករណីជាក់លាក់មួយនេះ គឺលោកនិយាយថា មិនមានការប្រាស្រ័យទាក់ទងជាមួយអង្គការទេ គឺលោកគ្រាន់តែប្រឌិតឡើងសម្រាប់ករណីមួយជាក់ស្តែងនេះ តើមែនឬទេ?

**ឆៈ** ច្បាស់លាស់ គឺអ៊ីចឹង។

[១១:១១:០១]

**សៈ** ហេតុអ្វីក៏លោកធ្វើដូច្នេះនៅក្នុងករណីមួយនេះ?

**ឆៈ** ម៉ែន សាន ហៅ យ៉ា មិនងាយសារភាពទេ។ ដូច្នេះ យើងចៀសទារុណកម្មឲ្យបានជាអតិបរមា។ ដូច្នេះ ត្រូវតែប្រឌិតវិធី ជាយ៉ាងនេះ យ៉ាងនោះ ដើម្បីចៀសទារុណកម្ម។

**សៈ** ដូច្នេះ តើជាញឹកញាប់ លោក-- តើលោកទំនាក់ទំនងជាមួយ សុន សេន ញឹកញាប់របៀបណា? បានន័យថាជាមួយនឹងមេកោយរបស់មន្ទីរស-២១ហ្នឹង តើញឹកញាប់របៀបណា?

**ឆៈ** អរគុណ។ ខ្ញុំសូមជ្រាបហើយ ខ្ញុំបានជម្រាបជាហូរហែមកហើយ។ នៅពេលដែលខ្ញុំធ្វើជាអនុប្រធាន ខ្ញុំសង្កេតឃើញថានៅស-២១ ខ្ញុំជាអនុប្រធានតែម្នាក់គត់ ដែលមេហៅទៅធ្វើការជាប់ជាមួយប្រធាន។ មានប្រធាន គឺមានអនុប្រធានទៅជាមួយគ្នា។ ដល់មេចេញទៅ មេមិនដែលហៅខ្ញុំ ហើយនិង មិត្តហ៊ ទៅទេ។ គាត់ហៅតែខ្ញុំទៅធ្វើការ។ ដូច្នេះ ជាចង្វាក់បីថ្ងៃគាត់ហៅខ្ញុំទៅជួបម្តង ឬក៏ប្រាំថ្ងៃយ៉ាងយូរ មិនដែលដប់ទេ។ ជាពិសេសរាល់ល្ងាច មេខ្ញុំតែងតែទូរស័ព្ទមកតាមដានខ្ញុំគ្រប់ការងារ មនុស្សណាដែលគាត់ចាប់អារម្មណ៍ គាត់ណែនាំបន្ថែមអ៊ីចេះ យ៉ាងនេះ យ៉ាងនោះ។ ហើយយុទ្ធវិធីអាន យុទ្ធវិធីសរសេរច្បាស់លាស់ គាត់ណែនាំជាប់រហូត។ នេះជាបញ្ហាដែលគាត់ណែនាំ។

[១១:១៣:២៩]

**សៈ** ហើយពាក់ព័ន្ធទៅនឹងបុគ្គលជាក់លាក់មួយនេះ គឺ យ៉ា មួយនេះ ថាតើលោកមានការពិភាក្សាជាមួយគាត់ដែរឬទេ? បានន័យថាតើពិភាក្សាជាមួយគេអំពីឈ្មោះ យ៉ា ដែរឬទេ? ថាតើលោកមានពន្យល់ទៅគាត់ ថាតើ យ៉ា ហ្នឹងគឺជាមនុស្សបែបណា ឬក៏បែបណានោះទេ?

**ឆ៖** នៅពេលដែលមុននឹងចាប់ យ៉ា ក៏មានគាត់ឲ្យដឹងខ្លះ។ នៅពេលដែលខាងលើសម្រេចចាប់ យ៉ា ហើយ តែមិនទាន់បានចាប់ប្រគល់មកឲ្យខ្ញុំ មិនទាន់ប្រគល់ យ៉ា មកឲ្យខ្ញុំ គាត់មានណែនាំខ្លះអំពីករណី យ៉ា។ ហើយសូមបញ្ជាក់មួយម៉ាត់ទៅទៀតចុះ គាត់ច្រើនហៅខាងក្រៅថា យ៉ា ឡុង។ គាត់ច្រើនហៅ បងយ៉ា នេះពីខាងក្រៅ ពីក្រោយខ្នងហៅថា យ៉ា ឡុង។ ដូច្នេះ គាត់មានបញ្ជាក់ខ្ញុំហួរហែ។ ដល់ពេល យ៉ា មកដល់ គាត់តាមដានជាប់ ឆ្លើយហើយនៅ? ធ្វើទារុណកម្មហើយនៅ? កុំអាលធ្វើទារុណកម្មអាហ្នឹងគាត់ណែនាំជាប់រាល់ល្ងាចរបស់គាត់។ យ៉ា លំបាកមិនងាយឆ្លើយទេ ប្រៀបធៀបនឹង កុយ ធួន យ៉ា តឹងណាស់។

**ស៖** តើលោកជួប សុន សេន នៅកន្លែងណា? ព្រោះថា លោកនិយាយថា លោកជួប សេន សុន ជារាល់បីថ្ងៃម្តង ជួបដោយផ្ទាល់។ តើលោកជួបនៅទីណាដែរ?

**ឆ៖** សុន សេន ជួបខ្ញុំម្តង តែម្តងគត់ នៅស្ថានីយ៍រាជអយស្ម័យយាន្ត គឺនៅពេលឧទ្ទេសនាមនៃការកកើតស-២១។ ក្រៅពីនោះ គាត់ជួបនៅខាងជើងបូរីកីឡា។ នៅប្លង់ដែលខ្ញុំបានរាយការណ៍ជូនសហព្រះរាជអាជ្ញាហើយ ខ្ញុំដាក់អក្សរ “B” នៅនុ៎ង។ ត្រង់ម្តុំវីឡា ឆន សុខុម។ ខ្ញុំជួបនៅកន្លែងហ្នឹងរហូត។ ហើយម្តងគត់ទៀត ខ្ញុំជួបលើកំពូល-- អ៊ំ ន៎ែ លើកដំបូលនេះ ជាន់ទីបួន ជាន់ទីប៉ុន្មានទេ នៅស្តាតអូឡាំពិក។ សរុបមក ខ្ញុំជួប សុន សេន សឹងតែនិយាយបានថាទាំងអស់ នៅចំណុច “B” ដែលខ្ញុំរាយការណ៍នៅក្នុងប្លង់ខ្ញុំជូនការិយាល័យសហព្រះរាជអាជ្ញារួចហើយ។

**ស៖** អ៊ីចឹង ទីតាំងដែលមាន-- ដែលៗដាក់ឈ្មោះថា “B” ថាតើវាជាការិយាល័យ? ជានាយកដ្ឋាន? តើការិយាល័យអីដែរនៅទីនោះ? តើតួនាទី-- តើអគារនុ៎ង មានតួនាទីអ្វីដែរ ឬក៏មានមុខងារអ្វីដែរនៅអគារនោះ?

**ឆ៖** ខ្ញុំមិនអាចនិយាយថាយ៉ាងម៉េចទេ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសូមរៀបរាប់អំពីទិដ្ឋភាពខ្លះ។ ជំនួយការរបស់គាត់ទាំងប៉ុន្មាននៅទីនោះ។ ណាត ក៏នៅទីនោះ។ សោម ក៏នៅទីនោះ។ ហើយនីរសារសំខាន់ៗក៏នៅទីនោះ ហើយទូរស័ព្ទអីៗនៅទីនោះ។ ហើយកន្លែងនុ៎ងមាននីរសារម្នាក់ ដែលទទួលខុសត្រូវសំខាន់ដែរ ឈ្មោះ មិត្តថា។ នីរសារនៅផ្លូវរទេះភ្លើង នៅរ៉ារទេះភ្លើង ជានីរសារខាងក្រៅទេ សម្រាប់ទទួលភ្ញៀវ។ មានការអី យកសំបុត្រមកឲ្យអាផ្លូវរទេះភ្លើង។ អាផ្លូវរទេះភ្លើងរត់ទៅអាកន្លែងអក្សរ “B” ហ្នឹង ហើយអក្សរ“B” រត់ទៅណាទៀត មិនដឹងទេ។ មិនដឹងជាគាត់ដេកនៅត្រង់ណា? ហូបចុកនៅត្រង់ណា? ស្អីត្រង់ណាច្បាស់លាស់ទេ? ខ្ញុំមិនដឹងទេ។

ដូច្នេះ យើងអាចកន្លែងឃើញ-- សូមបញ្ជាក់ទៀតថា នៅពេលកន្លែងនុ៎ង ជួនអី ខ្ញុំចូលទៅ ឃើញ មិត្តម៉េត ចេញមក ស៊ូ ម៉េត ចេញមក។ ជួនអី ខ្ញុំចូលទៅ ឃើញ សាន ចេញមក។ នេះកន្លែង ហ្នឹង ជាកន្លែងជួបជុំកងពល គាត់ហៅយកមកធ្វើការហ្នឹងដែរ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។

**ស៖** សូមអរគុណ។ នៅពេលលោកជួប សុន សេន តើលោកជួបគ្នាជាក្រុមច្រើននាក់ ឬមួយ ជួបគ្នាតែពីរនាក់ទេ?

**ឆ៖** ភាគច្រើន គឺច្រើនតែពីរនាក់។ គាត់ ហើយនិងខ្ញុំ ប៉ុន្តែពេលខ្លះមាន ទុំ ចូលជាមួយ។ ៨១ ចូលជាមួយ។ អនុប្រធានរបស់គាត់ អនុលេខាសេនាធិការចូលជាមួយ ដូចតែម្តងពីរដងប៉ុននុ៎ងទេ។

[១១:១៩:០៣]

**ស៖** តើកិច្ចប្រជុំហ្នឹង ជាមធ្យមវាមានរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** មិនតិចជាងដប់នាទីទេ ហើយក៏មិនលើសពីកន្លះម៉ោងដែរ។

**ស៖** នៅក្នុងការពិភាក្សារបស់លោកជាមួយនឹង សុន សេន តើជាទូទៅ លោកពិភាក្សាអំពីអ្វី ដែរ? តើលោកពិភាក្សាអំពីអ្នកជាប់ឃុំនៅមន្ទីរស-២១ ឬមួយក៏មានបញ្ហាផ្សេងៗទៀត ដែលលោក ត្រូវពិភាក្សា?

**ឆ៖** អរគុណ។ ចូលទៅដល់អង្គុយតុជាមួយគ្នា របៀបវារៈ គាត់អ្នកកំណត់។ ក៏ប៉ុន្តែខ្ញុំអាច សរុបបានជារួមថា សភាពការណ៍ដែលសំខាន់ គឺរឿងចម្លើយសារភាពរបស់បុគ្គលមួយចំនួន ដែលគាត់ ចាប់អារម្មណ៍។ គាត់ឲ្យរាយការណ៍សរុប ហើយណែនាំផ្ទាល់។ បន្ទាប់មកបានសភាពការណ៍រួមនៅក្នុង មន្ទីរ។ ហើយបន្ទាប់មកទៀតបញ្ហាផ្សេងៗ ដូច្នេះរបៀបវារៈនៅលើគាត់ទេ។ ប៉ុន្តែយើងអាចសរុបបាន អ៊ីចឹង។

**ស៖** សូមអរគុណ។ នៅពេលដែល បានន័យថា សុន សេន ក្លាយមេរបស់លោកនៅក្នុងខែ៨ ឆ្នាំ៧៧ តើមានរយៈយូរប៉ុន្មានដែរដែលគាត់ក្លាយជាមេរបស់លោក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! ដោយមានការតវ៉ាពីមេធាវីការពារក្តី។ សូមអញ្ជើញលោក!

[១១:២១:១១]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ព្រះរាជអាជ្ញាបាននិយាយថា គាត់បាននិយាយថា គឺខែ៨ ឆ្នាំ៧៧

ហើយខ្ញុំបានសរសេរថា សាក្សីនេះនៅថ្ងៃ២០ ខែមីនា បាននិយាយថារហូតដល់ថ្ងៃ១៥ ខែមេសា ឆ្នាំ៧៨ គាត់បានរាយការណ៍ទៅ សុន សេន។

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំគិតថា វាជាត្រឹមត្រូវ ព្រោះថាសាក្សីហាក់ដូចជាផ្តល់នូវកាលបរិច្ឆេទពីរដែលផ្ទុយគ្នា ដូច្នេះខ្ញុំចង់ឲ្យគាត់បញ្ជាក់ទៅលើកាលបរិច្ឆេទនេះឲ្យបានច្បាស់លាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសាក្សីឆ្លើយនឹងសំណួរ!

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** តើដើម្បីនិយាយឲ្យច្បាស់ខ្ញុំសូមសួរ ថាតើនៅពេលណាដែល នួន ជា ក្លាយទៅជាបុគ្គលដែលលោកត្រូវរាយការណ៍ដោយផ្ទាល់នូវមន្ទីរស-២១។ បានន័យថា នៅពេល-- នៅកាលបរិច្ឆេទពេលណាដែលលោករាយការណ៍ទៅ នួន ជា?

[១១:២២:៣៩]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ថ្ងៃ១៥ ខែសីហា ១៩៧៧ បងនួន ឲ្យគេហៅខ្ញុំទៅធ្វើការ។ ទៅដល់គាត់ប្រាប់ខ្ញុំថា មិត្តខៀវ ទៅសមរភូមិហើយ ខ្ញុំជំនួស។ នេះគឺជួបគ្នានៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅជាន់លើទៅទៀតពេលនុ៎ង។ ដូច្នេះ ខ្ញុំរាយការណ៍ជូនបង នួន តាំងពីពេលនុ៎ងរហូតមក។

**ស៖** តើលោកប្រាស្រ័យទាក់ទងញឹកញាប់របៀបណា? បានន័យថា តើលោករាយការណ៍ញឹកញាប់បែបណាទៅ នួន ជា?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

[១១:២៣:៤៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ។ ខ្ញុំមានការជំទាស់ជាទូទៅ ទៅលើប្រភេទសំណួរនេះ ហើយខ្ញុំគិតថា ព្រះរាជអាជ្ញានឹងសួរសំណួរបែបនេះតទៅទៀតចំពោះសាក្សីទាក់ទងទៅនឹងកូនក្តីរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមលើកការជំទាស់ជាទូទៅ។ ខ្ញុំដឹងថា លោក លោកស្រីចៅក្រមនៅក្នុងអង្គជំនុំជម្រះនេះ បានសម្រេចថាព្រះរាជអាជ្ញាអាច

ហើយនិងយើងអាចពិនិត្យទៅលើសាក្សីនេះបានអំពី-- បានន័យថា អាចសាកសួរទៅលើសាក្សីអំពីរចនាសម្ព័ន្ធ ទាំងរចនាសម្ព័ន្ធក៏ដូចជា ការទំនាក់ទំនងបន្ទាប់ពីរយៈពេលដែលពាក់ព័ន្ធនៅក្នុងសវនាការទីមួយ ហើយយើងឲ្យពិភាក្សាអំពីតួនាទីរបស់ជនជាប់ចោទ ទោះបីថាវាមិនពាក់ព័ន្ធទៅនឹងអង្គហេតុ ឬក៏ពាក់ព័ន្ធទៅនឹងបទចោទដែលយើងត្រូវត្រួតពិនិត្យនៅក្នុងសវនាការនេះក៏ដោយ។

[១១:២៤:៤៣]

ហើយខ្ញុំក៏ដឹងថា លោក លោកស្រីចៅក្រមបានសម្រេចដែរ។ ដូច្នេះដើម្បីឲ្យច្បាស់អំពីអង្គហេតុដែលយើងត្រូវចោទសួរ ខ្ញុំស្នើថា ឲ្យៗព្រះរាជអាជ្ញាសួរតែទៅលើការ-- ទៅលើអង្គហេតុពាក់ព័ន្ធជាក់ស្តែងដូចជា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏ចលនាប្រជាជននៅក្នុងឆ្នាំ៧៥, ៧៦ ទៅភាគខាងឧត្តរ។ ដូច្នេះ ខ្ញុំស្នើថាយើងត្រូវមានការប្រុងប្រយ័ត្នក្នុងការពិភាក្សាអំពីរចនាសម្ព័ន្ធនៅក្រោយរយៈពេលបឋម។ គឺរយៈពេលដែលយើងបាននិយាយក្នុងពេលកន្លងមកហើយ។ ហើយអ្វីដែលព្រះរាជអាជ្ញាដែលបានលើកឡើងនេះ គឺវាហាក់ដូចជារយៈពេលនៅឆ្នាំ៧៧ រហូតដល់ឆ្នាំ៧៨ និងដល់ដើម៧៩។ ដូច្នេះ ខ្ញុំគិតថា ការសាកសួរសាក្សីនេះ អំពីហេតុការណ៍ទាំងអស់នោះ គឺហាក់ដូចជាការបង្កឲ្យមានព្យសនកម្មចំពោះសាក្សីរបស់យើង ដោយសារមានហេតុផលពីរ។ ទីមួយ គឺថាៗ ជាការផ្តល់នូវការបង្ហាញមួយថា កូនក្តីរបស់យើងមានការទទួលខុសត្រូវច្រើន ឬក៏មានការទទួលខុសត្រូវលើសពីឆ្នាំ៧៥, ៧៦។ បានថាជាការនិយាយអំពីការទទួលខុសត្រូវនៅក្នុងឆ្នាំ៧៨ ឬក៏នៅក្រោយថ្ងៃ១៥ ខែ៨ ៧៧។ វាជាការបង្កឲ្យមានព្យសនកម្មដែលធ្វើឲ្យមានប៉ះពាល់ដល់សេចក្តីសម្រេច ព្រោះថា វាជាអង្គហេតុដែលកើតឡើងនៅមុនពីរឆ្នាំ។ វាជាការចោទសួរមួយដែលអាចមានគ្រោះថ្នាក់។ ដូច្នេះ ខ្ញុំស្នើថា ឲ្យមានការពិចារណាអំពីផលវិបាកនេះ។

[១១:២៦:៣៨]

ហើយចំណុចទីពីរ គឺថាយើងមិនគួរពិភាក្សាអំពីស-២១ ទេនៅក្នុងដំណាក់កាលសវនាការទីមួយនេះ។ ដូច្នេះហើយ-- ហើយម៉្យាងទៀតស-២១ មិនមែនជាផ្នែកនៃសវនាការទីមួយនេះទេ។ ដូច្នេះប្រសិនបើវាជាចេតនារបស់ព្រះរាជអាជ្ញាគឺថា យើងអាចនឹងមានសវនាការបន្ត ឬក៏សវនាការថ្មីមួយទៀតដែលវាជាសវនាការពាក់ព័ន្ធទៅលើមន្ទីរស-២១។

ដូច្នេះហើយការចោទសួរអំពីតួនាទីរបស់កូនក្តីខ្ញុំនៅក្នុងមន្ទីរស-១២ នៅក្រោយឆ្នាំ៧៧ គឺជាការបង្កឲ្យមានព្យសនកម្មដល់កូនក្តីខ្ញុំ។ ដូច្នេះហើយ យើងមិនអាចបង្កើតឲ្យមាននូវអង្គហេតុណាមួយនៅ

ក្រោយឆ្នាំ៧៧ ឬ៧៨ នោះទេ។ ដូច្នេះ ការពិចារណាអំពីការទទួលខុសត្រូវរបស់គាត់នៅមន្ទីរស-២១ ដោយមិនបានពិចារណាអំពីអង្គហេតុផ្សេងៗទៀតទេ។ ដូច្នេះហើយ ឯកសារដែលពាក់ព័ន្ធ ឯកសារ--ភស្តុតាងដែលពាក់ព័ន្ធ ឬក៏សាក្សីដែលពាក់ព័ន្ធគឺត្រូវស្នើឱ្យមានការកោះហៅ ដើម្បីសម្រេចទៅលើអង្គហេតុនៅពេលដែលយើងឈានទៅដល់សវនាការជាក់ស្តែងទាំងអស់នោះ។ ដូច្នេះ ខ្ញុំគិតថានេះ គឺជាការមួយដែលអាចបង្កឱ្យមានព្យសនកម្មទៅដល់កូនក្តី ក៏ដូចជាសវនាការនេះដែរ។

[១១:២៨:០៩]

ដូច្នេះហើយខ្ញុំគិតថា យើងគួរតែទុកសម្រាប់សវនាការបន្តទៀតដែលយើងត្រូវបន្ត។ ហេតុដូច្នេះ ការពិភាក្សាអំពីតួនាទីរបស់កូនក្តីខ្ញុំជាលម្អិត គឺយើងគួរតែទុកនៅពេលដែលលោក លោកស្រីចៅក្រមសម្រេចថា យើងដាក់ស-២១ ចូលទៅក្នុងរបៀបវារៈនៃសវនាការ។ ហើយសេចក្តីសម្រេចកាលពីខែមករា ហ្នឹង គឺមិនទាន់បានសម្រេចឱ្យច្បាស់នៅឡើយទេ។

ខ្ញុំស្នើថា យើងបន្តសំណួរបែបនេះនៅពេលដែលយើងទទួលបាននូវឯកសារពាក់ព័ន្ធទាំងអស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:២៩:០៣]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ដូចដែលលោក លោកស្រីចៅក្រមជ្រាបហើយ ដីកាទាក់ទងទៅនឹងការបំបែកសំណុំរឿងនេះ គឺត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការបង្ហាញភស្តុតាង នូវភស្តុតាងមូលដ្ឋានមួយចំនួនដែលត្រូវបានប្រើនៅក្នុងរឿងក្តី។ នេះជាគោលបំណងសំខាន់នៃគោលដៅនោះ។ ផ្នែកទាំងអស់នោះ គឺទាក់ទងពីតួនាទីរបស់ជនជាប់ចោទ រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនយោបាយ។ អ្វីដែលយើងនិយាយនោះ គឺមានការពិភាក្សា និងការសម្រេចហើយ គឺយើងនិយាយអំពីរចនាសម្ព័ន្ធទំនាក់ទំនងស-២១ ថាតើកងវរសេនាតូចផ្សេងទៀតហ្នឹង គឺថាទាក់ទងយ៉ាងដូចម្តេចនៅក្នុងខ្សែទំនាក់ទំនង ដែលវាពាក់ព័ន្ធនៅក្នុងយុត្តាធិការនៅក្នុងដីកានោះ កថាខណ្ឌ៧២ ហើយដីកាដំណោះស្រាយក៏បានបញ្ជាក់ដែរ ហើយនិងនៅក្នុងដីកាបំបែកសំណុំរឿងហ្នឹងក៏បញ្ជាក់ដែរ។ ការជម្លៀសបង្ខំ ឬការជម្លៀសប្រជាជនចេញពីភ្នំពេញដំណាក់កាលទីមួយ។

ទីពីរ ដូចដែលលោកចៅក្រមជ្រាបហើយថា ដំណាក់ទីពីរ គឺមានហេតុការណ៍ហ្នឹងឆ្នាំ១៩៧៧ មិនមែនកើតតែ៧៥ នោះទេ។ ដូចដែលលោកមេធាវីបានលើកឡើងហ្នឹង គឺនិយាយពីដំណាក់កាលទីមួយទេ ប៉ុន្តែដំណាក់កាលទីពីរ គឺឆ្នាំ៧៧ ឆ្នាំ៧៨ ហ្នឹងក៏មានដែរ។

បាទ ចំណុចទីបី គឺថាគោលបំណងនៃការតាំងសំណួរនេះ គឺមិនមែនបង្ហាញភស្តុតាងអំពីការអនុវត្តនូវបទឧក្រិដ្ឋ ឬក៏ការអនុវត្តគោលនយោបាយនៅស-២១ ទេ។ យើងមិនសួរនិយាយអំពីវិធីសាស្ត្រទារុណកម្ម ពីការសម្លាប់ ហើយយើងគ្រាន់តែសួរអំពីថា តើគេអនុវត្តការងារដោយវិធីណា? យើងសួរៗជូនសាក្សីនេះ ថាតើតួនាទីដែល នួន ជា អនុវត្តនៅពេលនោះ។ ហើយតុលាការបានសម្រេចហើយដែរថា តួនាទីរបស់ជនជាប់ចោទនៅក្នុងករណីនោះ គឺថាមានតួនាទីជាច្រើនត្រូវតែពិភាក្សា ដើម្បីបង្ហាញភស្តុតាងក្នុងរឿងក្តីនេះ។ ហើយយើងធ្វើបែបនោះ-- តាមពិតគឺថាតួនាទីខ្លះ ទាក់ទងទៅនឹងតួនាទីជាឧក្រិដ្ឋ ហើយភស្តុតាងក៏បានបង្ហាញបែបនោះដែរ។ នេះហើយជាភស្តុតាងដែលយើងទទួលបានផ្អែកទៅតាមអង្គហេតុ។

[១១:៣១:២២]

ចំណុចទីបី យើងមិនព្យាយាមសួរសំណួរសាក្សីនេះជាច្រើនថ្ងៃ អំពីតួនាទីរបស់ នួន ជា ការចូលរួមរបស់គាត់ លម្អិតជារឿងរាល់ថ្ងៃនោះទេ។ ប៉ុន្តែយើងច្បាស់ថា ការពិភាក្សាទាក់ទងទៅនឹង សុន សេន ដែលពន្យល់អំពីការជួបប្រជុំជាមួយអ្នកផ្សេងទៀតនៅក្រៅ ស-២១។

នេះគឺវាទាក់ទងទៅនឹងមធ្យោបាយទំនាក់ទំនង ការប្រាស្រ័យទាក់ទងជាមួយក្រុមផ្សេង។ ដូចគ្នាដែរជាមួយ នួន ជា យើងគ្រាន់តែចង់បង្ហាញភស្តុតាង និងឲ្យយល់ថា តួនាទីជាមូលដ្ឋានរបស់គាត់ទាក់ទងទៅនឹងប្រតិបត្តិការសន្តិសុខ ដែលមានន័យថានៅក្នុងកថាខណ្ឌមួយចំនួន ដែលតុលាការបានសម្រេចអង្គជំនុំជម្រះបានសម្រេចហើយពីកត្តានោះ។

[១១:៣២:០៩]

លោក លោកស្រីចៅក្រមនឹងបានឃើញហើយថា សំណួរហ្នឹង គឺនឹងផ្តោតចំណុចនោះមិនប្រើពេលយូរទេ។ ហើយតាមពិតយើងត្រូវបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ។ បើមិនដូច្នោះទេ យើងមិនបានបំពេញភារកិច្ចយើងជាសហព្រះរាជអាជ្ញាទេ។

គោលបំណងចំណង ហើយអ្វីដែលមេធាវីការពារយល់ខុសនោះ គឺថាគាត់យល់ថា យើងបង្ហាញភស្តុតាងឲ្យលម្អិតនៅទីនេះ ហើយយកទៅបង្ហាញទៀតនៅករណីផ្សេង។ តាមពិតមិនមែនដូច្នោះទេ

យើងនិយាយតែពីការប្រាស្រ័យទាក់ទង រចនាសម្ព័ន្ធ តួនាទីរបស់ជនជាប់ចោទ។ ហើយយើងយល់ឃើញថា យើងមិនសួរសំណួរដដែលៗជារៀងរាល់ថ្ងៃទៅចំណុចដែលយើងនិយាយអំពីការអនុវត្ត ឬក៏ការចូលរួមជាលម្អិតរបស់ជនជាប់ចោទ។ យើងយល់ហើយថា នេះមិនមែនជាគោលបំណងនៃសវនាការនេះទេ។ ប៉ុន្តែតួនាទីរបស់គាត់ហ្នឹង គឺជាទិសដៅនៃសវនាការនេះ។ ហើយតុលាការ អង្គជំនុំជម្រះក៏បានតម្រូវឲ្យធ្វើបែបនោះ។

[១១:៣៣:១៤]

បាទ ដូច្នេះយើងនឹងសួរដើម្បីឲ្យចេញជា-- ទទួលបានជាព័ត៌មាន និងភស្តុតាងដើម្បីបង្ហាញអំពីចំណុចទាំងនោះ គឺមិនមែនយើងសួរលម្អិតទៅដល់ករណីផ្សេងនោះទេ។

សូមអរគុណ លោកប្រធាន លោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឆ្លើយតបដោយសង្ខេប។ សហព្រះរាជអាជ្ញាបាននិយាយថា គាត់បង្ហាញ ព្យាយាមបង្ហាញភស្តុតាងដើម្បីឲ្យហួសពីវិមតិសង្ស័យ ដើម្បីហើយសូមឲ្យតុលាការបង្ហាញឆន្ទះរបស់គាត់ថា តួនាទីរបស់កូនក្តីរបស់ខ្ញុំហ្នឹងមានអ្វីខ្លះនៅស-២១? នៅក្នុងការសវនាការជាក់លាក់នេះ តើគោលបំណងមួយទៀតដែលថា សវនាការលើស-២១ ដើម្បីអ្វី? បើយើងសួរមកកន្លែងនេះហើយ។ តើនឹងសួរអ្វីនៅទីនោះ?

[១១:៣៤:០៤]

ជាពិសេសជាតួនាទីនៅក្នុងករណីឧក្រិដ្ឋស-២១ គឺត្រូវបង្ហាញភស្តុតាងនៅក្នុងរឿងក្តីផ្សេង។ យើងមិនអាចធ្វើសេចក្តីសន្និដ្ឋានអំពីតួនាទីរបស់គាត់បានទេ បើមិនមានភស្តុតាងអ្វីផ្សេងដែលយើងចង់បង្ហាញនៅក្នុងករណីនោះជាឯកសារភស្តុតាង ដែលមិនទាន់បានបង្ហាញ។ នេះហើយ គឺជាគោលដៅនៃសាក្សីដែលនៅក្នុងបញ្ជីរបស់ខ្ញុំ គឺថាមិនមែនស្ថិតនៅក្នុងបញ្ជីដែលកំណត់សម្រាប់សវនាការនេះទេ។

សូមលោក លោកស្រីចៅក្រម កម្រិតឲ្យសហព្រះរាជអាជ្ញាសួរសំណួរឲ្យកម្រិតត្រឹមហ្នឹង ហើយដើម្បីកុំឲ្យចៀសវាងមានសេចក្តីសន្និដ្ឋានលើតួនាទីរបស់កូនរបស់ខ្ញុំ ដែលទូលាយពីអ្វីដែលជាមុខការនៅក្នុងសវនាការនេះ។ សូមអរគុណ។

[១១:៣៤:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៧:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារមានការជំទាស់អម្បាញ់មិញនេះ ពីសំណាក់មេធាវីអន្តរជាតិការពារក្តី នួន ជា ទៅលើការសួរដេញដោលក្របខ័ណ្ឌ ឬក៏វិសាលភាពនៃការសួរដេញដោលដែលធ្វើឡើងដោយតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសម្រេចថា ការជំទាស់តវ៉ារបស់មេធាវីអន្តរជាតិការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ ដោយសារមូលហេតុអង្គជំនុំជម្រះបានសម្រេចរួចហើយ។ ប៉ុន្តែទន្ទឹមនឹងនេះ ក៏អង្គជំនុំជម្រះសូមរំឭកបន្ថែមទៀត ចំពោះតំណាងសហព្រះរាជអាជ្ញា សូមមានការយកចិត្តទុកដាក់ក្នុងការតាំងសំណួរនៅក្នុងបរិបទដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១។ ហើយនៅដំណាក់កាលដែលដេញដោលនេះ គឺជុំវិញបញ្ហានៃប្រព័ន្ធទំនាក់ទំនងការងារកម្ពុជាប្រជាធិប-តេយ្យ គឺគប្បីចៀសវាងនៅក្នុងការសួរដេញដោលនូវបញ្ហាណាដែលមានលក្ខណៈស៊ីជម្រៅ ទៅលើក្របខ័ណ្ឌនៃអង្គហេតុជាក់លាក់នៅក្នុងដំណើរការប្រតិបត្តិការនៃមន្ទីរសន្តិសុខ ស-២១។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ! ហើយសំណួរចុងក្រោយអំមិញអាចបន្ត-- អ៎! អាចសួរឡើងវិញដើម្បីរំឭកដល់សាក្សី ដើម្បីស្តាប់បាន និងយល់អំពីសំណួរ ដើម្បីអាចឆ្លើយតបបាន។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ យើងខ្ញុំមានការប្រុងប្រយ័ត្នយ៉ាងប្រាកដណាស់ ដើម្បីគោរពទៅតាមដីកាសម្រេចនោះនៅក្នុងករណីនេះ។ ហើយខ្ញុំយោងទៅរកសម្តី កថាខណ្ឌ ៨៧៨ អំពីតួនាទីរបស់លោក នួន ជា នៅក្នុងក្បាលម៉ាស៊ីនសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យសាក្សីបានស្តាប់ ហើយដើម្បីឲ្យគាត់ពន្យល់ឲ្យច្បាស់អំពីដែលថាភស្តុតាងហ្នឹង គឺជាអ្វីដែលយើងនិយាយនេះឯង អំពីកថាខណ្ឌ៨៧៨ នៅក្នុងដីកានោះ។ ហើយសំណួរមួយចំនួនដើម្បីយើងសួរ ដើម្បីបង្ហាញភស្តុតាងអំពីអ្វីដែលបញ្ជាក់នៅក្នុងអង្គហេតុនោះ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី យើងនិយាយអំពីការជួបជាមួយលោក សុន សេន។ លោកបាននិយាយថាលោកបានប្រាប់តុលាការថានៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ លោក នួន ជា--

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ដាច់ការបកប្រែជាខ្មែរអំមិញ។ ដាច់ការបកប្រែជាខ្មែរអំមិញមួយកំណាត់ចុងក្រោយ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា! ចាត់តាំង-- អឺ! នែ៎ តាំងសំណួរសាជាថ្មីម្ដងទៀត ពីព្រោះការបកប្រែមិនបានពេញលេញទេ សំណួររបស់លោក។ ដូច្នេះ សាក្សីមិនអាចឆ្លើយនឹងសំណួរបានទេ ពីព្រោះស្ដាប់សំណួរជាភាសាខ្មែរមិនបានពេញលេញនូវខ្លឹមសារដែលបណ្ដាលមកពីបញ្ហាបកប្រែភាសា។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបញ្ហានេះជាមួយនឹងអង្គភាពបកប្រែ។

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអាចបន្តតាំងសំណួរសាជាថ្មីម្ដងទៀត។

[១១:៤២:២៨]

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី លោកបាននិយាយថានៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ លោក សុន សេន លែងក្លាយជាមេរបស់លោកហើយ ហើយ នួន ជា មកជំនួស។ តើលោកដឹងកាលបរិច្ឆេទច្បាស់ម្ល៉េះ ហេតុអ្វីបានជាលោកចាំ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** បងនួន ធ្វើធំជាងបង ខៀវ--សុន សេន។ ដូច្នេះជួបមេធំ វារំភើបដែរ កត់ត្រាទុក។

**ស៖** ថាតើលោកបានជួប នួន ជា ញឹកញាប់ប៉ុនណាក្រោយពីកាលបរិច្ឆេទនោះមក?

[១១:៤៣:២៩]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលអស់ថ្មហើយ! ដូរថ្មជូនសាក្សី។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** តើលោកសាក្សីស្ដាប់ខ្ញុំឮហើយឬនៅ? ថាតើលោកបានជួប នួន ជា ញឹកញាប់ប៉ុនណាក្រោយពីកាលបរិច្ឆេទដែលលើកអម្បាញ់មិញនេះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ប្រហែលជាបីថ្ងៃ។ យ៉ាងយូរណាស់ប្រាំថ្ងៃម្ដង គាត់ហៅខ្ញុំទៅ គាត់ឲ្យគេទូរស័ព្ទមកហៅខ្ញុំ។

**ស៖** តើលោកបានជួបគាត់នៅកន្លែងណា?

**ឆ៖** កន្លែងដែលជួបគាត់ គឺនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ជាន់ផ្ទាល់ដី។

**ស៖** បើនិយាយជាមធ្យម តើលោកជួបគាត់ម្ដងៗហ្នឹង ប្រើរយៈពេលប៉ុន្មានដែរ?

**ឆ៖** ជួបប្រហែលជាដប់មីនុត លើសខ្វះបន្តិចបន្តួច។ គាត់មិនសូវនិយាយច្រើនទេ។

**ស៖** ចាតើមានអ្នកណាផ្សេងវត្តមាននៅក្នុងការជួបជាមួយគាត់នោះទេ?

**ឆ៖** ជួបតែពីរនាក់ទេ ក៏ប៉ុន្តែកងការពារមិនដឹងគេពួននៅត្រង់ណាខ្លះ ការពារគាត់ទេ។

**ស៖** អ្នកណាជាអ្នកកោះហៅប្រជុំ តើលោកជាអ្នកកោះហៅ ឬក៏លោក នួន ជា ឬអ្នកណាផ្សេងជាអ្នកកោះឲ្យទៅប្រជុំនោះ?

**ឆ៖** ទម្លាប់របស់កម្ពុជាប្រជាធិបតេយ្យ កូនមិនដែលហ៊ានហៅមេប្រជុំទេ គឺមេហៅកូនទៅប្រជុំ។ នេះជាហូរហែអ៊ីចឹង។ អ្នកដែលទូរស័ព្ទមកហៅខ្ញុំគឺ មិត្តទៀង។

**ស៖** ចាតើនៅក្នុងការប្រជុំនោះ ពិភាក្សាពីបញ្ហាអ្វីដែរ?

**ឆ៖** ពិភាក្សាតែអំពីចម្លើយខ្មាំង ហើយផ្សេងៗនោះ ខ្ញុំអាចរាយការណ៍អំពីសភាពការណ៍អង្គភាពជូនគាត់ខ្លះ ជូនគាត់។

[១១:៤៧:២៣]

**ស៖** នៅពេលដែលនិយាយថា លោកពន្យល់ពីស្ថានភាពទូទៅ ចាតើស្ថានភាពហ្នឹងទាក់ទងទៅនឹងបញ្ហាអ្វី?

**ឆ៖** ស្ថានភាពហ្នឹងនិយាយអំពីបាតុភាពសម្រុកការងារ ហើយនិងបាតុភាពសេរីនៅក្នុងអង្គភាព ជាពិសេសបាតុភាពសេរីនៅក្នុងអង្គភាព ដែលគួរឲ្យចាប់អារម្មណ៍។

**ស៖** តើលោកចង់មានអត្ថន័យដូចម្ដេច និយាយថា បាតុភាពសេរីហ្នឹងបាទ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ ក៏ប៉ុនខ្ញុំនិយាយជាទូទៅទេ។ ឧទាហរណ៍ មិត្តខ្លះសួរពឹងផ្អែកតែលើវ៉ៃខ្លាំងពេក ក៏យើងអាចសន្មតថា ជាបាតុភាពសេរី។ មិត្តខ្លះប៉ាកល្ងើយមិនសួរ ក៏បាតុភាពសេរី។ មិត្តខ្លះបណ្ដោយឲ្យអ្នកឆ្លើយហ្នឹង និយាយរាលដាលដាក់គេដាក់ឯង ក៏យើងចាត់ទុកថា ជាបាតុភាពសេរី។ នេះម៉្យាង។ ម៉្យាងទៀត សេរីដើរហើរអី។ ជាទូទៅនៅស-២១ គ្មាននរណាហ៊ានសេរីដើរហើរទេ អាហ្នឹងយើងចាត់ទុកថា ជាល្អ ដែលខាងលើ-- ខ្ញុំរាយការណ៍ជូនខាងលើ។

[១១:៤៩:១១]

**ស៖** លោកនិយាយថា កិច្ចប្រជុំហ្នឹង គឺធ្វើឡើងរៀងរាល់បីថ្ងៃម្ដង។ ថាតើបន្តរៀងរហូតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ តាំងពីលោករាយការណ៍ទៅឲ្យគាត់នោះ?

**ឆ៖** តាំងពីខ្ញុំរាយការណ៍ទៅឲ្យគាត់ វាមានពីរកំណាត់ដាក់ដោយឡែកពីគ្នា។ មួយកំណាត់ទីមួយ មុនគាត់ទៅទស្សនកិច្ចនៅចិន។ ទៀងទាត់ យ៉ាងយូរណាស់ប្រាំថ្ងៃ។ ដល់គាត់ទៅទស្សនកិច្ចនៅចិនទៅ ប៉ង់ គេចុះមកក្នុងឋានៈជាអ្នកនាំពាក្យរបស់ ប៉ុល ពត មកខ្ញុំ។ ដូច្នេះ ក្នុងឋានៈគេជាអ្នកនាំពាក្យនេះ គេអាចសម្រេចកិច្ចការតូចធំបាន។ ក្រោយពីគាត់ត្រឡប់មកពីចិនវិញ ការជួបខ្ញុំរវាងខ្ញុំ ហើយនិងបងនួន មានលក្ខណៈមួយអាចរយាលយើងគិតថាប្រាំថ្ងៃម្ដងក៏ថាបានដែរ។

**ស៖** មុនពេលដែលគាត់ទៅប្រទេសចិន គឺជួបគាត់រៀងរាល់បីថ្ងៃម្ដង ក្រោយពីគាត់មកវិញថាបី-- ប្រាំថ្ងៃបានជួបម្ដង តើអ៊ីចឹងត្រូវទេបាទ?

**ឆ៖** សូមកុំនិយាយបីថ្ងៃដាច់ណាត់ ប្រហាក់ប្រហែលហ្នឹង បើយូរក៏បួនថ្ងៃប៉ុនទុំងដែរ យ៉ាងយូរប្រាំថ្ងៃ។

**ស៖** នេះជាទូទៅដើម្បីយើងអាចបញ្ចប់ប្រធានបទនេះ ហើយប្រហែលថាដើម្បីចៀសវាងនៅក្នុងការបង្ហាញឯកសារមួយៗនោះ តើអ្វីគាត់តែងតែលើកពីបញ្ហាអ្វីនៅក្នុងកិច្ចប្រជុំទាំងអស់នេះទាក់ទងទៅនឹងសេចក្ដីសារភាពដែលលោកបាននិយាយនោះ? ថាតើប្រភេទនៃការពន្យល់របស់លោកទៅជូនគាត់ហ្នឹងគឺលោកពន្យល់អ្វីខ្លះនៅក្នុងកិច្ចប្រជុំទាំងនោះ?

[១១:៥១:៣១]

**ឆ៖** ខ្ញុំមិនចាំទេ ជាទូទៅ។ ក៏ប៉ុន្តែមានថ្ងៃមួយនោះ គាត់សួរខ្ញុំថា មិត្តធ្វើអីប៉ុន្មានថ្ងៃ? ដូចជាគ្មានអីរាយការណ៍ ហើយតាមពិតមែន អង្កាល់នោះខ្ញុំនិយាយឲ្យជាក់ស្ដែងទៅខ្ញុំអស់កម្លាំងធ្វើការហើយវាធ្លាយដល់ថ្នាក់លើឃើញ សង្កេតឃើញ។ នេះខ្ញុំមិននិយាយពីសាច់រឿង ដែលគេឆ្លើយដាក់ប៉ះអ្នកនេះយ៉ាងម៉េច? ប៉ះអ្នកនោះយ៉ាងម៉េចទេ? អាហ្នឹងវាចូលសាច់រឿង ខ្ញុំសូមមិនទាន់និយាយទេ។

**ស៖** បើនិយាយដោយជាក់លាក់ តើអ្វីខ្លះដែលលោកបានរាយការណ៍ទៅឲ្យលោក នួន ជា នោះ?

**ឆ៖** និយាយដោយជាក់លាក់គឺ ចម្លើយសារភាពរបស់មនុស្សដែលជាប់នៅស-២១ អ្នកណាដែលខាងលើចាត់ទុកថាជាសំខាន់ ឬក៏ជួនអីយើងអាចបន្ថែមថា អ្នកនេះដូចជាសំខាន់ដែរ ក៏សឹងថាបានក៏ប៉ុន្តែជាទូទៅខ្ញុំត្រូវរាយការណ៍ជូនគាត់ នូវអ្នកទាំងឡាយណាដែលគាត់ចាត់ទុកជាសំខាន់ ហើយចម្លើយដល់ណាហើយ ដើម្បីសូមមតិកែប្រែ ហ្នឹងអ៊ីចឹង។

[១១:៥២:៥៧]

អ៊ីចឹងហើយបានជាលេចអាចចម្លើយអីណា ខ្ញុំថាតាមការណែនាំថ្ងៃ២៥ របស់បងទីពីរអីហ្នឹង។ វាលេចចេញអ៊ីចឹង។

**ស៖** បន្ទាប់ពីលោកបានរាយការណ៍ទៅជូនគាត់ហើយនោះ នូវព័ត៌មានមួយចំនួននៅក្នុងសេចក្តីសារភាពនៅក្នុងការប្រជុំរួចមក តើលោកទទួលការណែនាំអ្វីពីគាត់តទៅទៀតដែរឬទេ?

**ឆ៖** វាយូរពេកភ្លេចអស់ហើយ ក៏ប៉ុន្តែឯកសារមួយអំមិញហ្នឹងវាច្បាស់ហើយ។ គាត់ណែនាំឲ្យដកឈ្មោះនេះចេញបើមាន។ ហ្នឹងគឺច្បាស់លាស់ មានឯកសារនៅហ្នឹង។ ហើយបើដល់ហ្នឹងហើយខ្ញុំគិតថា គួរនិយាយដែរអំពីអ្នកខ្លះឆ្លើយដាក់។ ឧទាហរណ៍ មានម្នាក់នោះឆ្លើយដាក់ប្អូនថ្លៃគាត់ឈ្មោះ ក្លយ ហើយនិងស្រីម្នាក់ឈ្មោះ កូ ស៊ីលឹង គាត់ថា ហ៊ឺ! មនុស្សនេះយើងចិញ្ចឹមដូចកូន ដូចចៅតាំងពីក្មេងមកហ្នឹងមួយម៉ាត់ទៅ។ ហើយនៅពេលមួយនោះគេឆ្លើយដាក់ មិញ ហើយនិង ពឿន។ មិញ ហ្នឹងកូនបង្កើតរបស់ អៀង សារី។ ពឿន ហ្នឹងកូនប្រសារបស់ អៀង សារី មិត្តភក្តិខ្ញុំ។ ដល់គាត់ឃើញខ្ញុំភ័យគាត់ថាយីស! មិត្តភ័យព្រោះ មិញ អេះ! ខ្ញុំក៏ហួសចិត្ត។ ដូច្នេះខ្ញុំត្រឡប់មកផ្ទះវិញឲ្យគេដកឈ្មោះ មិញ ហើយនិង ពឿន ចេញ។ នេះរបៀបហ្នឹង។ ហើយដល់ក្រោយមកមានម្នាក់ ឆ្លើយដាក់ ខៀវ សំផន ថាជាអ្នកដឹកនាំខាងផ្លូវក្បត់។ ខ្ញុំទៅរាយការណ៍ជូនគាត់ គាត់ថាមិត្តអេះ! មួយស្រុកខ្មែរនៅសល់តែខ្ញុំហើយនិងបង ប៉ុល មួយទេ។ មិត្តចង់ទៅធ្វើទូតទេ? រឿងទាំងអស់នេះ ខ្ញុំអត់លាក់ទេរាយការណ៍ជូនសហព្រះរាជអាជ្ញា-- (សូមទោស) សហការិយាល័យសហចៅក្រមស៊ើបអង្កេតរួចអស់ហើយ។

**ស៖** យើងអាចបញ្ចប់នូវប្រធានបទនេះ នៅពេលនេះ តើលោកតែងតែនិយាយថា គោលបំណងនៃការប្រជុំជាមួយលោក នួន ជា នោះ ថាតើគោលបំណងចម្បង គឺដើម្បីអ្វីកាលសម័យនោះ?

**ឆ៖** ការដែលគាត់ហៅខ្ញុំទៅធ្វើការ។ គោលបំណងរបស់គាត់គឺដើម្បីក្តាប់សភាពការណ៍ចម្លើយមនុស្សសំខាន់ដែលគាត់ចាប់អារម្មណ៍ឲ្យបាន ដើម្បីមានវិធានការចំពោះមុខ។ បន្ទាប់មក ក្តាប់សភាព-ការណ៍នៅស-២១ ដើម្បីមានមតិណែនាំ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងត្រឡប់ទៅរកអំពីប្រព័ន្ធទំនាក់ទំនងនៅក្នុងស-២១ នៅពេលហូបរួមគ្នា ឬក៏បាយល្ងាចអីជាដើមហ្នឹង ថាតើគេហូបរួមគ្នា ឬក៏ដាច់ដោយឡែកពីគ្នា នៅក្នុងស-២១?

**ឆ៖** បង ប៉ុល ប្រកាសដូចនៅក្នុងបុណ្យ គាត់ប្រកាសពេលណាទេ ផ្សាយស្រួលបួលផង។

នៅក្នុងបទឧទ្ទេសនាមណាមិនដឹងទេ ឲ្យហូបរួម។ គ្មាននរណាមួយបានហូបដោយឡែកទេ។ ដូច្នេះ នៅស-២១ ចង្ក្រានបាយនោះ គឺនៅចុង ត្រង់ណា ខ្ញុំបានគូរនៅក្នុងប្លង់របស់ខ្ញុំជូនអស់ហើយ។ ចង្ក្រានបាយបុគ្គលិកនៅនុំង ខ្ញុំទៅហូបរួមនឹងគេ។

[១១:៥៧:២៦]

**ស៖** ក្នុងការហូបរួមនេះ ជាគោលការណ៍មួយ តើលោកបានដឹងទេ ថាគេអនុវត្តនៅក្រៅស-២១ ទេ? ឬក៏នៅក្នុងមន្ទីរក្រសួងផ្សេងទៀតដែរទេ?

**ឆ៖** បងប៉ុល គឺ ប៉ុល ពត នេះ ជាលេខាបក្ស។ បញ្ជារបស់គាត់សម្រាប់ទូទាំងបក្ស។ គ្មាននរណាហ៊ានល្មើស។

**លោក វីល្លៀម ស្មឺត៖**

លោក លោកស្រីចៅក្រម អាចនឹងដល់ពេលសមស្រប ដើម្បីសម្រាកពិសាអាហារថ្ងៃត្រង់។ ខ្ញុំសូមអនុញ្ញាតឲ្យតុលាការឲ្យខ្ញុំបានបន្តនៅពេលបន្ទាប់ពីនោះ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាក ដើម្បីពិសាត្រង់ថ្ងៃហើយ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ហ្នឹង ទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការកន្លែងផ្តល់សក្ខីកម្ម នៅរសៀលនេះ នៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១១:៥៩:០៥]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ គាត់អស់កម្លាំង។ គាត់ចង់សូមអនុញ្ញាតថយទៅតាមដាននៅខាងបន្ទប់ខាងក្រោម ដើម្បីតាមដាន ហើយនិងខ្ញុំជម្រាបជូនតុលាការថា បើសិនជាគាត់មានលទ្ធភាពកែប្រែ ខ្ញុំនឹងជូនដំណឹងតុលាការ ហើយខ្ញុំនឹងដាក់លិខិតលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងសាលសវនាការនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សូមទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមបន្ទប់សវនាការនេះ តាមប្រព័ន្ធសោតទស្សន៍ ដោយលះបង់សិទ្ធិមិនចូលរួមតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយមានបញ្ហាសុខភាព មិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការបាន ហើយដោយសន្យាថានឹងផ្ដល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដែលធ្វើឡើងដោយកូនក្ដីរបស់ខ្លួន។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[១២:០០:៤២]

អង្គជំនុំជម្រះបង្គាប់ឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដែលធ្វើឡើងដោយលោក នួន ជា ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងខ្លួនជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងរសៀលនេះ បង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន ឡើងមកកាន់បន្ទប់សវនាការឲ្យមុនម៉ោងមួយសាមសិបនាទី។

ដោយឡែកលោក នួន ជា គឺរក្សាទុកគាត់ឲ្យបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ដែលបានរៀបចំទុកសម្រាប់គាត់។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៨]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីអាចសួរសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ទិវាសួស្តីអស់លោក លោកស្រីទាំងអស់គ្នា ហើយក៏សូមសួស្តីលោកសាក្សី។

[១៣:៣២:៥៥]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកកាំង ហ្កេកអ៊ាវ មុនពេលដែលយើងឈប់សម្រាកអាហារថ្ងៃត្រង់ យើងបានពិភាក្សាអំពីព័ត៌មានដែលលោកបានផ្តល់ អំពីការប្រាស្រ័យទាក់ទង ការបញ្ជូនព័ត៌មាននៅ ស-២១។ ហើយក៏បានប្រាប់យើងអំពីការចែករំលែក ឬក៏ការបញ្ជូនព័ត៌មានចេញខាងក្រៅស-២១ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ឥឡូវនេះខ្ញុំសូមបន្តទៅការប្រាស្រ័យទាក់ទងនៅក្រៅស-២១ ហើយខ្ញុំសូមចោទសំណួរទាក់ទងទៅនឹងការសិក្សា ការរៀនសូត្រ ឬមួយក៏ការសង្កេត ព្រមទាំងបទពិសោធន៍របស់លោក ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរដ្ឋ បានន័យថា គឺដំណើរការវិវឌ្ឍនៃបក្សកុម្មុយនីស្តកម្ពុជា។ លោកបាននិយាយអំពីគោលការណ៍ទូទៅ និយាយអំពីលក្ខណៈសម្បត្តិរបស់បក្ខជនបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងគោលនយោបាយ និងគោលការណ៍នានា។ ឥឡូវនេះ ខ្ញុំសូមចោទសួរសំណួរមួយចំនួនអំពីរដ្ឋ បានន័យថា រដ្ឋជារួមតែម្តង។ បានន័យថា តើបក្សកុម្មុយនីស្តកម្ពុជាហ្នឹង ទំនាក់ទំនងយ៉ាងម៉េចជាមួយនឹងរដ្ឋ នៅក្នុងរយៈពេលទាំងមូល បានន័យថា នៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យទាំងមូល។

ខ្ញុំគិតថា ប្រហែលជាលោកបានផ្តល់រួចហើយនៅក្នុងសក្ខីកម្មរបស់លោក ប៉ុន្តែថាតើមានបក្ស--មានគណបក្សនយោបាយប៉ុន្មាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីខែមេសា ៧៥ រហូតដល់ខែមករា ឆ្នាំ៧៩?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ក្រោយ១៧ មេសា រហូតដល់ ០៦ មករា ១៩៧៩ មានបក្សតែមួយទេ គឺបក្សកុម្មុយនីស្តកម្ពុជា ដែលគ្រប់គ្រងរដ្ឋផ្តាច់មុខ គ្រប់មុខ ហើយនិងដាច់ខាតតែម្នាក់ឯង។

[១៣:៣៥:០៧]

**ស៖** នៅពេលដែលលោកនិយាយថា គណបក្សគ្រប់គ្រងអ្វីៗទាំងអស់ បានន័យថាគ្រប់គ្រងផ្ដាច់មុខតែម្ដង។ តើៗលោកចង់និយាយថាគណបក្សហ្នឹងគ្រប់គ្រងទៅលើអ្វី?

**ឆ៖** ផ្ដាច់មុខ មិនមែនមានន័យទៅលើអ្វីទេ ផ្ដាច់មុខគឺមានន័យថាម្នាក់ឯងគត់ អត់ឲ្យអ្នកណាជ្រៀតជ្រែក គ្មានបក្សណាមួយទៀតជាទីពីរ។ គ្មានមាគ៌ាបក្សណាមួយទៀតជាទីពីរ គ្មានសតិអារម្មណ៍ វណ្ណៈ បក្សណាមួយទៀត វណ្ណៈផ្សេងណាមួយទៀតជាទីពីរទេ។ នេះផ្ដាច់មុខ។

**ស៖** ចុះទ្រព្យសម្បត្តិវិញយ៉ាងម្ដេចដែរ? តើអ្នកណាជាអ្នកគ្រប់គ្រងទៅលើទ្រព្យសម្បត្តិ? បានន័យថាទ្រព្យសម្បត្តិឯកជន។ ឧទាហរណ៍ដូចជា អគារ ឃ្លាំង ដី តើអ្នកណាជាអ្នកគ្រប់គ្រងទៅលើទ្រព្យសម្បត្តិទាំងអស់នេះនៅក្នុងរយៈរបបកម្ពុជាប្រជាធិបតេយ្យ?

[១៣:៣៦:១៦]

**ឆ៖** ទ្រព្យសម្បត្តិទាំងអស់នេះ ខ្ញុំធ្លាប់រាយការណ៍រួចមកហើយ ជូនសហចៅក្រមស៊ើបអង្កេតហៅថា "មធ្យោបាយផលិតកម្ម" រួមមាន៖ ទាំងដីស្រែ ដីចម្ការ រោងចក្រ រោងកម្មន្តសាល មធ្យោបាយដឹកជញ្ជូនគ្រប់បែបយ៉ាង រួមទាំងសម្បត្តិធម្មជាតិលើដី ក្នុងដី ទាំងអស់ ហៅថា "មធ្យោបាយផលិតកម្ម"។ ទាំងអស់នេះស្ថិតនៅក្នុងកណ្ដាប់ដៃបក្សកុម្មុយនីស្តកម្ពុជាតែម្នាក់ឯងគត់។

**ស៖** ចុះស្ថាប័នសាធារណៈឧទាហរណ៍ដូចជា សាលារៀន មន្ទីរពេទ្យ ឬក៏កន្លែងព្យាបាលជំងឺនានា បានន័យថា ស្ថាប័នរដ្ឋ តើអ្នកណាជាអ្នកគ្រប់គ្រងទៅលើស្ថាប័នរដ្ឋទាំងអស់នោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? បានន័យថាចាប់ពីឆ្នាំ៧៥ មក។

**ឆ៖** ស្ថាប័នរដ្ឋទាំងអស់គ្រប់គ្រងផ្ដាច់មុខដោយបក្សកុម្មុយនីស្តកម្ពុជា។

[១៣:៣៧:៤៨]

**ស៖** តើនៅពេលណាដែលលោកចាប់ផ្ដើមឮឈ្មោះ "បក្សកម្ពុជាប្រជាធិបតេយ្យ"? បានន័យថានៅឆ្នាំណា ឬក៏នៅពេលណាដែលលោកបានឮឈ្មោះនេះ?

**ឆ៖** ក្រោយ១៧ មេសា។

**ស៖** តើគេៗចាប់ផ្ដើម-- តើគេដំណើរការដោយរបៀបណា? តើគេប្រកាសដោយរបៀបណា?

**ឆ៖** ខ្ញុំចាំស្រពេចស្រពិលណាស់ ក៏ប៉ុន្តែមានប្រកាសតាមវិទ្យុក៏មានដែរ ហើយមានប្រកាសអំពីកំណើតសភា។ សភាដែលខ្ញុំហៅថា "ស្ថាប័នឧបកិច្ច" នោះក៏មាន។ ហើយរដ្ឋធម្មនុញ្ញនេះមានផ្ដល់

ទៅគ្រប់កន្លែង មានដល់ទៅស-២១ ផងដែរ រដ្ឋធម្មនុញ្ញ។ ហើយពេលប្រជុំអនុម័តលក្ខន្តិកៈហ្នឹង គេយកកងទ័ពនៅភ្នំពេញហ្នឹង ទៅប្រជុំតែម្តង មិត្តហ៎ា ទៅប្រជុំនឹងគេដែរ។

[១៣:៣៩:៣១]

**ស៖** នៅពេលដែលលោកនិយាយថា លក្ខន្តិកៈត្រូវបានគេអនុម័ត តើលោកចង់និយាយអំពីលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា ឬក៏រដ្ឋធម្មនុញ្ញ?

**ឆ៖** សូមទោស! ខ្ញុំនិយាយអាចច្រឡំ។ ខ្ញុំនិយាយនេះ គឺសំដៅ "រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ"។

[១៣:៤០:០០]

**ស៖** នៅក្នុងរយៈពេលនោះ តើលោកបានសិក្សាពីបញ្ញត្តិ ឬក៏មាត្រានៅក្នុងរដ្ឋធម្មនុញ្ញនោះទេ?

**ឆ៖** រដ្ឋធម្មនុញ្ញប្រកាសតាមវិទ្យុ ផ្សាយជាៗអត្ថបទផង ផ្សាយជាទម្រង់អាយ៉ៃឆ្លើយឆ្លងរវាងស្រីនិងប្រុសផង។ ក្នុងមាត្រាទាំងអស់នៃរដ្ឋធម្មនុញ្ញ ខ្ញុំអត់មានបានរៀនទេ គ្រាន់តែបានឮផ្សាយតាមវិទ្យុហ្នឹងឯង។

**ស៖** តើលោកដឹងទេថា អ្នកណាជាអ្នកតាក់តែង ឬក៏អ្នកណាជាអ្នកសរសេររដ្ឋធម្មនុញ្ញនោះ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ មិនច្បាស់ជាអ្នកណាទេ។ ក៏ប៉ុន្តែមិនមែនថ្នាក់ក្រោមទេ គឺថ្នាក់លើហ្នឹង។ បើមិនបងទីមួយ ប៉ុល ពត គឺបងទីពីរ នួន ជា គាត់សរសេរ។ តែគំនិតផ្តើមគឺពិតជាបងទីមួយ ប៉ុល ពតហើយ។

[១៣:៤១:២៩]

**ស៖** តើលោកបានទទួលនូវធម្មនុញ្ញជា-- តើលោកបានទទួលនូវឯកសាររដ្ឋធម្មនុញ្ញនោះដែរឬទេ?

**ឆ៖** ខ្ញុំបានទទួលៗ ហើយសូមបញ្ជាក់ថា រដ្ឋធម្មនុញ្ញដែលយើងប្រើនៅក្នុង អ.វ.ត.ក បង្ហាញឲ្យខ្ញុំពន្យល់ គឺរដ្ឋធម្មនុញ្ញដែលយកបានពីស-២១។

**ស៖** ឯកសារ 9.2 គឺសូមបញ្ជូនទៅឲ្យ-- គឺឯកសារដែលមាន IS9.2 គឺជួយបញ្ជូនទៅឲ្យសាក្សី។ សាក្សី តើលោកអាចពិនិត្យទៅលើឯកសារបានដែរឬទេ? ហើយពិនិត្យមើលទៅលើឯកសារនោះ ព្រមទាំងពិនិត្យមើលថា តើលោកធ្លាប់ស្គាល់ឯកសារនេះដែរឬទេ? ហើយប្រសិនបើលោកធ្លាប់ស្គាល់ គឺយើងចង់ចោទសួរសំណួរមួយចំនួនទៅលោក ទាក់ទងទៅនឹងឯកសារនេះ។

[១៣:៤៣:០៥]

**ឆ៖** ខ្ញុំស្គាល់ឯកសារនេះ។ សូមអញ្ជើញ ព្រះរាជអាជ្ញាសួរមកចុះ!

**ស៖** អរគុណ។ ប្រសិនបើយើងមើលទៅមាត្រាទី៥ នៃរដ្ឋធម្មនុញ្ញ គឺវាបានចែងថា "អំណាចធ្វើច្បាប់ ជាអំណាចរបស់សភាតំណាងប្រជាជន កម្មករ កសិករ និងពលករកម្ពុជាផ្សេងទៀតទាំងអស់"។ តើលោកបានឃើញមាត្រានេះដែរឬទេ?

**ឆ៖** ខ្ញុំឃើញមាត្រានេះ។

**ស៖** មាត្រានេះបាននិយាយថា "សភានេះមានឈ្មោះជាផ្លូវការថា សភាតំណាងប្រជាជនកម្ពុជា" ហើយវាបានចែងបន្តទៀតថា "សភាតំណាងប្រជាជនកម្ពុជាមានសមាជិកទាំងអស់២៥០នាក់ តំណាងឲ្យប្រជាជន កម្មករ កសិករ និងពលករកម្ពុជាផ្សេងទៀត ហើយនិងតំណាងឲ្យកងទ័ពបដិវត្តន៍កម្ពុជា"។ ក្នុងនោះគឺ ក្នុងចំនួន២៥០នាក់ហ្នឹង គឺមានតំណាងកសិករ១៥០នាក់ តំណាងកម្មករ និងពលករផ្សេងទៀត៥០នាក់ និងតំណាងកងទ័ពបដិវត្តន៍៥០នាក់។

សំណួររបស់ខ្ញុំ គឺថាតាមការយល់ដឹងរបស់លោក នៅពេលនោះ តើមាន-- តើសភាតំណាងប្រជាជនកម្ពុជានោះ តើគេមានការបោះឆ្នោតដែរឬទេ? បានន័យថាមានការបោះឆ្នោតជ្រើសរើសតំណាង២៥០នាក់ នោះដែរឬទេ?

[១៣:៤៥:១១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ ដោយមានការតវ៉ាពីខាងមេធាវីការពារក្ដី។ សូមអញ្ជើញលោកមេធាវី!

[១៣:៤៥:២២]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ជាថ្មីម្ដងទៀតនោះ គឺព្រះរាជអាជ្ញាគាត់កំពុងតែចាត់ទុកថា អ្នកសាក្សីជាអ្នកជំនាញ ហើយគាត់គិតថា ហើយគាត់បាននិយាយថា ប៉ុល ពត ហាក់ដូចជាអ្នកសរសេរឬក៏គាត់តែងនេះ។ ប៉ុន្តែដូចជាមិនមានអ្នកណាបង្រៀនអំពីរដ្ឋធម្មនុញ្ញនេះឡើយ។ គាត់គ្រាន់តែនិយាយថា គាត់ឮតាមវិទ្យុតែប៉ុណ្ណោះ។ ដូច្នេះខ្ញុំមិនដឹងថា ខ្ញុំគិតថាសាក្សីប្រហែលជាមិនអាចនិយាយអ្វីឲ្យល្អឲ្យមានប្រយោជន៍ទាក់ទិនទៅនឹងឯកសារនេះទេ។ សូមអរគុណ។

**លោក វីណ្ឌៀម ស្មីត៖**

អរគុណលោកប្រធាន។ ខ្ញុំគិតថា ប្រសិនបើព្រះរាជអាជ្ញាអាចចោទសួរសាក្សីមួយចំនួន យើងអាចនឹងមើលឃើថា តើគាត់អាចផ្ដល់នូវព័ត៌មានសំខាន់ៗមួយចំនួនទាក់ទងនឹងឯកសារនេះ ឬក៏អត់? ឯកសារនេះ មិនមែនជាឯកសារដែលមានលក្ខណៈវិទ្យាសាស្ត្រអីនោះទេ វាជាឯកសារដែលមានលក្ខណៈធម្មតា ហើយសាក្សីគាត់រស់នៅក្នុងរបបនោះ គាត់បានសង្កេតឃើញ គាត់បានសិក្សាដឹង ហើយគាត់អាចយល់អំពីចំណុចទាក់ទងទៅនឹងនយោបាយរដ្ឋបាល។ ដូច្នេះ ខ្ញុំគិតសាក្សីរូបនេះអាចឆ្លើយនូវសំណួរជាមូលដ្ឋានមួយចំនួន ទាក់ទងទៅនឹងបញ្ញត្តិច្បាប់នៅក្នុងរដ្ឋធម្មនុញ្ញនេះ។ ហើយគាត់បាននិយាយថា គាត់បានទទួលនូវឯកសារធម្មនុញ្ញនេះ ហើយគាត់បានស្ដាប់តាមវិទ្យុ។ ដូច្នេះ គាត់មិនចាំបាច់ត្រូវជាអ្នកជំនាញនោះទេ ដើម្បីអាចឆ្លើយនូវសំណួរដែលចោទសួរអំពីឯកសារសាមញ្ញមួយនេះ។ សូមអរគុណលោកប្រធាន។

[១៣:៤៧:១២]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមិនយល់ថា ហេតុអ្វីថាក៏ព្រះរាជអាជ្ញាត្រូវផ្ដល់ឯកសារនេះទៅឲ្យនោះទេ ប្រសិនបើព្រះរាជអាជ្ញាចង់ចោទសួរសំណួរសាមញ្ញទៅលើសាក្សីនោះ។

ដូច្នេះ ប្រសិនបើគាត់ចង់ចោទសួរអំពីបទពិសោធន៍ អំពីការយល់ដឹងអី ដូច្នេះ គាត់ ព្រះរាជអាជ្ញាមិនគួរផ្ដល់ឯកសារទៅដល់សាក្សីទេ។ ព្រោះការផ្ដល់ឯកសារសាក្សីនោះ ហាក់ដូចជាឲ្យសាក្សីរំឭកនឹកឃើញឡើងវិញ។

[១៣:៤៧:៤០]

**លោក វីណ្ឌៀម ស្មីត៖**

ប្រសិនបើខ្ញុំអាច លោក លោកស្រីចៅក្រម ព្រោះថាឯកសារនេះ វាអាចជួយរំឭកទៅដល់ការចងចាំរបស់សាក្សី ហើយឯកសារនេះ គឺជាឯកសារដែលគាត់បានប្រើប្រាស់ បានសិក្សានៅក្នុងសម័យនោះ ព្រោះថានៅពេលនោះ គឺគាត់អាចនឹងដឹង គាត់អាចយល់ពីពាក្យមួយចំនួនដែលគាត់អាចជម្រាបមកអង្គជំនុំជម្រះបាន។ ហើយទីពីរ គឺយើងអាចចោទសួរសំណួរ ថាអ្នកណា? ពេលណា? ហេតុអ្វី? អីទីណាវិញ? ប៉ុន្តែខ្ញុំគិតថា ប្រសិនបើយើងចោទសួរបែបនេះ វាចំណាយពេលយូរ ព្រោះថាសាក្សីគាត់ដឹង គាត់ស្គាល់ គាត់យល់អំពីឯកសារនេះអស់ទៅហើយ។ ដូច្នេះហើយ គិតថាវាជាការចំណាយពេលឥត

ប្រយោជន៍ប្រសិនបើខ្ញុំត្រូវពន្យល់អំពីឯកសារនេះ ហើយទាញចូលទៅគ្រប់ចំណុចទាំងអស់នោះវិញ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៩:១៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ លោកតំណាងសហព្រះរាជអាជ្ញាអាចបន្តការសួរដេញដោលចំពោះសាក្សីរូបនេះ អំពីបញ្ហាពាក់ព័ន្ធទៅនឹងខ្លឹមសារនៃរដ្ឋធម្មនុញ្ញនេះតទៅទៀត។

**សួរដោយលោក វីណ្ស៉ៀម ស្មីត៖**

**ស៖** សាក្សី--

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាសម្រាកសិន មានការជំទាស់មួយផ្សេងទៀតហើយ។

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា។

[១៣:៥០:០៦]

**លោក សុន អរុណ៖**

សូមគោរពតុលាការ! អំមិញខ្ញុំឮលោកសាក្សីនេះ គាត់មុនដំបូងបំផុតព្រះរាជអាជ្ញាបានសួរគាត់ថាដែលឃើញរដ្ឋធម្មនុញ្ញហ្នឹងទេ? សាក្សីបានឆ្លើយថា អត់ដែលឃើញទេ។ សាក្សីបានឆ្លើយថា បានស្តាប់ឮតែតាម*វិទ្យុ* ហើយនិងអាយ៉ៃឆ្លងឆ្លើយ។ ហើយសួរស៊ីជម្រៅ មានន័យថាសាក្សីឆ្លើយអត់រួចទេ។ ហើយបើកាលណាសួរៗគឺចង់ដឹកនាំមុខសាក្សី សំណួរដឹកមុខ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ តើលោកដែលបានឃើញនូវរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យនេះទេ កាលពីលោករស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងពេលដែលលោកធ្វើជាប្រធាន ឬក៏លេខានៃមន្ទីរសន្តិសុខស-២១?

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឆ្លើយអំមិញជាមួយនឹងរដ្ឋអាជ្ញាអន្តរជាតិ ខ្ញុំឆ្លើយថា ឯកសារ

រដ្ឋធម្មនុញ្ញដែលយកមកបង្ហាញនេះ គឺយកចេញមកពីមកស-២១ តេ.អេស.អិល(TSL) ជាសញ្ញាស្រាប់។ ដូច្នេះបានន័យថាខ្ញុំឃើញហើយឯកសារនេះ។ ប្រតិចារឹកនៅ។ ហ្នឹងខ្ញុំសូមបញ្ជាក់ ជូនលោកប្រធានប៉ុណ្ណេះ។

[១៣:៥១:៣៦]

**ប្រធានអង្គជំនុំ៖**

បាទច្បាស់ហើយ ចង់បញ្ជាក់ដើម្បីឲ្យបានកាន់តែច្បាស់លើបញ្ហាការស្ដាប់ ពីព្រោះការរៀនបានន័យថារៀនសូត្រស៊ីជម្រៅលើបញ្ហាស្ដាប់ខទ្ទេសនាម អំពីរដ្ឋធម្មនុញ្ញនេះគឺទំនងជាមិនបានធ្វើទេ។ ប៉ុន្តែឯកសារនេះ គឺបានទទួល ហើយនិងបានដឹងស្គាល់ឯកសារហ្នឹងតាំងពីដើមមក ច្បាស់លាស់ហើយទៅលើចម្លើយ ក្រែងលោមានការភ័ន្តច្រឡំ។

សូមបន្តសំណួរលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សីប្រសិនបើលោកមើលទៅមាត្រាទី៦នៃរដ្ឋធម្មនុញ្ញ គឺបានចែងថា "សមាជិកសភាតំណាងប្រជាជនកម្ពុជា ត្រូវបានប្រជាជនជ្រើសតាំងឡើងដោយការបោះឆ្នោតទូទាំងប្រទេសដោយផ្ទាល់ និងដោយសម្ងាត់ក្នុងរយៈកាលប្រាំឆ្នាំម្ដង។ សំណួររបស់ខ្ញុំគឺថាតាមបទពិសោធន៍ និងការសង្កេតផ្ទាល់របស់លោកនៅក្នុងពេលនោះ បានន័យថានៅក្នុងគឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ តើលោកធ្លាប់ឮអំពីការបោះឆ្នោត ដើម្បីជ្រើសរើសតំណាងប្រជា-- តំណាងសភា-- ជ្រើសរើសសមាជិកសភាតំណាងប្រជាជនកម្ពុជាដែរឬទេ?

[១៣:៥៣:០៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមញែកបញ្ហានេះជាពីរ។ មណ្ឌលបោះឆ្នោតនៅភ្នំពេញមានតែមួយទេ នៅមុខស្ថានីយរាជាយស្វ័យយាន កន្លែងនុំង ជាមណ្ឌលបោះឆ្នោតរបស់ទួលគោក ខណ្ឌទួលគោក។ តំណាងរាស្ត្រដែលឈរនៅកន្លែងហ្នឹងគឺ បងនួន បងទីពីរហ្នឹងតែម្ដង។ ហើយអ្នកទៅបោះឆ្នោតបងហែម (ខៀវ សំផន), សីហនុ, ប៉ែន នុត នេះខ្ញុំដឹងច្បាស់។ ក្នុងការដែលកងទ័ពឃើញ ហើយនិង

និយាយតៗគ្នាមកឮដល់ខ្ញុំអ៊ីចឹង។ ឯចំណែកកន្លែងផ្សេងទៀត គ្មានការបោះឆ្នោតទេ។ ឧទាហរណ៍ ប្រពន្ធណាត, ណាត លេខាស-២១ នេះ, មិត្តគន្ធ គាត់ជាប្រធានរោងចក្រមួយ។ គាត់ជាសមាជិក អ៎! គាត់ជាតំណាងកម្មករ។ មិត្តសាយ គណៈកម្មាធិការឧស្សាហកម្ម ជាតំណាងកម្មករ។ មិត្តសោម ជំនួយការសេនាធិការ ជាតំណាងយោធា។ នេះខ្ញុំសូមរាប់រៀបប៉ុណ្ណេះ អំពីការបោះឆ្នោត និងមិនបោះឆ្នោត។

[១៣:៥៤:៣០]

**ស៖** តើមានការបោះឆ្នោតទូទាំងប្រទេសដែរឬទេ ក្នុងការជ្រើសរើសសភាតំណាងប្រជាជន? ប្រសិនបើតាមការដឹងរបស់លោក?

**ឆ៖** ខ្ញុំសូមនិយាយអំពីការដែលមេខ្ញុំ សុន សេន ប្រាប់ម្តង ដូចជានៅក្នុងស្ទីទេមិនដឹង គាត់ប្រាប់អំពីបរទេស។ គេថា អ្ហ៎! ពួកមិត្តបែបជាវរល់ណាស់ក្នុងរឿងបោះឆ្នោត ឯទៅតាមពិតយើងអត់វរល់អីទេ។ យើងអនុម័តយកទេ។ ដូច្នេះរឿងនេះវាបញ្ជាក់ច្បាស់ហើយ ពីការបរទេសគេយល់ច្រឡំថា កម្ពុជាវរល់នឹងការបោះឆ្នោត ឯចំណែករឿងពិត គឺយើងអត់មានវរល់ទេ។ យើងអនុម័តយក។ នេះគឺរឿងពិត។

**ស៖** សូមអរគុណ។ តើលោកដឹងទេថា នៅក្នុងមាត្រាទី៧ ដែលបានចែងថា សភាតំណាងប្រជាជនមានភារកិច្ចសម្រេចច្បាប់ និងកំណត់មាគ៌ានយោបាយផ្សេងៗ ក្នុងប្រទេស និងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ។ តើលោកដឹងទេថា តើមានសភាដែលមានភារៈសម្រេចច្បាប់សម្រាប់កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១៣:៥៦:១០]

**ឆ៖** សភាតំណាងប្រជាជនកម្ពុជា ជាស្ថាប័នឧបកិច្ចមានតែឈ្មោះ គ្មានអង្គភាព គ្មានសកម្មភាព។ បានជាខ្ញុំនិយាយថា គ្មានសកម្មភាព ក្រោយពីរៀបចំដែលគេហៅថា បោះឆ្នោតហើយនោះ នួន ជា ដឹកនាំប្រជុំបានម្តង សមាជិកអចិន្ត្រៃយ៍ ដែល ប៉ុល ពត រើសបន្ថែមមានប្រហែល១០នាក់មែន ក៏ប៉ុន្តែស្ងូត្រតែសុន្ទរកថាហ្នឹងបានតែម្តង ក្រោយពីនោះមក សភាតំណាងប្រជាជនកម្ពុជាហ្នឹងបិទតែស្លាកនៅនឹងមាត់ទន្លេទ្នុំង អត់មានអ្នកណាទៅប្រជុំ អត់មានអ្នកណាទៅស្ទីទេ។ តំណាងទាំងអស់នៅក្នុងអង្គភាពរបស់ខ្លួន ហើយតំណាងទាំងអស់ហ្នឹង យូរៗត្រូវគេចាប់យកមកស-២១ ជាហូរហែ។ អ្នកដែលចាប់មកមុនគេនោះគឺ វេត នៅខាងកសិកម្ម។ អរគុណ។

**ស៖** តើលោកដឹងទេថា ហេតុអ្វីក៏សមាជិកទាំងអស់នេះត្រូវបានគេចាប់ ហើយបញ្ជូនមក ស-២១?

**ឆ៖** សមាជិកទាំងអស់របស់សភាតំណាងប្រជាជន វាជាបក្ខជន ដូច្នេះខុស ឬត្រូវបក្ស សម្រេចនៅក្នុងក្របខ័ណ្ឌបក្សបញ្ជូនមកស-២១។

[១៣:៥៨:០៨]

**ស៖** ប្រសិនបើខ្ញុំឲ្យលោកពិនិត្យទៅលើមាត្រា៩ គឺវាបានចែងថា តុលាការ ជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរី ប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាព ដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន។ តើមានការបង្កើតតុលាការរបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ បើតាមលោកដឹង?

**ឆ៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សហករណ៍វាប្រមូលផ្តុំអំណាចពីរ គឺអំណាចតុលាការផង និងអំណាចនីតិប្រតិបត្តិផង។

**ស៖** ពាក់ព័ន្ធទៅនឹងមាត្រា៩ គឺបាននិយាយថា តុលាការគ្រប់ជាន់ថ្នាក់ត្រូវសភាតំណាងប្រជាជនជ្រើសរើស និងតែងតាំង តើមានដែរឬទេតាមលោកដឹង?

**ឆ៖** គ្មានទេ មានតែគណៈកម្មាធិការបក្សគ្រប់ថ្នាក់ រៀបចំដោយបក្ស។ គណៈកម្មាធិការបក្សថ្នាក់សហករណ៍ គណៈកម្មាធិការបក្សថ្នាក់ស្រុក គណៈកម្មាធិការបក្សថ្នាក់តំបន់ រៀបចំដោយបក្ស។

[១៤:០០:០៧]

**ស៖** ប្រព័ន្ធតុលាការដែលលោកទើបតែបានរៀបរាប់អម្បាញ់មិញនេះ តើនរណាគេជាអ្នកគ្រប់គ្រងប្រព័ន្ធតុលាការ ដំណើរការតុលាការដូចដែលលោកបានរៀបរាប់នេះ?

**ឆ៖** ខ្ញុំបានពន្យល់-- ខ្ញុំបានបញ្ជាក់អម្បាញ់មិញថា នៅក្នុងគណៈកម្មាធិការបក្សថ្នាក់មូលដ្ឋានវាប្រមូលផ្តុំអំណាចពីរ។ អំណាចនីតិប្រតិបត្តិផង និងអំណាចតុលាការផង។ ដូច្នេះ នៅក្នុងសហករណ៍មួយ ឬឃុំមួយ ហៅថាឃុំមួយ អំណាចទាំងពីរហ្នឹងវានៅក្នុងកណ្តាប់ដៃគណៈកម្មាធិការបក្សសហករណ៍។ ដូច្នេះវាអត់មាននេះទេ។ វានៅបក្ស ហើយនិង-- បក្សគឺវាកាន់ក្តាប់អំណាចពីរហ្នឹង។ នីតិប្រតិបត្តិ និងនីតិតុលាការ។ ហ្នឹងអំណាចតុលាការ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលមាត្រា១១ និយាយអំពីគណៈប្រធានរដ្ឋ។ នៅក្នុងនេះ

ថែងថា កម្ពុជាប្រជាធិបតេយ្យមានគណៈប្រធានរដ្ឋមួយ ជ្រើសរើស និងតែងតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជាក្នុងរយៈកាល៥ឆ្នាំម្តង។ ថាតើមានការជ្រើសរើសគណៈប្រធានរដ្ឋដែរឬទេ?

[១៤:០១:៥៤]

**ផ៖** អរគុណ។ គណៈប្រធានរដ្ឋនេះ ក៏នៅតែជាស្ថាប័នឧបកិច្ច។ សកម្មភាពស្មើរតែថាអត់អង្គភាពជាគោលការណ៍មានបីនាក់ គឺ ខៀវ សំផន ប្រធាន ប៉ែន នុត អនុប្រធាន ហើយនិង រស់ ញឹម សមាជិក។ រស់ ញឹម គាត់នៅធ្វើលេខាភូមិភាគពាយព្យតែគាត់ទៅ។ ប៉ែន នុត លោកតា ប៉ែន នុត ចាស់ណាស់ហើយ។ គេយកគាត់ទៅទុកនៅផ្ទះមួយខាងកើតវិទ្យាឌុកទ័រ ម៉ី សាមីឌី នេះ។ ហើយយូរៗ ខៀវ សំផន ទៅអើតគាត់ម្តង។ នេះគ្មានសកម្មភាពទេ។ សន្មតហៅថាគ្មានសកម្មភាព។ ដូច្នេះគណៈប្រធានរដ្ឋ ខ្ញុំសូមនិយាយឡើងវិញ ជាស្ថាប័នឧបកិច្ច គ្មានអង្គភាព គ្មានការិយាល័យ គ្មានសកម្មភាព។

**ស៖** លោកបានលើកឡើងឈ្មោះ រស់ ញឹម ដែលជាបុគ្គលម្នាក់ដែលគេឧបកិច្ចផងដែរ។ រស់ ញឹម នេះជានរណាដែរ? មានអ្វីកើតឡើងចំពោះគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ ដោយមានការតវ៉ាពីមេធាវីការពារក្តី។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ យើងបានពិភាក្សាចំណុចនេះពីមុនរួចមកហើយ សាក្សីកាលពីមុនបានផ្តល់មតិយោបល់អំពីបញ្ហាគណៈប្រធានរដ្ឋ។ យើងខ្ញុំបានស្នើសុំសហព្រះរាជអាជ្ញា ឲ្យសួរបន្តបានទៅលើសាក្សី ថាតើប្រភពព័ត៌មានបានមកពីណា? ហើយសហព្រះរាជអាជ្ញាសន្យាថានឹងសួរដេញព័ត៌មានទាំងអស់នេះ។ ខ្ញុំមិនដឹងថាតើសាក្សីរូបនេះ គឺគាត់មិនដឹងព័ត៌មាននេះពីរបៀបណា? ហើយហេតុអ្វីបានជាគាត់ដឹង?

ដូច្នេះថាតើការដឹងទាំងអស់នេះ បានតាមរយៈចម្លើយសារភាពនៅស-២១ ឬក៏យ៉ាងណា? ប្រសិនបើអ៊ីចឹងមែន យើងអាចនិយាយថា សាក្សីរូបនេះ កំពុងតែយកព័ត៌មានទាំងឡាយដែលទំនងជាទទួលបានក្រោមការធ្វើទារុណកម្ម។ ដូច្នេះហើយគួរតែឲ្យសហព្រះរាជអាជ្ញានោះ បញ្ជាក់-- សួរបញ្ជាក់ដែរថា ព័ត៌មាននេះគាត់ដឹងតាមរយៈណា? ហើយប្រសិនបើព័ត៌មាននេះចេញតាមរយៈចម្លើយសារភាពមែន គួរតែដកចេញមិនអាចសួរបានទេ។

E1/54.1

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:០៥:00]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំគិតថា គោលបំណងនៃការដេញដោលនោះ គឺយើងមិនមែនចង់សួរទៅលើចំណុចនេះទេ។ ហើយចំពោះសំណួរដេញបន្តនោះ យើងខ្ញុំនឹងសួរ។ ខ្ញុំចង់សូមសួរ--

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកមេធាវីអន្តរជាតិការពារក្តី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ ដែលឱ្យខ្ញុំធ្វើការឆ្លើយតប។ វាហាក់ដូចជាងាយពេក សហព្រះរាជអាជ្ញាកំពុងតែដឹកមុខសាក្សី។ ហើយយើងគួរតែឱ្យសហព្រះរាជអាជ្ញាគោរពតាមវិជ្ជាជីវៈរបស់ខ្លួនឱ្យបានត្រឹមត្រូវ ហើយមិនអាចឱ្យសាក្សីធ្វើសម្មតិកម្ម ធ្វើការស្មាន ហើយថាព័ត៌មាននោះ ទទួលបានតាមចម្លើយសារភាពនោះទេ។ ដូច្នេះហើយ យើងគួរតែឱ្យសហព្រះរាជអាជ្ញាគោរពទៅតាម-- ឱ្យបានត្រឹមត្រូវទៅតាមវិជ្ជាជីវៈ ដើម្បីអនុវត្តនៅក្នុងការដេញដោលនីតិវិធីនៅទីនេះ។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគិតថា ប្រហែលជាមិនមានមូលដ្ឋានណាមួយ យើងឃើញថាសាក្សីនេះ កំពុងតែទាយស្មានសន្និតនៅក្នុងនោះទេ។ ហើយគឺយើងហាក់ដូចជាឃើញថា គាត់នុំង មិនមែនយកព័ត៌មានទាំងអស់នេះមកពីចម្លើយសារភាពនោះទេ។ ដូច្នេះហើយខ្ញុំមិនដឹងថា មេធាវីនោះ គាត់ផ្អែកការជំទាស់របស់គាត់ត្រង់ចំណុចនេះ ដោយរបៀបនោះទេ។ តែយ៉ាងណាក៏ដោយ យើងនឹងសួរថាតើគាត់ដឹងមកពីណាចំពោះចំណុចហ្នឹង? យ៉ាងណាក៏ដោយ ខ្ញុំមិនចង់ឱ្យមេធាវីការពារក្តីក្រោកឈរឡើងជំទាស់ ថាខ្ញុំមិនគួរសួរសំណួរនេះ គួរតែសំណួរផ្សេងនោះទេ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនឹងសុំសួរសាក្សីអំពីប្រភពព័ត៌មានដែលគាត់ទទួលបានពី-- តាមរយៈណា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ ព្រះរាជអាជ្ញាអាចតាំងសំណួរបានចំពោះសាក្សីរូបនេះជាបន្ត។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** រស់ ញឹម លោកបាននិយាយ ថាគាត់ជាសមាជិកមួយរូបនៅក្នុងគណៈប្រធានរដ្ឋ ហើយជាឧបកិច្ចតែប៉ុណ្ណោះ។ តើលោកអាចជម្រាបជូនតុលាការ តើគាត់ជានរណាដែរ? ហើយមានអ្វីកើតឡើងចំពោះគាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** រស់ ញឹម ជាលេខាគណៈកម្មាធិការភូមិភាគពាយព្យ។ ក្រោយមក គាត់ត្រូវចាប់ខ្លួនមក ស-២១ ដោយសារមានចម្លើយឆ្លើយដាក់។

[១៤:០៨:១៩]

**ស៖** សំណួរបន្ទាប់ ដែលខ្ញុំចង់សួរនោះ គឺពាក់ព័ន្ធទៅនឹងមាត្រា១២ ដែលទាក់ទងទៅនឹងសិទ្ធិ និងករណីយកិច្ចរបស់ប្រជាជនកម្ពុជាម្នាក់ៗ។ ក្នុងមាត្រានេះចែងថា ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជីវភាពពេញទីខាងសម្ភារៈ ខាងស្មារតី និងខាងវប្បធម៌។ ហើយប្រសិនបើយើងមើលមាត្រា១៣វិញ ចែងថា ត្រូវមានសមភាពពេញទីរវាងប្រជាជនកម្ពុជាទាំងអស់ ក្នុងសង្គមកម្ពុជាមួយស្មើភាព យុត្តិធម៌ ប្រជាធិបតេយ្យ សុខដុមរមនា មានសុភមង្គលក្នុងមហាសាមគ្គីជាតិទាំងមូល ដើម្បីការពារប្រទេស និងកសាងប្រទេសទាំងអស់គ្នា។ ខ្ញុំចង់សូមសួរលោក ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ថាតើសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងមាត្រា១២ និង១៣ មានការគោរពសិទ្ធិទាំងអស់នេះដែរឬទេ ចំពោះបុគ្គលម្នាក់ៗនោះ?

[១៤:១០:១២]

**ឆ៖** មាត្រា១៣ ត្រូវមានសមាភាពពេញទីរវាងប្រជាជនកម្ពុជាទាំងអស់ក្នុងសង្គមកម្ពុជាមួយស្មើភាព យុត្តិធម៌ ប្រជាធិបតេយ្យ សុខដុមរមនា មានសុភមង្គលក្នុងមហាសាមគ្គីជាតិទាំងមូល ដើម្បីការពារប្រទេស និងកសាងប្រទេសទាំងអស់គ្នា។ បុរស និងនារីស្មើភាពគ្នាពេញទីលើគ្រប់វិស័យទាំងអស់ មិនអនុញ្ញាតឲ្យមានប្រពន្ធច្រើន និងប្តីច្រើនឡើយ។ ត្រូវមានសភាពពេញទីរវាងប្រជាជនកម្ពុជាទាំងអស់។ បញ្ហានេះវាមានលក្ខណៈជាទ្រឹស្តីជាង សូមលើកឧទាហរណ៍ផ្ទុយមួយ ហើយដែលមានជាជាក់ស្តែងហូរហែក្នុងសង្គមកម្ពុជា ប្រជាជនថ្មី ឬក៏ប្រជាជន១៧ មេសា ត្រូវស្ថិតនៅក្រោមការ

គ្រប់គ្រងរបស់ប្រជាជនចាស់ ដូច្នេះវាអត់ស្មើភាពរួចទៅហើយ។ វាអត់ស្មើភាពរួចទៅហើយ ដូច្នេះខ្ញុំសូមលើកអំពីការមិនស្មើភាពត្រឹមប៉ុណ្ណេះជូន។

**ស៖** ចាតើមានលក្ខណៈប្រជាធិបតេយ្យ គេអនុវត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរឬទេ?

[១៤:១២:១២]

**ឆ៖** បញ្ញត្តិប្រជាធិបតេយ្យនេះឲ្យនិយមន័យទៅតាមមេគំនិតនយោបាយ ប្រជាធិបតេយ្យនៅកម្ពុជា គេហៅថា "ប្រជាធិបតេយ្យសង្គមនិយម" អនុវត្តផ្តាច់ការបដិវត្តន៍ គឺធ្វើម៉េចកុំឲ្យខូចផលប្រយោជន៍វណ្ណៈកម្មករ និងកសិករ។ នេះប្រជាធិបតេយ្យដែល ប៉ុល ពត លើកឡើង ហើយដាក់ចេញឲ្យអនុវត្ត។

**ស៖** សូមអរគុណ។ លោកបានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងរដ្ឋ ដូច្នេះនៅពេលនេះ ខ្ញុំសុំឲ្យពិនិត្យមើលថាតើកម្ពុជា-- បក្សកុម្មុយនីស្តកម្ពុជានេះគ្រប់គ្រងរដ្ឋដោយរបៀបណា? ខាងដើមលោកបាននិយាយអំពីគណៈមជ្ឈិម ដែលជាគណៈកម្មាធិការខ្ពស់បំផុតនៅក្នុងបក្ស តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** គណៈកម្មាធិការមជ្ឈិម បើសិនជាយើងឲ្យន័យថា ជាអង្គការខ្ពស់បំផុតនៅក្នុងបក្សមិនខុសទេ។

[១៤:១៤:១៧]

**ស៖** ប្រសិនបើខ្ញុំឲ្យលោកមើលលក្ខន្តិកៈម្តងទៀត គឺ IS9.1 សូមឲ្យបញ្ចាំងនៅលើអេក្រង់។ លោកសាក្សី តើលោកមានឯកសារហ្នឹងមួយច្បាប់នៅចំពោះមុខលោកដែរឬទេ គឺលក្ខន្តិកៈ? ប្រសិនបើលោកមើលលើមាត្រា២៣ នៃលក្ខន្តិកៈ ហើយខ្ញុំសុំឲ្យលោកអានមាត្រា២៣នោះ បន្ទាប់មកខ្ញុំនឹងសួរលោក ថាតើមាត្រា២៣នោះ មានន័យយ៉ាងម៉េច យោងតាមលក្ខន្តិកៈ? សូមឲ្យលោកអាន។

**ឆ៖** អរគុណ។ មាត្រា២៣៖ "ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម។ ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម គឺអនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទាំងមូល។ ២) ណែនាំអង្គការភូមិភាគ តំបន់ ស្រុកទាំងអស់ និងអង្គការបក្ស។ ទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំង តាមភារកិច្ចការពារប្រទេស និងការកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និង

ការកសាងសង្គមនិយមរបស់បក្ស។ ៣) គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនទាំងមូលព្រមទាំងអង្គការស្នូលទាំងអស់ ដោយក្ដាប់ប្រវត្តិរូប ជំហរនយោបាយសតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់ និងឲ្យជាប់ជានិច្ច ហើយអប់រំបំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច។ ៤) តាងនាមបក្ស ក្នុងការទាក់ទងបណ្ដាបក្សម៉ាក្ស-ឡេនីន ជាបងប្អូន"។ ចប់ សូមចប់។

[១៤:១៧:១៥]

**ស៖** តើលោកដឹងទេ តើគណៈកម្មាធិការមជ្ឈិមនោះមានសមាជិកទាំងមូលមានចំនួនប៉ុន្មានដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អង្គការមជ្ឈិមបក្សមានបួនថ្នាក់។ ថ្នាក់ទាបជាងគេ ១ហៅថាជំនួយការមជ្ឈិម។ ពួកនេះមានសិទ្ធិចូលទៅរៀនជាមួយនឹងគេ តែគ្មានសិទ្ធិបញ្ចេញមតិ គ្មានសិទ្ធិបោះឆ្នោតសម្រេចស្អីទេ។ ខ្ពស់ជាងនោះមួយបន្តិច គេហៅថា "មជ្ឈិមត្រៀម"។ ពួកនេះមានសិទ្ធិរៀនជាមួយនឹងគេផង ហើយក៏មានសិទ្ធិបញ្ចេញមតិ តែគ្មានសិទ្ធិបោះឆ្នោតសម្រេចស្អីទេ។ ដល់កាលណាមជ្ឈិមពេញសិទ្ធិបានគេមានសិទ្ធិបោះឆ្នោតសម្រេច។ ឯចំណែកខ្ពស់ជាងនោះទៅទៀត គេហៅថា "អចិន្ត្រៃយ៍មជ្ឈិម"។ អចិន្ត្រៃយ៍មជ្ឈិមនេះ ចំនួនខ្ញុំដឹងច្បាស់ ខ្ញុំវាយការណ៍ហូរហែរួចមកហើយ មានប្រាំពីររូប។ គឺបងទីមួយ ប៉ុល ពត លេខា, បងទីពីរ នួន ជា អនុលេខាទីមួយ, សោ ភឹម អនុលេខាទីពីរ, អ៊ុង ជឿន ហៅ ម៉ុក អនុលេខាទីបី ហើយ អៀង សារី សមាជិកមជ្ឈិមពេញសិទ្ធិ, សុន សេន សមាជិកមជ្ឈិមត្រៀម (សូមទោស) វន វ៉េត មកមុន វន វ៉េត សមាជិកមជ្ឈិមត្រៀម ហើយនិង សុន សេន ចុងក្រោយគេសមាជិកមជ្ឈិមត្រៀមទាំងអស់ប្រាំពីរនាក់ហ្នឹង។ ដូច្នេះខ្ញុំដឹងតែប៉ុណ្ណឹងច្បាស់ ឯចំណែកអ្នកផ្សេងទៀតខ្ញុំក្ដាប់មិនបានច្បាស់ទេ មិនដឹងជាចំនួនប៉ុន្មាន ប៉ុន្តែលើសមួយរយមើលទៅ។

[១៤:១៩:៣៣]

**ស៖** ខ្ញុំគិតថា ប្រហែលជាបញ្ហាបកប្រែ នៅពេលដែលយើងកត់ត្រាសមាជិកគណៈអចិន្ត្រៃយ៍ គឺខ្ញុំកត់បានតែប្រាំមួយនាក់តែប៉ុណ្ណោះ។ ហើយខ្ញុំអាចអានឈ្មោះទាំងប្រាំមួយនោះជូនលោកឡើងវិញ។ គឺ ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី, សុន សេន និង វន វ៉េត។ តើមានប្រាំពីរ ឬក៏ប្រាំមួយ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ឡើងវិញ ពួកនេះគោរពគ្នាតាមលំដាប់។ ដូច្នេះ ខ្ញុំសូមរាប់តាមលំដាប់ឲ្យបានត្រឹមត្រូវ។ ១) ប៉ុល ពត ២) នួន ជា ៣) សោ ភឹម ៤) អ៊ុង ជឿន ហៅ ម៉ុក។

លោកព្រះរាជអាជ្ញាគាត់រំលង អ៊ុង ជឿន ហៅ ម៉ុក។ បន្ទាប់ពី អ៊ុង ជឿន ហៅ ម៉ុក មក

 

អៀង សារី។ បន្ទាប់ពី អៀង សារី មកមាន វន វ៉េត សិន។ បានចុងបំផុតមាន សុន សេន។

[១៤:២០:៥៤]

**ស៖** សូមអរគុណ។ តើលោកដឹងដោយរបៀបណា ថាអ្នកណាម្នាក់ជាសមាជិកអចិន្ត្រៃយ៍នោះ?

**ឆ៖** អរគុណនឹងសំណួរនេះ។ ណាត ជាមនុស្សម្នាក់ដែលចង់បានចូលមជ្ឈិមនឹងគេខ្លាំងណាស់។ ម្ល៉ោះហើយគាត់ដើរសួរ។ ណាត គាត់ដឹង គាត់ប្រាប់ខ្ញុំមុន។ មានលំដាប់លំដោយទាំងអស់បែបនេះ។ បន្ទាប់មកខ្ញុំសួរ កុយ ធួន ហើយសុំបញ្ជាក់ថា កុយ ធួន ជាអ្នកទោសម្នាក់ដែលខ្ញុំមិនដែលបានវ៉ៃ។ បន្ទាប់មកទៀតជួប ឈឹម សំអោក ហៅ ប៉ង់ ដែលជាអ្នកនាំពាក្យរបស់ ប៉ុល ពត ទៅស-២១ហ្នឹង ហើយ ប៉ង់ នេះជាសមាជិកមជ្ឈិមម្នាក់។ ខ្ញុំសួរទៅច្បាស់ ឆ្លើយដូចគ្នាអ៊ីចឹង។ ទន្ទឹមនេះ ខ្ញុំនៅពេលដែល ប៉ុល-- អឺនែ៎! សុន សេន គាត់ឲ្យខ្ញុំសរុបឯកសារដែលគេឆ្លើយដាក់ សួស នៅ ហៅ ឈូក។ ខ្ញុំធ្វើឯកសារជាប្រាំពីរដុំជូនគាត់។ គាត់អត់មាត់ទេ គាត់ទទួល គាត់ប្រាប់ខ្ញុំថា ឌុច អ្នក! បងៗជិតប្រជុំគ្នាហើយ មិត្តរៀបចំឯកសារដែលគេឆ្លើយដាក់ មិត្តឈូក ប៉ុន្មានមកឲ្យខ្ញុំ។ ខ្ញុំធ្វើជាប្រាំពីរដុំជូនគាត់ ដូច្នេះគាត់អត់មាត់ទេ។ សរុបមក រឿងដែលខ្ញុំបានឆ្លើយប៉ុណ្ណេះ គឺមកពីខ្ញុំឆ្លងកាត់ការសាកសួរបែបនេះ ហើយនិងធ្លាប់ជួបពិសោធន៍បែបនេះ។

[១៤:២២:៤៨]

**ស៖** ហេតុអ្វីបានគេៗឲ្យលោករៀបចំចម្លើយសារភាពទាំងប្រាំពីរនោះ?

**ឆ៖** អត់ទោសៗ លោកព្រះរាជអាជ្ញាអាចស្តាប់ខ្ញុំមិនចំបញ្ហាទេ។ មេខ្ញុំបញ្ជាតាមទូរស័ព្ទមកថា “ឌុច អ្នក! បងៗជិតប្រជុំគ្នាហើយ ដើម្បីសម្រេចពីករណី មិត្តឈូក គឺលេខាតំបន់លេខា២៤ហ្នឹង ឈ្មោះដើម សួស នៅ ហៅ ឈូក”។ ខ្ញុំដឹង ទទួលបាន ខ្ញុំអត់ងងុយបីយប់ បីថ្ងៃតគ្នារៀបចំឯកសារហ្នឹងជាប្រាំពីរដុំៗហ្នឹង គំនិតផ្តើមរបស់ខ្ញុំទេ ដើម្បីចង់ដឹងថា តើមេគាត់ថាម៉េច? គាត់អត់ថាម៉េច គាត់ទទួល។

**ស៖** លោកនិយាយខាងថាដើមថា លោកត្រូវរៀបចម្លើយនោះប្រាំពីរដុំ ហើយនៅពេលនេះលោកបានលើកឡើងថា សុន សេន ជាអ្នកឲ្យលោករៀបចំឯកសារមួយចំនួនសម្រាប់បងៗ ហើយលោកនិយាយឯកសារបីដុំខុសគ្នា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយនូវសំណួរនេះ។ សូមអញ្ជើញលោកមេធាវី!

[១៤:២៤:២៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ជាបឋមចំណុចតូចទេ ក៏ប៉ុន្តែសំខាន់។ សាក្សីទើបតែនិយាយថា គាត់ដឹងសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍ ដោយសារតែក្នុងនោះ គាត់ដឹងថាមានពីរនាក់ ដែលនៅបានផ្តល់ព័ត៌មានទៅដល់គាត់ក្នុងស្ថានភាពមួយមានការគាបសង្កត់។ សហព្រះរាជអាជ្ញាបានលើកឡើងពីរដង ដែលពាក់ព័ន្ធទៅនឹង-- សហព្រះរាជអាជ្ញាបានសួរពីរដងពាក់ព័ន្ធទៅនឹង គេឱ្យសាក្សីបង្កើតឯកសារប្រាំពីរដុំ ហើយបន្ទាប់មកគឺ គាត់លើកឡើងថា សុន សេន បានប្រាប់គាត់ឱ្យរៀបចំឯកសារដោយសារតែសម្រាប់-- ឯកសារនោះសម្រាប់បងៗ។

**លោក វីល្លៀម ស្មីត៖**

ជាបឋម កុយ ធួន គឺត្រូវបានគេឃុំនៅស-២១ ដូចដែលសាក្សីបានលើកឡើងគ្មានការធ្វើទារុណកម្មទៅដល់ កុយ ធួន ទេ។ ចំណុចទីពីរ ហេង គឺ គាត់បានលើកឡើងថា គាត់ទទួលព័ត៌មានពី ប៉ង់, ឈឹម សំអោក ហៅ ប៉ង់ ដែលគាត់ធ្វើការនៅស-២១។ នៅ-- ដូច្នេះប្រសិនបើខ្ញុំសូមបញ្ជាក់ឱ្យអស់មន្ទិលសង្ស័យចំណុចហ្នឹងជាមួយនឹងសាក្សី ហើយសួរសំណួរទៅដល់សាក្សីថា នៅពេលដែល ប៉ង់ ផ្តល់ព័ត៌មានទៅដល់សាក្សី ថាតើនរណាគេជាសមាជិកគណៈអចិន្ត្រៃយ៍នោះ ខ្ញុំនឹងសួរសាក្សីថា តើ ប៉ង់ នោះជាអ្នកជាប់ឃុំនៅស-២១ ឬក៏នៅពេលនោះគាត់ជាតំណាងរបស់ខាងមជ្ឈិម? មានការយល់ច្រឡំគ្នាបន្តិចទាក់ទងទៅនឹងការរៀបចំឯកសារប្រាំពីរដុំ ហើយបន្ទាប់មកលើកឡើងថា មានឯកសារបីដុំទៀត។ ដូច្នេះហើយខ្ញុំចង់សួរបញ្ជាក់ទៅលើចំណុចទាំងអស់នេះឱ្យបានច្បាស់លាស់ ប្រសិនបើអនុញ្ញាតខ្ញុំសូមសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះអនុញ្ញាត។ សូមបន្តសំណួរ!

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** នៅពេលដែល ប៉ង់ ប្រាប់លោកអំពីសមាជិកទាំងប្រាំពីរនៅក្នុងគណៈអចិន្ត្រៃយ៍ថា ជានរណាខ្លះនោះ ថាតើ ប៉ង់ គាត់ធ្វើការឱ្យបក្សនៅពេលនោះ ឬក៏គាត់ហ្នឹងជាអ្នកជាប់ឃុំ ពេលដែលគាត់ប្រាប់លោកហ្នឹង?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណដែលបានបញ្ជាក់បញ្ហានេះឲ្យខ្ញុំ។ មុននឹងបក្សសម្រេចចាប់ ប៉ង់ ខ្ញុំហើយនិង ប៉ង់ បានប្តូរមតិយោបល់គ្នាច្រើនណាស់។ ដូច្នេះករណីអចិន្ត្រៃយ៍មជ្ឈិមបក្សនេះ ខ្ញុំសួរនៅពេលដែល ប៉ង់ មានសេរីភាពចុះមកស-២១ ក្នុងឋានៈជាអ្នកនាំពាក្យ ប៉ុល ពត មកបញ្ជាស-២១។ ជាមនុស្សគេមាន សិទ្ធិពេញបរិបូរ។

[១៤:២៨:០០]

**ស៖** ពាក់ព័ន្ធទៅនឹងឯកសារ លោកលើកឡើងថា លោករៀបចំប្រាំពីរដុំ។ គេសុំឲ្យលោក រៀបចំចំនួនប្រាំពីរដុំ ឬក៏លោករៀបចំឯកសារប្រាំពីរដុំនោះតាមការនឹកឃើញរបស់ខ្លួន?

**ឆ៖** អរគុណ។ អរគុណការដែលបានសួរបញ្ជាក់ខ្ញុំបញ្ហានេះឡើងវិញ។ រឿងនេះយើងស្តាប់ គ្នាមិនបាន។ ខ្ញុំមើលទៅមូលហេតុបក-- បកប្រែក៏មិនដឹង។ ខ្ញុំសូមបញ្ជាក់ថា ដំបូង សុន សេន គាត់ បញ្ជាខ្ញុំ គាត់ថា “ឌុច បងៗជិតប្រជុំគ្នាហើយ មិត្តរៀបចំឯកសារដែលទាក់ទងនឹងមិត្តឈូក ឲ្យខ្ញុំ”។ គាត់បញ្ជាប៉ុននុ៎ង។ អត់បញ្ជាថាប៉ុន្មានដុំៗទេ។ ខ្ញុំក៏រៀបចំទាំងប្រាំពីរដុំ ៗចំនួនប្រាំពីរដុំផ្ញើទៅឲ្យគាត់។ គាត់នៅស្ងៀម មិនមានមតិអី។ ដូច្នេះពិសោធន៍ហ្នឹងធ្វើឲ្យខ្ញុំជឿថា អចិន្ត្រៃយ៍មជ្ឈិមបក្សមានប្រាំពីរនាក់ មែន។ នេះខ្ញុំសូមបញ្ជាក់ឡើងវិញប៉ុណ្ណេះ។

[១៤:២៩:២៦]

**ស៖** លោករៀបចំប្រាំពីរដុំ ដោយសារគេប្រាប់លោកថា សមាជិក ដោយសារតែ ប៉ង់ ជាអ្នក ប្រាប់លោកថា នៅក្នុងអចិន្ត្រៃយ៍មានប្រាំពីរនាក់។ មែនដែរឬទេ ទើបលោករៀបចំប្រាំពីរដុំដូច្នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ ដោយសារមានការតវ៉ាពីមេធាវី។ សូមអញ្ជើញ!

**លោក ម៉ៃខល ការណាវាស៖**

លោកប្រធានជាទីគោរព! ខ្ញុំគិតថាវិធី យើងគួរតែអនុវត្តវិធីសមស្របមួយនៅក្នុងការសួរ សំណួរ។ នេះជាការនាំមុខហើយ ហើយប្រសិនបើសាក្សីនោះ គាត់ដឹងព័ត៌មាននោះដោយខ្លួនឯង មិន បាច់ចាំដឹកមុខសាក្សីនោះទេ គឺសាក្សីហ្នឹងគាត់សន្មត គាត់សន្និដ្ឋានថា មានប្រាំពីរនាក់ ហើយបន្ទាប់មក យើងឃើញថា សហព្រះរាជអាជ្ញាសួរសំណួរដដែល។ ដូច្នេះ ហាក់ដូចជាសំណួរនេះ នាំមុខរួចទៅ ហើយ។ យើងដឹងហើយថា អ្វីខ្លះដែលសាក្សីបានដឹង ហើយអ្វីដែលយកពាក្យហ្នឹង ញ៉ុកឲ្យ-- លើកឡើង

ឱ្យសាក្សីនេះបញ្ជាក់ឆ្លើយតប។ ដូច្នេះហើយ ខ្ញុំសុំឱ្យសហព្រះរាជអាជ្ញាសួរមួយដំណាក់កាលម្តងៗ ថាតើសាក្សីដឹងដែរឬទេ ហើយប្រសិនបើខ្លាចអស់ពេលនោះអាចសុំពេលថែមបាន។ ហើយយើងមិនអាចឱ្យសហព្រះរាជអាជ្ញា លើកឡើងថា វានឹងចំណាយពេលច្រើនណាស់នៅក្នុងការសួរ។ ដូច្នេះហើយ ជួយដល់សាក្សី ដឹកមុខសាក្សីតែម្តង។

[១៤:៣០:៥៥]

សហព្រះរាជអាជ្ញាបានពន្យល់ជូនអង្គជំនុំជម្រះរួចមកហើយ ហើយគាត់សុំថាប្រសិនបើយើងដឹងថា មុនពេល ឬក៏ក្រោយពេល ដូច្នេះប្រសិនបើសួរអ៊ីចឹង គឺដឹងច្បាស់ទាំងអស់គ្នា។ ខ្ញុំដឹងហើយសហព្រះរាជអាជ្ញា គឺគាត់បាន-- គឺយើងដឹងហើយថា សាក្សីគឺគាត់បានមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងការរៀបចំចម្លើយសារភាព ការធ្វើទារុណកម្ម។ ដូច្នេះហើយគាត់មិនអាចឆ្លើយតបទៅនឹងអ្វីដែលសហព្រះរាជអាជ្ញា គាត់សួរនោះទេ។ ហើយប្រសិនបើសហព្រះរាជអាជ្ញាគួរតែ-- ប្រសិនបើសាក្សីដឹងថា ចម្លើយនោះវារបៀបណានោះ គួរតែបណ្តោយទៅ ហើយយើងគួរតែពិចារណាថាតើចម្លើយនោះជាចម្លើយប្រឌិត ឬក៏យ៉ាងណា។ យើងមកទីនេះ គឺដេញដោល ហើយយើងមិនចង់ស្តាប់អ្វី ក្រៅតែពាក្យសម្តីរបស់សាក្សីនោះទេ។ យើងដឹងហើយថា សាក្សីរូបនេះ គឺគាត់បានឆ្លើយនៅក្នុងសំណុំរឿង០០១ ហើយនៅក្នុងនេះគឺយើងបានឱ្យគាត់ស្បថ មិនឱ្យគាត់មានការកុហក។

ខ្ញុំស្នើសុំថា យើងគួរតែឱ្យសហព្រះរាជអាជ្ញា សួរសំណួរក្នុងលក្ខណៈចំហជាជាងការសួរសំណួរនាំមុខ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗ!

**សួរដោយលោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សាក្សីបាននិយាយខាងដើមហើយ ហើយខ្ញុំបានសង្ខេបចម្លើយខាងដើម។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ យើងអាចសួរយឺតៗបានមួយដំណាក់កាលម្តងៗបាន។

**ស៖** នៅពេលដែលលោករៀបចំប្រាំពីរដុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលសម្រាកសិន!

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៤:៣០]

បាទ យើងខ្ញុំសូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីកំណត់សម្គាល់ពីបញ្ហានេះ ហើយនិងសម្រេចលើបញ្ហាជំទាស់ និងការឆ្លើយរបស់ភាគីអម្បាញ់មិញនេះ លើការតាំងសំណួរ ដើម្បីឱ្យការប្រើប្រាស់ពាក្យពេចន៍ឲ្យបានល្អ ហើយនិងត្រឹមត្រូវ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ លោកប្រធាន។ សហព្រះរាជអាជ្ញាត្រូវបានស្នើសុំធ្វើយ៉ាងឲ្យសួរសំណួរៗកុំឲ្យជាសំណួរនាំមុខ គឺអាចសួរឲ្យបញ្ជាក់បំភ្លឺបាន ឧទាហរណ៍ ដើម្បីឆ្លើយតបទៅនឹងសំណួរមុន សាក្សីនិយាយថា ប៉ង់ ជាអ្នកប្រាប់អំពីឈ្មោះទាំងប្រាំពីរដែលជាសមាជិកអចិន្ត្រៃយ៍។ បន្ទាប់មក គឺអាចសួរតបាន។ វាសំខាន់សម្រាប់អង្គជំនុំជម្រះឲ្យយល់ឲ្យបានច្បាស់និងភាគីផងដែរ ធ្វើយ៉ាងណា ពេលសួរ កុំឲ្យជាសំណួរនាំមុខ។ ដូច្នេះហើយ ខ្ញុំស្នើសុំឲ្យសហព្រះរាជអាជ្ញានេះ សួរឲ្យបានច្បាស់លាស់ ហើយកុំឲ្យនាំសួរសំណួរនាំមុខ កុំឲ្យយកពាក្យសម្ដីទៅឲ្យសាក្សីឆ្លើយ។ ហើយសូមលោក កាណាវាស ចៀសវាងកុំប្រើពាក្យថា "*ខន់ហ្វេប្បូឡឺស*" ជាជាងសូមឲ្យប្រើពាក្យផ្សេង ដើម្បីឲ្យអ្នកបកប្រែអាចមានលក្ខណៈងាយស្រួលក្នុងបកប្រែ។ ហើយចំពោះខាងសហព្រះរាជអាជ្ញា គឺគួរតែសួរសំណួរណាដែលឲ្យសាក្សីនោះ ឲ្យភាគីទាំងអស់គ្នាបានយល់ ហើយកុំឲ្យសំណួរដែលបានសួរនោះ ជាសំណួរនាំមុខ។

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណ លោកស្រីចៅក្រម។

[១៤:៣៦:២៨]

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោកសាក្សី នៅពេលណាដែល ប៉ង់ បានប្រាប់លោកថា អ្នកទាំងអស់នោះ ជាសមាជិកអចិន្ត្រៃយ៍?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ខ្ញុំសួរ ប៉ង់ គឺនៅពេលដែល ប៉ង់ ចុះឡើងមក ក្នុងឋានៈជាអ្នកនាំពាក្យរបស់ ប៉ុល ពត។ មកគ្រប់គ្រង មកបញ្ជាស-២១។

**ស៖** តើលោកដឹងទេ ថាតើគាត់ប្រាប់លោកនៅពេលណាពីសមាជិកនៃគណៈអចិន្ត្រៃយ៍ បានន័យថា តើគាត់ប្រាប់លោកនៅឆ្នាំណា?

**ឆ៖** ប៉ង់ ចុះមកជួបខ្ញុំជាហូរហែ ដូចនៅឆ្នាំ១៩៧៧។ មនុស្សនេះ មកដល់ ស-២១ យូរដែរហើយៗ។ ប៉ុន្តែចាត់តាំងជាផ្លូវការឲ្យចុះមក គឺក្នុងរវាងឆ្នាំ៧៧។

**ស៖** នៅពេលដែលគេប្រាប់លោកអំពីសមាជិកនៃគណៈអចិន្ត្រៃយ៍ បានន័យថា ពេលគេប្រាប់លោកថាមានសមាជិកប្រាំពីររូបនៅក្នុងគណៈអចិន្ត្រៃយ៍ ថាតើគេប្រាប់លោកនៅពេល-- នៅមុនពេលដែលលោករៀបចំឯកសារទាំងប្រាំពីរនោះ? ឬក៏នៅក្រោយពេលដែលលោករៀបចំឯកសារទាំងប្រាំពីរដុំនោះ?

**ឆ៖** ខ្ញុំវង្វេងហើយៗ មិនដឹងជាមុន ឬក្រោយទេ ប៉ុន្តែសង្ស័យមុន ខ្ញុំមិនច្បាស់ទេ។ ព្រោះបើសិនជាក្រោយ ខ្ញុំឮប្រភពពីរហ្នឹង ខ្ញុំអត់ប៊ានធ្វើប្រាំពីរអ៊ីចឹងទេ។ ដូច្នេះអាចមុន។

**ស៖** លោកបាននិយាយថា ណាត ក៏ប្រាប់លោកដែរ អំពីសមាជិកទាំងប្រាំពីររូបនៃគណៈអចិន្ត្រៃយ៍ តើលោកចាំបានទេ ថាតើនៅពេលដែល ណាត ប្រាប់លោក?

**ឆ៖** អរគុណ។ ខ្ញុំបានបញ្ជាក់អំមិញមួយបន្តិចដែរថា ណាត គាត់ចង់ណាស់ ចង់បានចូលមជ្ឈិមនឹងគេ។ ហើយពេលនុ៎ង មេខ្ញុំអរ ដែលបក្សប្រគល់ភារកិច្ចឲ្យគាត់ពីរ។ យោធាផង សន្តិបាលផង។ គាត់និយាយប្រាប់ ណាត។ នេះ ណាត មកនិយាយជាមួយខ្ញុំ។ រួចពេលហ្នឹង ដែលណាត ប្រាប់ខ្ញុំថាអចិន្ត្រៃយ៍មជ្ឈិមបក្ស មានប្រាំពីរនាក់ ហើយគាត់រៀបរាប់មក ដូចខ្ញុំរៀបរាប់ហូរហែអ៊ីចឹង។ ដូច្នេះរវាងខែ១១ ឬយ៉ាងយូរណាស់ខែ១២។ រវាងខែ១១ ឬខែ១២។

**ស៖** តើនៅក្នុងឆ្នាំណាដែរ? គឺថាខែវិច្ឆិកា ឬក៏ខែធ្នូហ្នឹង តើនៅក្នុងឆ្នាំណាដែរ?

**ឆ៖** អរគុណ។ ៧៥ៗ។

[១៤:៤០:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំង អញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យនាំ អញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅម៉ោងបី គឺបានមុនអង្គជំនុំជម្រះចូលកាន់អាសនៈ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកសាក្សី! នៅពេលដែលយើងឈប់សម្រាកចំណុចចុងក្រោយ ដែលខ្ញុំសួរនោះគឺថា ណាតបានប្រាប់លោកនៅក្នុងខែវិច្ឆិកា ឬក៏ខែធ្នូ ឆ្នាំ១៩៧៥ ដែលប្រាប់លោកថាមាន ប្រាំពីរនាក់ ដែលជាសមាជិកគណៈអចិន្ត្រៃយ៍។ ហើយថាតើលោកអាចជម្រាបដែរឬទេ នៅពេលណាដែលគេចាប់ ឈូក យកទៅដាក់នៅស-២១ នោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំភ្លេចហើយ លេខបញ្ជីចូល សួស នៅ ហៅ ឈូក មាននៅបញ្ជីចូលរបស់ ស-២១។ បញ្ជីកម្មេចដែលការិយាល័យសហព្រះរាជអាជ្ញាសរុបឲ្យខ្ញុំ ១២.០០០នាក់ប្លាយនោះ មាននៅក្នុងនុ៎ង។ សួស នៅ ហៅ ឈូក ហៅ ឆែម ទៀត។

**ស៖** សូមអរគុណ។ តើលោកអាចនិយាយបានដែរឬទេ នៅក្នុងឆ្នាំ១៩៧៥ ឬក៏ក្រោយ៧៥ ឬក៏លោកមិនដឹងទាល់តែសោះ?

[១៥:០៣:៣៦]

**ឆ៖** អត់ទោស បកប្រែដាច់មួយកំណាត់ហើយ។ ស្អីក្រោយ៧៥ មុន៧៥ ឬមិនដឹងទាល់តែសោះ។ ខ្ញុំអត់យល់សំណួរហ្នឹង។

**ស៖** ខ្ញុំដឹងថា លោកមិនដឹងថ្ងៃខែដែលគេចាប់ខ្លួន ឈូក ដូច្នេះថាតើគេចាប់គាត់នោះនៅក្នុងឆ្នាំ ៧៥ ឬក្រោយឆ្នាំ៧៥?

**ឆ៖** អរគុណ។ ក្រោយ៧៥ រវាង៧៧ ឬក៏ចុង៧៦។

**ស៖** សូមអរគុណ។ ក្រោយពីគេទូរស័ព្ទ ក្រោយពីនិយាយទូរស័ព្ទជាមួយ សុន សេន ពាក់ព័ន្ធទៅនឹង ឈូក តើក្រោយមកលោកបានឮពី សុន សេន ដែរឬទេ ថាតើគេសម្រេចយ៉ាងម៉េចទៅលើ ឈូក នេះ? បាទ គឺជាមួយនឹង ឈូក នេះ?

**ឆ៖** អរគុណ។ ក្រោយពីប្រជុំគ្នាហ្នឹង សុន សេន គាត់ដំណាលប្រាប់ខ្ញុំថា ប៉ុល ពត ឲ្យគាត់អានឯកសារដែលស-២១ ផ្តល់ឲ្យ។ ដល់អានមួយសន្ទុះហើយ ប៉ុល ពត សួរគាត់ថា លទ្ធភាព មិត្តឈូកប៉ុន្មានភាគរយជាខ្មាំង។ សុន សេន គាត់ឆ្លើយថា ៥០ភាគរយ ហើយទៅ សុន សេន គាត់ប្រាប់ថា បងភឹម ឆ្លើយភ្លាមថា ១០០ភាគរយ។ ហើយបានខ្ញុំបាននិយាយជាមួយនឹងគាត់ ម៉េចបានបងមិនមានប្រសាសន៍ថា ១០០ភាគរយ? នេះខ្ញុំសួរ សុន សេន អ៊ីចឹង។ គាត់ថា ឪុច! តែកាលណាផ្លូវនយោបាយតែកាលណាគេនិយាយតែ៥០ភាគរយហ្នឹង វាពេញលេញទៅហើយ។ នេះរឿងរ៉ាវដែល សុន សេន ដំណាលប្រាប់ខ្ញុំក្រោយពីការប្រជុំអចិន្ត្រៃយ៍លើកនោះ។

[១៥:០៦:០១]

**ស៖** លោកនិយាយៗឈ្មោះបុគ្គលមួយ ឈ្មោះ ភឹម តើឈ្មោះអីដែរ ឈ្មោះពេញ?

**ឆ៖** សោ ភឹម។

**ស៖** ភឹម?

**ឆ៖** ភឹម, សោ ភឹម លេខាភូមិភាគបូព៌ា មេផ្ទាល់របស់ ឈូក។

**ស៖** សូមអរគុណ។ លោកនិយាយថា គណៈមជ្ឈិមនេះមានបួនថ្នាក់ ហើយលោកបានលើកឡើងបីថ្នាក់ គឺមួយ ថ្នាក់ទីមួយទាបបំផុតនោះ គឺជំនួយការមជ្ឈិម។ ពីរ គឺមជ្ឈិមត្រៀម ហើយមជ្ឈិម--អចិន្ត្រៃយ៍មជ្ឈិម។ អ៊ីចឹងថាតើបាត់មួយថ្នាក់នោះ តើថ្នាក់អាថ្នាក់ចុងក្រោយគេទីបួននោះ គឺអ្វីដែរ?

**ឆ៖** មិនចុងក្រោយទេ ថ្នាក់ទីបីដែលខ្ពស់ជាងមជ្ឈិមត្រៀមហ្នឹង គេហៅថា "មជ្ឈិមពេញសិទ្ធិ"ៗ ហើយបានលើមជ្ឈិមពេញសិទ្ធិហ្នឹង គឺអចិន្ត្រៃយ៍។

[១៥:០៧:៣៣]

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលលក្ខន្តិកៈម្តង នៅក្នុងមាត្រា២៥។ មាត្រា២៥ ចែងថា "គណៈកម្មាធិការមជ្ឈិមត្រូវប្រជុំជាសាមញ្ញប្រាំមួយខែម្តង ដើម្បីពិនិត្យតាមដាន វិនិច្ឆ័យការងារចាស់គ្រប់ផ្នែក ហើយលើកការងារថ្មីគ្រប់ផ្នែក"។ សំណួររបស់ខ្ញុំចង់សួរទៅកាន់លោក គឺតើគណៈកម្មាធិការប្រជុំប្រាំមួយខែម្តងដែរឬទេ តាមដែលលោកដឹង? បើមិនដូច្នោះទេ តើគណៈកម្មាធិការមជ្ឈិម

ប្រជុំជាញឹកញយប៉ុនណាដែរ?

**ឆ៖** អរគុណ។ សំណួរនេះលើសពីសមត្ថភាពយល់ដឹងរបស់ខ្ញុំ។

**ស៖** តើលោកអាចនិយាយទេ ថាតើគណៈកម្មាធិការមជ្ឈិមជួបប្រជុំគ្នាញឹកញយប៉ុនណាដែរ?

**ឆ៖** ខ្ញុំសូមនិយាយជាក់ស្ដែងអំពីការរៀនសូត្រប្រចាំឆ្នាំ។ ការរៀនសូត្រប្រចាំឆ្នាំ គឺមួយឆ្នាំម្ដងជារៀងរាល់ឆ្នាំ រវាងខែមិថុនា ឬខែកក្កដា។ ដូច្នេះនៅពេលដែលមជ្ឈិមប្រជុំគ្នាហ្នឹង មិត្តម៉េត បងមុត អីក៏ទៅរៀននឹងគេដែរ ព្រោះគេចូលជាសមាជិកមជ្ឈិមដែរ ដល់គេចេញមកវិញ បានៗ សុន សេន គាត់មកបង្រៀនពួកខ្ញុំ។ ហើយអត់មានមុខពីរនាក់ហ្នឹងទៅរៀនជាមួយនឹងខ្ញុំទេ គេរៀនរួចហើយ។ ដូច្នេះនេះជាការសង្កេតក្នុងកិច្ចដំណើរការប្រចាំឆ្នាំរៀងរហូតមក។ ហើយរឿងនេះមិនមែនក្រោយ៧៥ទេ គឺមានតាំងពី៧១មក។ រាល់ឆ្នាំឱ្យតែខែប្រាំមួយ ខែប្រាំពីរ សមាជិកមជ្ឈិមគេទៅរៀនជាមួយ ប៉ុល ពតហើយ។ នេះខ្ញុំគ្រាន់តែឆ្លើយបានប៉ុណ្ណឹង។ តាមការសង្កេតឃើញជាក់ស្ដែង ហើយតាមការដែលវគ្គអប់រំខ្ញុំបានទទួលរាល់ឆ្នាំ ក្រោយពីមជ្ឈិមគេរៀនសូត្រ។

[១៥:១០:៣៥]

**ស៖** តើលោកដឹងថាមានសមាជិកគណៈកម្មាធិការមជ្ឈិមប៉ុន្មាននាក់ដែរ ដែលមិនស្នាក់នៅ រស់នៅក្នុងទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ ប៉ុន្តែលេខាភូមិភាគទាំងអស់សុទ្ធតែសមាជិកមជ្ឈិម។ ដោយឡែក សោ ភឹម លេខាភូមិភាគបូព៌ា អនុលេខាមជ្ឈិម។ អ៊ុង ជឿន ហៅ ម៉ុក លេខាភូមិភាគនិរតី អនុលេខាមជ្ឈិម។ ដូច្នេះអចិន្ត្រៃយ៍មជ្ឈិមនៅក្រៅពីរនាក់ នៅភ្នំពេញប្រាំនាក់។

**ស៖** សូមអរគុណ។ តើលោកអាចពន្យល់អំពីទំនាក់ទំនងរវាងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមដែរឬទេ?

**ឆ៖** ខ្ញុំសូមពន្យល់ថា លេខា ឬក៏ហៅថា គណៈកម្មាធិការភូមិភាគគ្រប់ភូមិភាគ ដែលជាសមាជិកមជ្ឈិមដែរហ្នឹង ស្ថិតនៅក្រោមបញ្ជារបស់លេខានិងអនុលេខាទីមួយ។ ឯចំណែក សមាជិកអចិន្ត្រៃយ៍ផ្សេងទៀត គេមានការងាររបស់គេដោយឡែក។ ឧទាហរណ៍ អៀង សារី គាត់កាន់ខាងការបរទេស ទាក់ទងជាមួយនឹងបក្សម៉ាក្ស-ឡេនីន ជាបងប្អូន បក្សម៉ាក្ស-ឡេនីន ផ្សេងទៀត ហើយនិងទាក់ទងជាមួយនឹងរដ្ឋ។ សុន សេន ខាងយោធា ហើយនិងសន្តិបាល វន វេត សេដ្ឋកិច្ច។ គេមានមុខសញ្ញារបស់គេអ៊ីចឹង។

**ស៖** គណៈកម្មាធិការមជ្ឈិម និងគណៈម្មាធិការអចិន្ត្រៃយ៍ តើលោកអាចនិយាយបានដែរឬទេ តើគណៈកម្មាធិការមួយណាក្នុងចំណោមពីរហ្នឹង ដែលមានអំណាចខ្លាំងជាង? តើលោកអាចដឹង អាចនិយាយបានដែរឬទេ?

**ឆ៖** អំណាចទាំងអស់ប្រមូលនៅក្នុងកណ្ដាប់ដៃលេខា គឺ ប៉ុល ពត។ ក៏ប៉ុន្តែ នួន ជា នៅទុំងជាមួយគ្នា។ កាលណា ប៉ុល ពត រវល់ នួន ជា ជំនួស។ កាលណា ប៉ុល ពត សម្រេច នួន ជា តាមដានការអនុវត្ត។ ដូច្នេះ អំណាចមូលនៅលើ ប៉ុល ពត និង នួន ជា។

[១៥:១៤:១៨]

**ស៖** នៅក្នុងឯកសារនេះ ហើយនៅពេលដែលយើងមើលឈ្មោះនីមួយៗនៅក្នុងឯកសារនេះ ខ្ញុំចង់សួរលោក ប្រសិនបើលោកស្គាល់កាលបរិច្ឆេទ និងស្គាល់ឈ្មោះបុគ្គលនៅក្នុងនេះ ដើម្បីជួយពន្យល់ឲ្យអង្គជំនុំជម្រះបានយល់។ ប្រហែលជា ខ្ញុំសូមអនុញ្ញាតផ្ដល់ជាឯកសារក្រដាសជូនសាក្សី--

**ប្រធានអង្គជំនុំ៖**

កុំអាលសិន នៅមានការជំទាស់ពីមេធាវីការពារក្ដី។ សូមអញ្ជើញមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោសដែលខ្ញុំកាត់។ ខ្ញុំមិនចង់ឲ្យប្រតិចារឹករបស់យើងកាត់ដាច់កង់ៗដូច្នេះនោះទេ។ សហព្រះរាជអាជ្ញាបានសន្យាក្នុងថ្ងៃនេះ និងពីមុនរួចមកហើយថាគាត់នឹងសួរសំណួរបន្ត។ ដូច្នេះហើយយើងចង់ឲ្យសហព្រះរាជអាជ្ញាសួរដេញទៅលើព័ត៌មានដែលសាក្សីបានឆ្លើយ។ យើងដឹងហើយថា យើងឃើញថាសាក្សីបានសរសេរឯកសារមួយចំនួនរួមទាំងឯកសារនៅក្នុងសំណុំរឿង០០១ ផងដែរ។ ដូច្នេះ តើគាត់បានសរសេរឬក៏យ៉ាងណា? ហើយខ្ញុំគួរតែសុំឲ្យសហព្រះរាជអាជ្ញានេះគាត់សួរបន្ត ថាតើព័ត៌មានដែលគាត់ឆ្លើយ សាក្សីឆ្លើយអម្បាញ់មិញនេះគឺដឹងមកពីណា? តាមអ្វីដែលគាត់ដឹង ឬក៏ជាការដឹងឃើញដោយផ្ទាល់?

[១៥:១៦:២៣]

**លោក វីញ្ចៀម ស្មីត៖**

គោលបំណងនៃការដាក់ឯកសារនៅចំពោះមុខសាក្សី ដើម្បីឲ្យយើងដឹងថាបុគ្គលមួយចំនួនឈ្មោះនៅក្នុងឯកសារនោះ គឺដើម្បីឲ្យសាក្សីហ្នឹង ផ្ដល់ជាព័ត៌មានទាក់ទងទៅនឹងតួនាទីរបស់បុគ្គលទាំងអស់នោះនៅក្នុងហ្នឹង។ ហើយយើងក៏ចង់សាក្សីមើលទៅលើកម្មវត្ថុមួយចំនួននៅក្នុងឯកសារនេះ ថាតើ

កម្មវត្ថុដែលសរសេរនៅក្នុងឯកសារនេះស្របគ្នាទៅនឹងអ្វីដែលគាត់ជឿថា ជាការពិតនៅពេលនោះដែរឬទេ? ហើយក៏អាចជួយដល់អង្គជំនុំជម្រះបញ្ជាក់យថាភាពទៅលើឯកសារមួយនេះផងដែរ។ អាចឱ្យចៅក្រម ភាគីយល់ថាតើមានយថាភាពឬក៏យ៉ាងណា? ភាសាដែលគេប្រើនៅក្នុងឯកសារនេះ គឺយើងឃើញហើយថាវាមានការប្រើប្រាស់ស៊ីសង្វាក់គ្នា ដោយបក្ខជននៅពេលនោះ។ ហើយនៅក្នុងនេះក៏មានកាលបរិច្ឆេទផងដែរ ហើយខ្ញុំនឹងសួរសាក្សី វាកាន់តែមានភាពងាយស្រួលសម្រាប់យើង ប្រសិនបើព័ត៌មានទាំងអស់នេះដាក់បញ្ចាំង និងឱ្យសាក្សីបានមើល ហើយយើងខ្ញុំអាចនិយាយជាមួយនឹងសាក្សីអំពីបញ្ហាឯកសារនេះ។

[១៥:១៧:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រមជាទីគោរព ហើយសូមគោរពអស់លោក លោកស្រីនៅទីនេះ និងនៅក្រៅបន្ទប់សវនាការ។ អ្វីដែលខ្ញុំយល់ពីសហព្រះរាជអាជ្ញាគឺសហព្រះរាជអាជ្ញាគាត់បាននិយាយជាមួយនឹងចៅក្រមអង្កេត ដែលក្នុងនោះបានបញ្ជាក់សេចក្ដីប្រកាសមួយថា សហព្រះរាជអាជ្ញាមិនដែល-- សាក្សីមិនដែលបានឃើញឯកសារនេះរហូតដល់ពេលគាត់មកដល់មន្ទីរឃុំឃាំង ទើបឃើញឯកសារនេះ។ ហើយនៅពេលនេះយើងសុំបញ្ចាំងឯកសារ ហើយឱ្យសាក្សីបញ្ជាក់នោះ វាមិនសមហេតុផលទេនៅក្នុងកាលៈទេសៈនេះ។

[១៥:១៨:៣២]

ពាក់ព័ន្ធទៅនឹងអនុញ្ញាតឱ្យសាក្សីនេះនិយាយអំពីឈ្មោះបុគ្គលនៅក្នុងឯកសារ ខ្ញុំគិតថាហេតុអ្វីចាំបាច់បង្ហាញឯកសារធ្វើអ្វី? សហព្រះរាជអាជ្ញាអាចសួរទៅ តើបុគ្គលនេះជានរណា? ឈ្មោះអី? ហើយអាចឱ្យសាក្សីពន្យល់បាន។ យើងឃើញថា វាមានវិធីដែលយើងអាចពិភាក្សាយកព័ត៌មានតាមឯកសារនេះ ហើយយើងមិនចាំបាច់បង្ហាញឯកសារនេះទៅដល់សាក្សីនោះឡើយ។ វាមិនមែនជាឯកសារមួយសាមញ្ញទេ។ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង សាក្សីបានជម្រាបជូនសហចៅក្រមស៊ើបអង្កេតរួចហើយ ថាគាត់មិនដែលឃើញឯកសារនេះទាល់តែសោះនៅក្នុងអំឡុងពេលនោះ។ ដូច្នេះខ្ញុំសុំលើកឡើងថា ការដេញដោលត្រង់ចំណុចនេះ គឺគួរតែប្រើឯកសារផ្សេងទៅ។ សហព្រះរាជអាជ្ញា គឺគាត់ថា

ប្រសិនបើមិនប្រើឯកសារនេះ មិនមែនជាគុណប្រយោជន៍។ ដូច្នេះ ខ្ញុំសូមជួយទៅដល់សហព្រះរាជអាជ្ញាចុះ។ ហើយប្រសិនបើគាត់ សាក្សីគាត់មកដល់ទីនេះហើយគឺថាគាត់អាចផ្តល់ព័ត៌មានទាក់ទងទៅនឹងសម័យនោះ ហើយនិងព័ត៌មានផ្សេងទៀត។

[១៥:១៩:៤៥]

សាក្សីមិនអាចមកទីនេះដើម្បីបញ្ជាក់យថាភាពទៅលើឯកសារនោះឡើយ។ សាក្សីគ្រាន់តែអាចនិយាយអំពីបញ្ហាដែលមាននៅក្នុងឯកសារ ហើយនៅពេលដែលយើងបង្ហាញឯកសារនៅចំពោះមុខសាក្សី ហើយយើងយកមកដេញដោល ថាតើខ្លឹមសារនោះយ៉ាងម៉េចនោះ? ក៏វាមិនជាការសមហេតុផលដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីអន្តរជាតិការពារក្តី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

កុំព្យូទ័ររបស់ខ្ញុំ ហើយអេក្រង់របស់ខ្ញុំនេះ អត់ដើរទេ ដូច្នេះហើយខ្ញុំមិនអាចឃើញឯកសារនេះជាឯកសារអ្វី។ ខ្ញុំសូមជំទាស់ការបញ្ចាំងឯកសារនេះ ហើយសហព្រះរាជអាជ្ញាមិនបានសួរដេញតព័ត៌មាន-- ដេញព័ត៌មានបន្តនោះទេ។ ហើយគាត់ក៏តែសួរអំពីថាតើនរណាខ្លះជាសមាជិកមជ្ឈិម គេទទួលខុសត្រូវអ្វីខ្លះ? ខ្ញុំដឹងថាសហព្រះរាជអាជ្ញាគួរតែអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិជ្ជាជីវៈរបស់ខ្លួន ហើយគួរតែសួរសំណួរដេញបន្ត ដោយផ្អែកទៅលើព័ត៌មាន។ ហើយខ្ញុំគិតថា ព័ត៌មានដែលបានសួរនៅក្នុងឯកសារនេះ មាននៅក្នុងសំណុំរឿង ក៏មិនសមរម្យដែរ យកមកសួរនៅទីនេះ។ សហព្រះរាជអាជ្ញា ខ្ញុំដឹងហើយ ថាគាត់នឹងសួរសំណួរបន្ត ហើយខ្ញុំកំពុងតែរង់ចាំ ការសួរសំណួរពីសហព្រះរាជអាជ្ញាដែលគាត់សន្យាថា គាត់នឹងសួរបន្តអំពីសមាជិករបស់គណៈប្រធានរដ្ឋនោះ តែគាត់បែបជាមិនសួរ។

[១៥:២១:១៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា បញ្ហាចម្បងគឺអ្វីដែលយើងដកចេញពីលក្ខខណ្ឌដែលអង្គជំនុំជម្រះបានលើកឡើងអំពីការដាក់ឯកសារនៅចំពោះមុខសាក្សី គឺថាយើងចាំបាច់ឲ្យសាក្សីនោះ គាត់

ស្គាល់ទៅលើឯកសារ ឬក៏កម្មវត្ថុ និងបញ្ហាដែលមានសរសេរនៅក្នុងឯកសារ។ មុនពេលឯកសារមួយចំនួននោះ ដាក់នៅចំពោះមុខសាក្សី។ យើងយល់អំពីហេតុផលដែលតម្រូវឲ្យធ្វើដូច្នេះ។ បើមិនធ្វើដូច្នេះទេ គឺថាយើងនឹងអ្នកដឹកនាំ-- ដឹកមុខទៅលើសាក្សី។ យើងមិនធ្វើអ៊ីចឹងទេ យើងនឹងគ្រាន់តែសួរសំណួរដេញ បន្តមួយចំនួនតែប៉ុណ្ណោះ។ ប្រសិនបើសាក្សីគាត់ស្គាល់គ្រប់គ្រាន់ ឬក៏គាត់ដឹងទៅលើបញ្ហាដែលមានសរសេរនៅក្នុងឯកសារ។ ការដែលយើងសួរគាត់ឲ្យឆ្លើយ គឺឲ្យយើងយល់អំពីភាសាដែលគេប្រើនៅក្នុងឯកសារនោះ ហើយយើងអាចយល់អំពីទម្រង់ដែលគេប្រើប្រាស់នៅក្នុងរបបនោះ។ ហើយក៏វាឲ្យយើងយល់អំពីហេតុការណ៍ដែលគេសរសេរនៅក្នុងឯកសារនេះ ដោយសារសាក្សីបានពន្យល់អំពីលក្ខណៈនៃឯកសារ កាលបរិច្ឆេទជាដើម។

[១៥:២២:៥១]

ដូច្នេះហើយ ចំណុចនេះគឺជាមូលដ្ឋានដែលយើងខ្ញុំសូមលើកឡើងថា សមស្របដែលយើងដាក់ឯកសារនៅចំពោះមុខសាក្សី។ យើងមិនលើកឡើងព័ត៌មាន និងឲ្យសាក្សីឆ្លើយនោះទេ។ គ្រាន់តែយើងផ្តល់ព័ត៌មានបន្ថែមឲ្យសាក្សីគាត់យល់អំពីភាពពាក់ព័ន្ធ តម្លៃនៃឯកសារ និងយថាភាពតែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រមបានស្តាប់ឮ នៅក្នុងពេលដែលយើងដេញដោលទៅលើឯកសារ ហើយសហព្រះរាជអាជ្ញាត្រូវតែបញ្ជាក់អំពីយថាភាពទៅលើឯកសារដែលខ្លួនបានលើកឡើង។ យើងមិនស្ថិតនៅក្នុងស្ថានភាពមួយ ដែលថា ថាតើឯកសារទាំងអស់នោះ ដែលយើងលើកឡើង វាទំនងជាអាចទុកចិត្តបាន ឬក៏មិនអាចទុកចិត្តនោះទេ។ យើងមិនលើកឡើងដូច្នេះនោះទេ។ អ្វីដែលយើងចង់ធ្វើនៅទីនេះ គឺដើម្បីផ្តល់ឱកាសទៅឲ្យសាក្សី ផ្តល់តម្លៃបន្ថែមពាក់ព័ន្ធទៅនឹងឯកសារនេះ ថាតើយើងគិតថា វាមានយថាភាព ឬក៏អត់?

ចំពោះបញ្ហាជាក់លាក់ដែលសរសេរនៅក្នុងឯកសារ យើងខ្ញុំសូមបញ្ជាក់ថា វាគឺជាវិធាន ឬក៏ក្រឹត្យក្រមមួយដែលយើងលើកឡើងនៅក្នុងនេះតែប៉ុណ្ណោះ។ ហើយប្រសិនបើសាក្សី គាត់មិនមានចំណុច-- មិនមានចំណុចអ្វីចង់បញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃឯកសារនោះទេ វានឹងបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់។

[១៥:២៤:១៧]

វាមានទំនាក់ទំនងរវាងសាក្សីដែលគាត់ត្រូវយល់អំពីឯកសារនេះ។ វិធានរបស់តុលាការអន្តរជាតិក៏បានចែងទៅលើចំណុចនេះ។ នៅពេលនេះ ដោយសារតែខ្ញុំអាចលើកឡើងក្តីមួយចំនួន លើកយកមក

បាន តុលាការអន្តរជាតិអនុញ្ញាតឲ្យយើងសួរនៅពេលដែលសាក្សីគាត់ដឹងដោយផ្ទាល់ទៅលើខ្លឹមសារនៃឯកសារ ឬក៏ទិដ្ឋភាពមួយចំនួននៃឯកសារ។ យើងអាចបង្ហាញឯកសារនេះទៅដល់សាក្សី ឲ្យគាត់ឆ្លើយបាន។ ចំណុចទីពីរ ប្រសិនបើសាក្សី គាត់មានការដឹងដោយផ្ទាល់ទៅលើហេតុការណ៍ ឬក៏បុគ្គលណាមួយដែលមាននៅក្នុងឯកសារ ហើយអាចផ្ដល់ព័ត៌មានលម្អិតទៅដល់អង្គជំនុំជម្រះ។ សាក្សីគាត់អាចបង្ហាញថា តើវាមានន័យយ៉ាងម៉េច? ការធ្វើដូច្នេះនោះ គឺជួយឲ្យយើងយល់អំពីការធ្វើសេចក្ដីសន្និដ្ឋានរបស់យើងចុងក្រោយ ហើយអាចឲ្យការពារក្ដី គាត់អាចសន្និដ្ឋានបានទៅលើអ្វីដែលបានលើកឡើង។ សាក្សីដែលមកដល់ទីនេះ ក្នុងពេលនេះ គឺគាត់អាចឲ្យយើងយល់ឲ្យបានច្បាស់លាស់។ បញ្ហាដែលចំណុចនេះដែលថា សម្រេចទទួល ឬមិនទទួលនោះ គឺអាស្រ័យទៅលើអង្គជំនុំជម្រះ។

ខ្ញុំសុំលើកឡើងរឿងក្ដីមួយចំនួន ហើយរឿងក្ដីទាំងអស់នេះមានការពិបាកក្នុងការរកណាស់។ ដែលក្នុងនោះវាពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចទៅលើបញ្ហាដែលយើងកំពុងជួបប្រទះ។ វាពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចនៅក្នុងប្រតិចារឹកក្នុងសាលាក្ដីនានា គឺរឿងក្ដីរវាងសហព្រះរាជអាជ្ញា និង *សេស៊ែល* (Šešelj) ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០២ តុលាការ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ ដែលក្នុងនោះលើកឡើងថា សាក្សីមិនដែលឃើញឯកសារនេះទេ។ ចៅក្រមលើកឡើងដូច្នេះ ក៏ប៉ុន្តែឯកសារនោះបានលើកឡើងចំណុចមួយចំនួនដែលយើងឃើញថាស៊ីសង្វាក់ទៅនឹងអ្វីដែលសាក្សីលើកឡើង។ ដូច្នេះ សហព្រះរាជអាជ្ញាអាចសួរសំណួរដេញដោល ហើយនៅពេលដែលសួរ គឺអាចមើលទៅលើភស្តុតាង។

[១៥:២៦:២៩]

នៅពេលដែលយើងមើលទៅលើឯកសារនោះ គឺយើងឃើញថាកខណ្ឌមួយចំនួនស៊ីសង្វាក់ ហើយដូចទៅនឹងដែលសាក្សីបានលើកឡើង។ ដូចដែលសាលាដំបូងបានសន្និដ្ឋាននៅក្នុងចំណុចរបស់ខ្លួនការដែលលើកឡើងនេះ វាពាក់ព័ន្ធដល់យើងអាចទទួលយកបាននូវឯកសារ ដោយសារវាពាក់ព័ន្ធទៅនឹងយកថាភាព និងភាពទុកចិត្តបាន។

ចំពោះសេចក្ដីសម្រេចរដ្ឋអាជ្ញា ជាមួយនឹងក្រាជីស្ទីក ឆ្នាំ២០០៤ ត្រង់ទំព័រ៤២៩២ រដ្ឋអាជ្ញាទល់នឹងលូប៊ែងហ្កា នៅតុលាការអន្តរជាតិឆ្នាំ២០០៩ ត្រង់ទំព័រទី៣ យើងឃើញថាមានបញ្ជាក់ទៅលើចំណុចហ្នឹង សេចក្ដីសម្រេចដទៃទៀត ក៏បានលើកឡើងដូចគ្នាផងដែរ។

ជាមូលដ្ឋាននោះគឺថាលក្ខខណ្ឌ គឺតម្រូវដូច្នេះថា ប្រសិនបើសាក្សីមានលទ្ធភាពក្នុងការពន្យល់ឲ្យយើងយល់ទៅលើហេតុការណ៍ កាលបរិច្ឆេទបុគ្គល ឬក៏លក្ខណៈនៃឯកសារជូនតុលាការបាននោះ គឺ

យើងអនុញ្ញាត។ មិនមែនថា គាត់មិនឃើញឯកសារពីមុននោះ គឺមិនអាចឆ្លើយទៅបាននោះទេ។ ការដែលគាត់ឆ្លើយបន្ថែមទៅលើឯកសារនេះ គឺមិនមែនឆ្លើយជាន់គ្នាទេ គឺបន្ថែមតម្លៃទៅលើឯកសារ។

[១៥:២៧:៥២]

នៅចុងក្រោយជនជាប់ចោទ ខាងមេធាវីជនជាប់ចោទ គាត់អាចលើកឡើងថា នេះគឺជាអ្វីដែលឯកសារនេះលើកឡើង ហើយយើងមិនអាចទទួលយកបាននោះទេ។ ក៏ប៉ុន្តែចំពោះសាក្សីមួយនេះ គឺឯកសារដែលយើងចង់សួរដើម្បីឱ្យយើងយល់អំពីខ្លឹមសារនៃឯកសារនេះ ពាក្យពេចន៍ដែលគេប្រើ ហើយបុគ្គលដែលនៅក្នុងនោះ គឺយ៉ាងម៉េច?

ត្រង់ចំណុចនេះហើយដែលយើងខ្ញុំស្នើសុំឱ្យដាក់ឯកសារនេះនៅចំពោះមុខសាក្សី។ វាជាទម្រង់បទដ្ឋានមួយឱ្យយើងយល់ទាំងអស់គ្នា ហើយវាអាចជួយឱ្យអង្គជំនុំជម្រះយល់ផងដែរ។ ជាការពិតទៅយើងមិនមែនព្យាយាមដឹកនាំសាក្សីឱ្យឆ្លើយចម្លើយទៅលើឯកសារ និងភស្តុតាងនោះឡើយ។

[១៥:២៨:៤៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**កញ្ញា លី ម៉ាញឿន៖**

សូមគោរព លោក លោកស្រីចៅក្រមជាទីគោរព! យើងកំពុងតែប្រឈមនឹងការជំទាស់ពីរខុសគ្នាពីខាងក្រុម អៀង សារី និង នួន ជា។ ឆ្លើយតបទៅនឹងការជំទាស់ៗដែលលើកឡើងជូនតុលាការដោយមេធាវី អៀង សារី ហើយបន្តពីសហព្រះរាជអាជ្ញា។ យើងខ្ញុំគិតថា យើងគួរតែគិតអំពីប្រព័ន្ធរបស់យើងដែលយើងប្រព័ន្ធច្បាប់ស៊ីវិលឡូ ដែលយើងត្រូវពិចារណាអំពីទម្ងន់នៃភស្តុតាង។ ជាពិសេសនៅពេលដែលយើងដាក់ឯកសារនៅចំពោះមុខសាក្សី។

ពាក់ព័ន្ធទៅនឹងការជំទាស់របស់មេធាវី នួន ជា ប្រសិនបើមេធាវីការពារក្តីមិនមានការជំទាស់ចំពោះការដាក់ឯកសារនៅចំពោះមុខសាក្សីនោះទេ យើងយល់ឃើញថា ភាពទុកចិត្តបាននៃឯកសារដែលសាក្សីអាចនិយាយអំពីឯកសារនោះ វាផ្តល់ជាតម្លៃបន្ថែមទៅលើបញ្ហាដែលមាននៅក្នុងឯកសារ ហើយមេធាវីការពារក្តីក៏អាចធ្វើការដេញដោលចំពោះមុខផងដែរ។ នេះជាយោបល់ខ្លី ដែលខ្ញុំសូមលើកឡើង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ មេធាវីការពារក្តី ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់បន្ថែមទៅលើការជំទាស់ខាងភាគីការពារក្តីតែប៉ុណ្ណោះ។ ខ្ញុំអម្បាញ់មិញគិតថា អត្ថបទ-- ឯកសារនេះគឺថាមានការជំទាស់ ហើយក៏ប៉ុន្តែអង្គជំនុំជម្រះមិនទាន់បានធ្វើសេចក្តីសម្រេចទៅលើភាពទទួលយកបាននៃឯកសារនេះនៅឡើយទេ។ ដូច្នេះគឺ អ៊ីចឹងមូល-- អ៊ីចឹងគឺថាមូលហេតុនេះ យើងមិនអាចយកឯកសារនេះមកបង្ហាញជូនសាក្សីបាននោះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៣:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ ក្រោយពីពិភាក្សាអង្គជំនុំជម្រះសម្រេចប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ខាតរាយថ៍ ដើម្បីឆ្លើយបំភ្លឺដោះស្រាយបញ្ហានេះចំពោះភាគី។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ កាលពីសប្តាហ៍មុន គឺយើងទទួលបាននូវការជំទាស់ប្រហាក់ប្រហែលគ្នាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយយើងបានសម្រេចថា ភាគីណាមួយក៏ដោយក៏អាចដាក់ឯកសារនៅចំពោះមុខសាក្សី ហើយសួរដល់សាក្សី ថាតើសាក្សីធ្លាប់ឃើញឯកសារនេះពីមុនមកដែរឬអត់? ប្រសិនបើចម្លើយសាក្សីថា អត់ទេ នៅពេលនោះ គឺយើងត្រូវដកឯកសារនោះចេញពីសាក្សី ព្រោះបើមិនដូច្នេះទេ គឺវាអាចបង្ហាញថា សាក្សីគាត់អានចម្លើយពីក្នុងឯកសារនោះ។

ដូច្នេះហើយ គឺយើងត្រូវតែដកឯកសារនោះចេញភ្លាម ចេញដោយផ្ទាល់ពីសាក្សី។ ហើយសាក្សីហើយៗអាចចោទសួរសំណួរទៅសាក្សីអំពីប្រធានបទនៃឯកសារនោះ។ នៅពេលដែលមានការជំទាស់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ បានន័យថា នៅពេលដែលមានការជំទាស់ដដែលៗនេះ គឺយើងជម្រាបដល់ភាគីនានាថា ភាគីទាំងអស់មានឯកសារដើម្បីដេញដោលសាក្សីជាពេលក្រោយ ហើយអាចនឹងចោទទៅលើបញ្ហាទាំងអស់នេះ។ ខ្ញុំមិនប្រើប្រាស់ពាក្យថា "ដេញដោលសាជាថ្មី" ដែលហៅថា *"ក្រូស អ៊ិចសាមមីនេសិន"* នោះទេ ប៉ុន្តែគ្រាន់តែចង់និយាយថា ភាគីនានាអាចមានឱកាស

ដើម្បីដេញដោលសួរសាក្សី នៅពេលដែលវេនរបស់ខ្លួនបានមកដល់។

[១៥:៣៥:៣៨]

ដូច្នេះយើងមិនគួរឲ្យមានការ-- ដូច្នេះការបដិសេធនេះ គឺគ្មានប្រសិទ្ធភាព។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។

សាក្សី តើលោកមានឯកសារនៅចំពោះមុខលោកដែរឬទេ? គឺឯកសារ IS.63។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារជូនទៅសាក្សីពិនិត្យ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកសាក្សីសូមអញ្ជើញពិនិត្យមើលទៅលើឯកសារ ហើយថាតើលោកធ្លាប់ឯកសារនេះពីមុនមកដែរទេ?

[១៥:៣៦:៤៤]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ឯកសារនេះ គឺសហចៅក្រមស៊ើបអង្កេតយកមកសួរខ្ញុំ នៅក្នុងរយៈកាលស៊ើបអង្កេត។ ខ្ញុំបានអាន បានរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត។ ហើយសេចក្ដីសរុបរបស់ខ្ញុំនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ក៏ខ្ញុំឈរនៅលើឯកសារនេះដែរ។ ខ្ញុំសូមសង្ខេបប៉ុណ្ណេះ។

**ស៖** តើលោកអាចអានចំណងជើងនៃឯកសារ ហើយនិងកាលបរិច្ឆេទបានទេ? បន្ទាប់មកខ្ញុំនឹងចោទសួរសំណួរមួយចំនួនទៅលើខ្លឹមសារនៃឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

[១៥:៣៧:៥៣]

**លោក អាកទូរ វែកគែន៖**

បាទសូមអរគុណប្រធាន។ ខ្ញុំធ្វើការជំទាស់នៅក្នុងការបន្តសួរទៅសាក្សីនេះទៀត។ ខ្ញុំគិតថាដោយអនុលោមតាមវិធានដែលទើបនឹងបានលើកឡើងអម្បាញ់មិញនេះ ដោយអ្នកស្រីចៅក្រម ខាតវ៉ាយថ៍។ ការ១បង្ហាញឯកសារ ដែលថាឯកសារនេះសាក្សីមិនស្គាល់ទេកាលនៅសម័យដែលកើតអង្គហេតុហ្នឹង

កើតនោះ។ ប៉ុន្តែ៣០ឆ្នាំក្រោយមក នៅក្នុងក្របខ័ណ្ឌសួរចម្លើយតុលាការ ខ្ញុំដូចជាមិនយល់ថា ហេតុអ្វីបានជាសហព្រះរាជអាជ្ញាអនុញ្ញាតចោទសំណួរសួរទាំងអស់នេះខ្លួនឯង? ព្រោះថាវិធានដែលបានកំណត់ដោយអង្គជំនុំជម្រះនេះ ថាមិនត្រឹមតែថាកំណត់ឲ្យស្គាល់តាំងពីថាពីរឿងអតីតកាលទេ គឺថាឲ្យដឹងរឿងកាលពីសម័យនោះទៀតផង។ នៅពេលដែលថា លក្ខខណ្ឌទាំងនេះមិនត្រូវមានប្រមូលផ្តុំនោះ មិនត្រូវបានបំពេញនោះ គឺថាអត្ថបទនេះមិនត្រូវអាចជាកម្មវត្ថុនៃការសួរចម្លើយនោះទេ។ អ៊ីចឹងខ្ញុំគិតថា មិនមែនជាការយល់ស្របទេក្នុងការចោទសំណួរនោះ។

[១៥:៣៩:០៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីជាតិការពារក្តីឲ្យលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមបញ្ជាក់បន្ថែមទៅលើសហការីរបស់ខ្ញុំ។ ទាក់ទងទៅនឹងសំណួរដែលតំណាងសហព្រះរាជអាជ្ញាបានលើកអម្បាញ់មិញនេះ គឺបានចោទសំណួរទៅសាក្សីថា បានឃើញឯកសារនេះទេពីមុនមក? អ៊ីចឹងចំណុចនេះធ្វើឲ្យសាក្សីច្រឡំថា ពីមុនមកហ្នឹង ពីមុនៗពេលដែលបង្ហាញហ្នឹង ឬមួយក៏ពីមុនតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ? វាជាចំណុចដែលត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់ថា សាក្សីបានស្គាល់នៅពេលណា? បានឃើញនៅពេលណា? អ៊ីចឹងមិនមែនៗ នៅក្នុងនីតិវិធីស៊ើបអង្កេតនោះទេ ហើយក៏មិនមែននៅក្នុងនីតិវិធីបង្ហាញឯកសារនៅក្នុងសំណុំរឿង០០១ ដែរ។ គឺត្រូវតែបញ្ជាក់ថា តែបានស្គាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរឬទេ?

បាទ សូមអរគុណ។

[១៥:៤០:០០]

**ប្រធានអង្គជំនុំ៖**

អាចមានការភ័ន្តច្រឡំ ហើយមិនច្បាស់លាស់។ មានអ្វីលើកឡើងតបទៅនឹងអ្វីដែលជំទាស់របស់មេធាវី? សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំគិតថាឯកសារនេះបានទទួល ហើយខ្ញុំ-- ឯកសារនេះ គឺឯកសារ E3/12 ហើយដែលបានដាក់ពីមុនរួចមកហើយ។ ហើយសាក្សីគាត់អាចជួយសម្រួល

ដល់យថាភាពនៃឯកសារនេះ ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយទាក់ទងទៅនឹងសេចក្តីនៅក្នុងដំណាក់កាលមួយនេះ យើងសូមជម្រាបដល់អង្គជំនុំជម្រះថា យថាភាពនៃឯកសារហ្នឹង បានន័យថាយថាភាពនៃឯកសារដែលសាក្សីមិនធ្លាប់ឃើញ គឺមិនអាចមានដូច្នេះទេ។ ដូច្នេះ យើងនឹងលើកឡើងនៅពេលក្រោយមួយទៀត។ អ្វីដែលខ្ញុំយល់ គឺថាសេចក្តីសម្រេចហ្នឹង បានន័យថា សាក្សីហ្នឹងបានអានឯកសារហ្នឹងពីមុនមក ទោះបីថា ទោះបីគាត់អាននៅក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ ឬក៏នៅពេលក្រោយ នៅពេលក្រោយក៏ដោយនោះដែរ។

ដូច្នេះហើយ នៅក្នុងករណីមួយនេះ ដូចដែលសហការីខ្ញុំបានបង្ហាញអ៊ីចឹង គឺថានៅក្នុងសំណុំរឿងសាក្សីគាត់អាចបង្ហាញនូវចំណុចផ្សេងៗគ្នានៃឯកសារមួយនេះ បានន័យថា គាត់អាចបង្ហាញបានដោយមិនមែនជាការអានឡើងវិញ មិនមែនជាការនិយាយឡើងវិញនៅលើឯកសារនោះឡើយ។ ដូច្នេះហើយ នេះគឺជាអ្វីដែលសហព្រះរាជអាជ្ញាចង់បាន។ ហើយម្យ៉ាងទៀត កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីហ្នឹង គឺថាសាក្សី គាត់អាចផ្តល់តម្លៃបន្ថែមទៀតទៅលើតម្លៃនៃឯកសារនេះ ហើយគាត់នឹងអាចបំពេញបន្ថែម ឬក៏អាចផ្តល់តម្លៃបន្ថែមទៅលើឯកសារដែលយើងអាចទទួលបានក្រៅពីឯកសារនេះ។

[១៥:៤២:១២]

ដូច្នេះ បើតាមខ្ញុំយល់ ការសម្រេចនៅក្នុងដំណាក់កាលនេះ គឺវាមិនពាក់ព័ន្ធ ថាតើសាក្សីគាត់អានឯកសារហ្នឹងមុន ឬក៏ក្រោយនោះទេ។ បានន័យថា មិនសំខាន់ តើគាត់អាននៅក្នុងរបបហ្នឹង ឬក៏ក្រោយរបបនោះទេ។ អានេះគឺជាអ្វីដែលខ្ញុំយល់ពីសេចក្តីសម្រេចនោះ។ សូមអរគុណ។

**លោក អាកទូរ វែកកែន៖**

លោកប្រធាន បាទខ្ញុំហាក់ដូចជាយល់ឃើញថា វិធានដែលកំណត់ដោយអ្នកស្រីចៅក្រមខាតវ៉ាយថ៍ អម្បាញ់មិញនេះ គឺថានៅពេលដែលលាក់ឯកសារហ្នឹង ដែលថាសាក្សីមិនស្គាល់នៅសម័យខ្មែរក្រហមនោះទេ។ តើយើងមិនអាច-- យើងអាចចោទសំណួរទៅលើប្រធានបទដែលមាននៅក្នុងអត្ថបទហ្នឹង ក៏ប៉ុន្តែមិនមែនដើម្បីផ្ទៀងផ្ទាត់ថា តើចម្លើយរបស់សាក្សីហ្នឹងស៊ីគ្នាទៅនឹងខ្លឹមសារអត្ថបទហ្នឹងឬទេ? ក៏ប៉ុន្តែផ្ទុយទៅវិញ គឺថាយើងមិនអាចបង្ហាញឯកសារហ្នឹង ឬក៏ថាព្យាយាមធ្វើឲ្យគាត់ សួរគាត់ថាតើអត្ថបទហ្នឹងមាន ឬក៏មិនមាន? ហាក់ដូចជាគាត់ហ្នឹងជាអ្នកដែលមានជំនាញខាងឲ្យដឹងថាអត្ថបទហ្នឹងមានមែន ឬក៏មិនមែន? ឯកសារហ្នឹងមាន ឬក៏មិនមែន? ខ្ញុំគិតថា ដូច្នេះនេះវាមិនជាការសមស្របនោះទេ។

E1/54.1

[១៥:៤៣:៤១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ។ ខ្ញុំសូមលើកយកសង្ខេបទេ។ ខ្ញុំកត់សម្គាល់ឃើញថា សាក្សីគាត់កំពុងតែអានឯកសារហ្នឹងហើយ នៅពេលដែលយើងកំពុងតែពិភាក្សាគ្នា។ ដូច្នេះ ខ្ញុំគិតថាតើគោលដៅនៃការសម្រេចហ្នឹង តើវាមានន័យយ៉ាងម៉េចដែរ នៅពេលដែលគាត់អានព័ត៌មានដែលគាត់មិនគួរនឹងអាន មិនគួរនឹងមើលនោះ? សូមអរគុណ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន អង្គជំនុំជម្រះទើបតែកំណត់វិធានមួយដែលត្រូវតែអនុវត្តចំពោះភាគីទាំងអស់ទាក់ទងទៅនឹងការបង្ហាញឯកសារទៅសាក្សី។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំឮគេនិយាយដែលថា ដោយហេតុថាឯកសារនេះត្រូវបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹង ដូច្នេះយើងមិនត្រូវការពិភាក្សាទៅថ្ងៃនេះទៀតនេះ។ នេះគឺជាការយល់ច្រឡំ វិធានដែលអង្គជំនុំជម្រះទើបតែដាក់ចេញនេះ គឺថាត្រូវអនុវត្តចំពោះភាគីទាំងអស់ ក៏ប៉ុន្តែមិនចំពោះនៃ ចៅក្រមស៊ើបអង្កេតនោះទេ។ ដូច្នេះសាក្សីនេះ គាត់ទើបនឹងបាននិយាយថាគាត់ដឹងឯកសារនេះ ស្គាល់ឯកសារនេះតាំងពីយូរណាស់មកហើយ គឺថាក្នុងដំណាក់កាលស៊ើបអង្កេត។ ដូច្នេះ ខ្ញុំគិតថាយើងអាចស៊ើប-- យើងពិភាក្សាអំពីឯកសារនេះបានពីព្រោះថាអ្វីធ្វើដោយសហចៅក្រមស៊ើបអង្កេតនោះ មិន-- ត្រូវតែគោរព-- មិនគោរពតាមអង្គជំនុំជម្រះយើងនោះទេ។ បាទជាការពិតណាស់ថា ដែលគាត់បានពិភាក្សាអំពីឯកសារនេះជាមួយសហចៅក្រមស៊ើបអង្កេតតាំងពីមុនមក។ ខ្ញុំនៅចាំថាខ្ញុំបានអាននៅក្នុងប្រតិចារឹកនៃបណ្តឹងឧទ្ធរណ៍របស់លោក ឌុច ដែលគាត់ ដែលបានលើកអំពីសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៅខែមីនា។ ដូច្នេះ មិនមែនជាឯកសារថ្មីនោះទេ មិនមែនជាឯកសារថ្មីដែលសហព្រះរាជអាជ្ញាដាក់ជូនអង្គជំនុំជម្រះនោះទេ។

[១៥:៤៥:៤២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ហើយតាមការសង្កេតរបស់យើងឃើញថា ទំនងជាមានការភ័ន្តច្រឡំលើការបកប្រែ ដែលឆ្លងកាត់ការប្រើប្រាស់ភាសាទាំងបីនៅក្នុងការសម្រេចអំពីបញ្ហាអម្បាញ់មិញនេះ ដែល

មានការភ័ន្តច្រឡំថា ឯកសារដែល-- លុះត្រាតែឯកសារនោះជាឯកសារសាក្សីហ្នឹងបានស្គាល់ បានឃើញពីមុននៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងដីកាចោទប្រកាន់បញ្ជូនរឿងមកជំនុំជម្រះនេះ ឬមួយក៏ការដែលឃើញស្គាល់ហ្នឹង គឺមុនពេលមកផ្តល់សក្ខីកម្មនេះ។

តាមដែលយើងខ្ញុំទទួលព័ត៌មានតាមការបកប្រែភាសាគឺលោកស្រីចៅក្រមមិនបានកំណត់ថា ឯកសារដែលដាក់ចំពោះមុខសាក្សីត្រូវតែជាឯកសារដែលសាក្សីនោះបានឃើញ បានស្គាល់នៅក្នុងអំឡុងពេល ឬក៏មុនពេលកម្ពុជាប្រជាធិបតេយ្យឡើយ។

ដើម្បីបញ្ជាក់បញ្ហានេះឲ្យកាន់តែច្បាស់ ដោយអម្បាញ់មិញនេះ អង្គជំនុំជម្រះបានប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ដើម្បីបញ្ជាក់បញ្ហានេះឲ្យច្បាស់លាស់ ដោយសារការប្រើប្រាស់នូវភាសាអង់គ្លេសដែលជាភាពពាក់ព័ន្ធនឹងការប្រើប្រាស់ហ្នឹងវាជាក់ច្បាស់។

[១៥:៤៧:២៤]

អ៊ីចឹងគឺយើងខ្ញុំក្នុងនាមអង្គជំនុំជម្រះ សូមប្រគល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់លើចំណុចនេះឲ្យកាន់តែច្បាស់លាស់ថែមទៀត ក្រែងលោការស្តាប់របស់យើងខ្ញុំ និងការពិភាក្សារបស់យើងខ្ញុំមានការភ័ន្តច្រឡំ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៩:៤៨]

អញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា សេចក្តីសម្រេចរបស់ខ្លួនមិនគួរមានការយល់ច្រឡំនោះទេ គឺថាយើងព្យាយាមឲ្យ បង្ហាញឲ្យសាក្សីគាត់ដឹងអំពីព័ត៌មានទាំងអស់នេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អាចជាសួរគាត់ ថាតើគាត់ធ្លាប់ឃើញពីមុន ប្រសិនបើគាត់មិនធ្លាប់ឃើញពីមុនទេ គាត់-- នៅពេលនោះ គាត់មិនអាចបង្ហាញពីយថាភាពនៃឯកសារ។ ហើយនៅពេលដែលគាត់មិនអាចបង្ហាញពីយថាភាពនៃឯកសារទេ គឺត្រូវដកឯកសារចេញពីគាត់។ ការបង្ហាញយថាភាពនៃឯកសារ គឺវាមិនសំខាន់ទេនៅក្នុងករណីនេះ។ ព្រោះថា ឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ។ គឺបានន័យថា ឯកសារហ្នឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ។ ដូច្នេះហើយ ឯកសារនេះគឺអាចសាក្សីពន្យល់បង្ហាញបាន ហើយនិងអនុញ្ញាតឲ្យភាគីនានា

គាត់ពិនិត្យពិចារណា និងចោទសួរបន្ថែមនៅពេលដែលភាគីនានាចង់បាន។ ដូច្នេះ ការជំទាស់គឺគ្មានប្រសិទ្ធភាព។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាបន្តតាំងសំណួរ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ មុននឹងខ្ញុំបន្ត ខ្ញុំសូមបង្ហាញថាមានចំណុចមួយនៃសេចក្តីសម្រេចនេះ ដែលព្រះរាជអាជ្ញាចង់បង្ហាញនៅពេលក្រោយទៀត ប្រហែលជានៅពេលដែលភាគីទាំងអស់គ្នា គឺថាភាគីទាំងអស់គ្នានឹងទទួលបានឱកាសរៀងៗខ្លួន។

[១៥:៥១:៥១]

ដូច្នេះ យើងចង់បង្ហាញថានៅមានឱកាសនៅសប្តាហ៍ក្រោយ ឬក៏ពេលណាមួយដែលភាគីនានាអាចលើកឡើងអំពីចំណុចជាក់លាក់ណាមួយ ទាក់ទងទៅនឹងសេចក្តីសម្រេចនេះ។ ប៉ុន្តែ ក្នុងពេលឥឡូវនេះ ខ្ញុំស្នើថា អាចថានៅចុងក្រោយ ឬក៏នៅពេលណាមួយ។ ដូច្នេះ ខ្ញុំនឹងបន្តសំណួររបស់ខ្ញុំ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សាក្សី តើលោកមានឯកសារនៅចំពោះមុខលោកដែរឬទេ? តើលោកធ្លាប់អានឯកសារនោះ ពីមុនដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំធ្លាប់បានអាន។ ខ្ញុំធ្លាប់បានអធិប្បាយ ហើយក៏ធ្លាប់បានលើកយកខ្លឹមសារកថាខណ្ឌទីមួយនៃឯកសារនេះ សរសេរនៅក្នុងពាក្យតវ៉ារបស់ខ្ញុំ។

**ស៖** សូមអរគុណ។ ចំណងជើងនៃឯកសារនេះ គឺសេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ដែលចុះថ្ងៃ៣០ ខែមីនា ឆ្នាំ៧៦។ ហើយចំណុចទីមួយនៃឯកសារនេះ គឺនិយាយអំពីសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ។ សំណួរដែលខ្ញុំចង់សួរលោក គឺបានន័យថា បន្ទាប់ពី-- ថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦ មក តើមានការកើនឡើងក្នុងការសម្លាប់ដែរឬទេ បើតាមលោកសង្កេតឃើញនៅក្នុងមន្ទីរស-២១? ឬមួយក៏ថាតើមានការកើនឡើងក្នុងចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ដែរឬទេ?

[១៥:៥៣:៥៨]

**ឆ៖** ខ្ញុំចំពោះខ្លឹមសារនេះ ខ្ញុំបានអត្ថាធិប្បាយជូនសហចៅក្រមស៊ើបអង្កេតហើយ។ ឯកសារ

ថ្ងៃ៣០ កញ្ញា-- អ៎ ៣០ មីនា ១៩៧៦ នេះ វាញែកសម័យ។ មុន ៣០ មីនា ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាកម្ទេចសមាសភាពពួក លន់ នល់។ ក្រោយនោះ បក្សកុម្មុយនីស្តកម្ពុជាកម្ទេចសាច់ឯង ឈាមឯង គឺផ្ទៃក្នុងជួរបក្សហ្នឹងតែម្តង។ ជាយុទ្ធជន យុទ្ធនារី បក្ខជន កម្មាភិបាល។ នេះ ខ្ញុំបានញែកបញ្ហានេះជាពីរអ៊ីចឹង។ បើនិយាយពីចំនួនមនុស្សស្លាប់ មុនថ្ងៃ៣០ មីនា វាច្រើនជាងមែន។

**ស៖** តើខ្ញុំស្តាប់ត្រឹមត្រូវដែរឬទេ ដែលថាមានគេសម្លាប់មនុស្សច្រើននៅឆ្នាំ-- នៅថ្ងៃទី៣០-- នៅមុនថ្ងៃ៣០ ខែ៣ ឆ្នាំ៧៦ តើខ្ញុំស្តាប់ត្រឹមត្រូវដែរឬទេ?

**ឆ៖** ជឿថាអ៊ីចឹង។ ហើយលោកព្រះរាជអាជ្ញាពិតជាស្តាប់ត្រឹមត្រូវ។

**ស៖** ចំនួនប្រជាជននៅមន្ទីរស-២១ បានថាចំនួនអ្នកត្រូវសម្លាប់នៅមន្ទីរស-២១ គឺមានច្រើនជាងដប់ពីរពាន់នាក់។ ថាតើនៅពេលណាដែលចំនួនមនុស្សដែលត្រូវសម្លាប់ហ្នឹងកើនឡើងខ្លាំងនៅមន្ទីរស-២១?

**ឆ៖** នៅមន្ទីរស-២១ យើងអត់បានបូកស្ថិតិដាច់ដោយឡែកពីគ្នាទេ។ ១២.២៧៣នាក់ គឺស្ថិតិតាំងពីសម័យ ណាត រហូតដល់ចុងបញ្ចប់។ ឯចំណែកនៅក្នុងសម័យ ណាត សម្លាប់ភាគច្រើនពួកអ្នករាជការ អ្នកនេសាទថៃចូលដីខ្មែរ ពួកមូស្លីមនៅភូមិអារ៉ាប់ស្អីៗហ្នឹងមួយចំនួន។ បញ្ជីម្រយ ដូចជារប៉ាត់រប៉ាយខាងកាលបរិច្ឆេទ ក្រោយមកបានបញ្ជីម្រយ វាត្រឹមត្រូវ។ ដូច្នេះចំនួនវាអាចច្បាស់លាស់ យើងសរុបបាន។ ដូច្នេះ ផ្ទៃក្នុងវាទៅផ្សេង សមាសភាពអតីតអ្នករាជការវាទៅផ្សេង។

[១៥:៥៦:៥៦]

**ស៖** ក្នុងចំនួនមនុស្ស ១២.០០០នាក់ នោះថា តើៗលោកអាច-- ថាតើប្រហែលប៉ុន្មាននាក់ដែរដែលត្រូវសម្លាប់មុនថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦? តើប្រហែលប៉ុន្មានដែរ?

**ឆ៖** មិនប៊ានសន្និដ្ឋានពាសវាលពាសកាលទេ បញ្ជីមាននៅក្នុងនុំង យើងអាច ទាំងអស់គ្នាទៅមើល។ ដូច្នេះមិនបដិសេធទេ ក៏ប៉ុន្តែយើងនាំគ្នាទៅមើលបញ្ជី វាជាគោលភស្តុតាងហើយ។

**ស៖** សូមអរគុណ។

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រម ឥឡូវនេះ ខ្ញុំចង់សួរសាក្សីអំពីបញ្ហានៃអង្គការដែលមានចែងនៅក្នុងឯកសារនេះ ខ្ញុំត្រូវការពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ ហើយខ្ញុំគិតថា ចម្លើយអាចនាំទៅដល់ការយល់ដឹងបន្ថែម ឬក៏ការសិក្សាបន្ថែមអំពីរចនាសម្ព័ន្ធ ឬក៏អំពីអង្គភាពនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើខ្ញុំអាចបន្ត

ទៅទៀតបានឬទេ?

[១៥:៥៦:១៩]

**ប្រធានអង្គជំនុំ៖**

លោកត្រូវចំណាយពេលវេលាប្រហែលប៉ុន្មានទៅ? លោកតំណាងអយ្យការត្រូវការពេលវេលាប្រហែលប៉ុន្មានទៅសំណួរចុងក្រោយនេះ?

**លោក វីល្លៀម ស្មីត៖**

ប្រហែលជាដប់ប្រាំនាទីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ពេលវេលាដូចវែងដែរ ដោយសារយើងធ្វើសវនាការរាល់ថ្ងៃ ហេតុដូច្នេះពេលវេលាហ្នឹងសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកទៅ។

អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សីទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយឲ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកត្រឹមម៉ោងប្រាំបួន។ ហើយដូចគ្នា គឺបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនឹងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*